ថោង-ឃីណូ គ្រូបង្រៀន

# បញ្ជាក់ សទិសសព្ទ




វ៉ា.64

415.
ខមារ
គ.គ. ខែ ថ្មី ៧៣-១១-៦៥
4/179 - 4170 42
B-5
D-42
N° 91

ថោង-យីណ
គ្រូបង្រៀន

បញ្ជាក់

# សទិសសព្ទ

សម្រាប់បឋមភូមិបំពេញវិជ្ជា

រក្សាសិទ្ធិ បោះពុម្ពលើកទី ១
គ.ស. ១៩៦៥ ១០០០ក្បាល

# អារម្ភកថា

សៀវភៅនេះ កើតឡើងដោយសារការសន្សំពាក្យមួយ-ម៉ាត់ៗ ដែលខ្ញុំបានយកមកបង្រៀនសិស្សតាំងពីឆ្នាំ ១៩៥៥ ហើយនិងដកស្រង់ពីក្នុងអត្ថបទផ្សេងៗ ឯទៀតជាច្រើន ដូចជាក្នុងសារព័ត៌មានក្តី សៀវភៅនានាក្តីដែលខ្ញុំបានប្រទះឃើញ ៗ ពាក្យទាំងប៉ុន្មានក្នុងសៀវភៅនេះ សិស្សតែងធ្លាប់បាននិយាយធ្លាប់បានសរសេរជាញឹកញយដែរហើយ ដូចជាពាក្យ : "ជន·ជន់-ជន្ម ឬ ព្រាប-ព្រៀប-ប្រៀប.." តែការកាន់ប្រឡំនៅតែមានជាធម្មតា ព្រោះពាក្យទាំងនេះ សុទ្ធមានសូរសព្ទស្រ-ដៀងៗគ្នា ៗ ហេតុនេះហើយ បានជាខ្ញុំខំប្រមែប្រមូល ពីនេះបន្តិច ពីនោះបន្តិច យកមកបង្គ្រង់ធ្វើជាសៀវភៅមួយឲ្យឈ្មោះថា "បញ្ជាក់សទិសសព្ទ" ហើយខ្ញុំបានរៀបរៀងពាក្យនិមួយៗ ធ្វើជាឃ្លានិយាយធម្មតា ហើយថែមទាំងធ្វើជាឃ្លាបញ្ជាក់នឹងពាក្យមួយម៉ាត់ៗ នោះទៀតផង ដើម្បីឲ្យសិស្សឆាប់យល់ន័យពាក្យនោះភ្លាមៗ ៗ

ពិសេសទៅទៀត កាលដែលខ្ញុំរៀបរៀងជាពាក្យទាំងនេះបានហើយខ្ញុំក៏បានយកទៅជូនលោក សាយ-ហៀង ធ្វើការនៅទីចាត់ការកិច្ចការគរុកោសល្យ ឲ្យជួយពិនិត្យនិងកែសម្រួល ។ លោក សាយ-ហៀង ក៏បានយកចិត្តទុកដាក់ជួយផ្តល់យោបល់ និងពិនិត្យកែសម្រួលដកបដល់ចប់ជាស្ថាពរ ។

ជាអវសាន បើពាក្យទាំងប៉ុន្មានដែលមាននៅក្នុងសៀវភៅតូចនេះ ពុំមានគ្រប់គ្រាន់តាមសេចក្តីត្រូវការរបស់លោក-អ្នក-នាងទេ សូមលោក-អ្នក-នាងទាំងឡាយ មេត្តាអភ័យទោសដល់ខ្ញុំបាទ ខ្ញុំផងចុះ ។

ភ្នំពេញ ថ្ងៃទី ១ កញ្ញា គ.ស. ១៩៦៥

ថោង-យីណា

# អក្សរសរសេរកាត់

| | | |
|---|---|---|
| កិរិយាសព្ទ | សរសេរកាត់នឹងអក្សរ | កិ. |
| កិរិយានុគ្រោះ | —ដ— | កិ.នុ. |
| កិរិយាវិសេសន៍ | —ដ— | កិ.វិ. |
| គុណនាម | —ដ— | គុ. |
| នាម | —ដ— | ន. |
| និបាតស័ព្ទ | —ដ— | និ. |
| បរិវារស័ព្ទ | —ដ— | ប. |
| បកតិសំខ្យា | —ដ— | ប.សំ. |
| បុរិសសព្វនាម | —ដ— | បុ. |
| ពាក្យផ្ទុយ | —ដ— | ព.ផ្ទុ. |
| ពាក្យផ្សំ | —ដ— | ព.ផ្សំ. |
| សព្វនាម | —ដ— | សព្វ. |

## សរសេរកាត់នឹងអក្សរ

| | | |
|---|---|---|
| អាយតនិបាត | —ជ— | អា.និ. |
| អានថា | —ជ— | អា.ថ. |
| ឧបានស័ព្ទ | —ជ— | ឧ.ស. |
| ឧទាហរណ៍ | —ជ— | ឧ. |

# ក

ក=ន. កដៃ - កជើង - កដប...

១. សាច់មិនបានស៊ី យកឆ្អឹងព្យួរក ។ ក្បាលជាប់នឹងខ្លួនដោយសារក ។

កក=កិ. កកើត - កកូមិ - កវែកកន្ទាំង កសាង ... ១. វត្តនេះកសាងឡើងជាយូរសតវត្សរ៍មកហើយ ។ កាទើបតែនឹងគេស៊ីកវែកកន្ទាំងទេ ។

ក៏=និ. ទៅក៏ទៅ - ស៊ីក៏ដោយ - ដូចនេះក៏បាន ... ១. អ្នកពល់គ្នា សើចក៏ដោយ យំក៏ដោយ ។ អ្នកក៏ទៅខ្ញុំក៏ទៅ ។

ករ=ន. (ដៃ) កម្មករ - កសិករ - ហត្ថករ ...

១. លើកករប្រណម្យថ្វាយបង្គំផង ។ (លើករ=លើកដៃ)

កត់=កិ. កត់ទុក - កត់ចំណាំ - កត់ចំណានដៃ ...

១. ចូរយើងកត់ចំណាំពាក្យណាដែលពិបាកៗ ។

កដិ=ព.ផ្ស. (អា. ថ. កត់) ប្រាកដ=គុ. ដឹងប្រាកដ. ឃើញ

ប្រាកដ. ប្រាកដប្រជា...

ឧ. ខ្ញុំឃើញប្រាកដជាវាបានចូលមកមែន ។

កណ្ឌ = ន. (អា.ថ.កាន់), (វគ្គ.ខ្សែ) សាស្ត្រាមួយកណ្ឌ...

ឧ. បណ្ឌិតប្រុញទៅខ្ចីសាស្ត្រារឿងខ្យងស័ង្ខមួយ

កណ្ឌពីតាជួន ។

កាន់ = កិ. កាន់ទុក - កាន់អំពាន់ - និយាយកាន់ជើង ...

ឧ. ចូរយើងកាន់ចិត្តឲ្យទៀងត្រង់ ។

កណ្ដាស់ = កិ. ក្អកកណ្ដាស់ ... ឧ. ពូម៉ុលបេះតែកណ្ដាស់

ហៀរទឹកក្ហែកទឹកសំបោរ ។ មុននឹងកណ្ដាស់

ត្រូវយកកូនកន្សែងខ្ទប់មុខ ។

ក្រដាស = ន. ក្រដាសក្រាស់-ក្រដាសស្ដើង-ក្រដាសពណ៌...

ឧ. ចូរកុំយកក្រដាសស្អាតមកសរសេរលេង ។

កន្ទាស់ = ន. កន្ទាស់ក - ស្ទឹកកន្ទាស់...

ឧ. ម្ដាយខ្ញុំបានធ្វើកន្ទាស់កអំពីមាសដាំពេជ្រ ។

កន្ទះ= គុ. កន្ទះមាន់.កន្ទះគោ.កន្ទះពាង.កន្ទះលើគ្រ ...

ឧ. ប្អូនខ្ញុំទៅកន្ទះថ្ងៃហើយ មិនទាន់ឃើញត្រ-

ឡប់មកវិញសោះ ។

ក្រឡាស់= កិ. និយាយក្រឡាស់សំដី . ក្រឡាស់ទៅម្ខាង -

ក្រឡាស់ឲ្យត្រូវ ...

ឧ. ឯងកុំនិយាយក្រឡាស់សំដីយ៉ាងនេះ ។

កល= ន. (អា.ថ-កល់) ល្បិចកល-ឧបាយកល-ទាញកល...

ឧ. នែសម្លាញ់! ប្រយ័ត្នទាញកលឧបាយរបស់ខ្មាំង ។

កល់= កិ. កល់គ្រែ - កល់ពាង - កល់ឲ្យខ្ពស់ ...

ឧ. ឯងយកដុំឥដ្ឋបួនដុំនេះមកកល់គ្រែឲ្យខ្ពស់

បន្តិចឡើង ។

កល្ប= ន. (អា.ថ.កាល់) ឧ. មួយកប្ប មួយកល្បព្រះ ។

កាល់= កិ. មាន់កាល់ញី . កាល់កូន . ពស់កាល់ពង ...

ឧ. មេគោនេះកាល់កូនវា កុំចូលទៅជិតប្រយ័ត្នវាប៉ុះ ។

កប្ប= ន.(អា.ថ.កាប់.)មួយកប្ប.ភ្លើងឆេះកប្ប.(កប្បាស=ន.)

អាកប្បកិរិយា... ១. មួយកប្បព្រះមកហើយ ។

កាប់= កិ. កាប់ទាស . កាប់ក្បាល . កាប់បុស្សី ...

១. កសិករនេះកាប់ដីនឹងចបកាប់ ។

កា= ន. ១. បងខ្ញុំស្រេកទឹក គាត់ពិសាអស់ទឹកបីបួនកា ។

កា= កិ. ១. បើអ្នកកាខ្ទង់សំបុត្រ ត្រូវដាក់អស័យដ្ឋានឲ្យ

ច្បាស់លាស់ ។

ការ= កិ. ការពារ- ការអំបោះ ...

១. ចូរយើងត្រូវចាក់ថ្នាំការពារជម្ងឺ ។

ការ= ន. ធ្វើការ . មានការ . ការអ្វីខ្លះ ?

១. ចុះលោករកប៉ាខ្ញុំមានការអ្វីដែរ ? ។

កាណ៌= ន.(ត្រចៀក) ១. ព្រះកាណ៌ព្រះនាងទ្រង់ពាក់ពេជ្រ

ក្ងឹចិញ្ចៀន ។

ការណ៍= ន. រូបការណ៍ . ទាស់ការណ៍ . ព្រឹត្តិការណ៍

អន្តរជាតិ ...

ឧ. ឯងធ្វើយ៉ាងនេះនាំឲ្យខូចការណ៍អស់ ។

កាប=ក.ស. ឧ. តាប្រដេញគ្នាដណ្ដើមចំណីយំឮសូរកាបៗ

ទ្រហឹងអឹងកង ។

កាព្យ=ន. ពាក្យកាព្យ . កាព្យឃ្លោង . កាព្យា ...

ឧ. បណ្ឌិតប៉ុលបេះតែងកាព្យជូនយ៉ាងរណ្ដំគ្នា ។

កាល=ន. កាលពីដើម . កាលណោះ . កាលណា ...

ឧ. កាលដែលខ្ញុំត្រឡប់មកពីស្រុកកំណើតខ្ញុំវិញ

ខ្ញុំបាន ... ។

កាឡ=ព.ស្យ. (អា.ថ.កាល) កាឡកិណី=ន. ស្រីកាឡកិណី

មេស្រីកាឡកិណី ...

ឧ. ស្រីកាឡកិណីនេះធ្វើបាបកូនគ្មានអាណិត ។

កាឡា=កិ. (តែង-ប្រែ) កាឡាខ្លួន-ប្រែកាឡា-កាឡាខ្លួនជា...

ឧ. ព្រះឥន្ទកាឡាជាតាបសបុសីយ៉ាងជរាមួយអង្គ ។

ក្រឡា= ន. ក្រឡាផ្ទៃ - ក្រឡាឈើត្រង់ - ក្រឡាកន្ទេល - ក្រឡាមង ...

ឧ. ស្រែខ្ញុំមានទំហំផ្ទៃក្រឡាមួយហិចតា ។

កុរ= ន. (អ.ថ.កុលប្បកោ) ឧ. ខ្ញុំកើតឆ្នាំកុរ ខែបេត្រ ថ្ងៃពុធ ។

កុលបុត្ត= ន. កុលធីតា ។ ឧ. កុលបុត្រ កុលធីតា គាប្បី អ្នកខំសិក្សាបំណេះវិជ្ជាផ្សេងៗ ។

កៀក= កិ. កៀកក - កៀកឃៀក - កៀកបង្កើះ ...

ឧ. គូកនពីរនាក់នេះ កៀកកគ្នាដើរលេងកំសាន្ត ក្នុងសួនច្បារ ។

គាក= ព.ផ្ស. ទ្រគាក=ន. ឧ. ស្រីណាទ្រគាកសាយ ស្រីនោះច្រើនងាយសំរាលកូន ។

កៀង= ន. កៀងគោ - កៀងមាន់ - កៀងទា ...

ឧ. អាម៉ុកនៅពេលត្រឡប់មកពីឃ្វាលគោវិញ ក៏កៀងគោបញ្ចូលក្រោល ។

គាង= គុ. (កន្ទុក) - ស្ពាគាង - ស្នែងគាង ...

ឧ. បុរសនេះស្ពាឡើងគាងហើយមាំ ។

កៀត= ន. ធ្វើកៀត - ដើរកៀត - កៀតឈើ ...

ឧ. ឪពុកខ្ញុំ យកឈើធ្វើកៀតឲ្យប្អូនខ្ញុំរៀនដើរ។

គាត= ន. បង់គាត - ជ្រលក់គាត ...

ឧ. ម្ដាយខ្ញុំបង់គាតជ្រលក់ធ្វើហូល ។

កៀប= កិ. (កៀបដោយដង្កៀប) កៀបសួរ - កៀបដៃ - កៀបដើង ...

ឧ. ក្រុមរក្សាសន្តិសុខកៀបសួរចម្លើយអ្នកទោស ម្នាក់នឹងដង្កៀបដែក ។

គាប= កិ. (គាបដោយឃ្នាប) គាបត្នោត គាបកណ្ដាប់ស្រូវ...

ឧ. អ្នកធ្វើស្ករត្នោត គាបផ្កាត្នោតនឹងឃ្នាបឈើ។

កៀរ= កិ. កៀរក . ដើងកៀរបង្កុះ ...

ឧ. កូនឯងកៀរកឪពុកឲ្យជាប់កុំលែងដៃប្រយ័ត្ន

ផ្កាក្រោយ ។

គាវ= ន. គាវគ្នាត . គាវជូង . ប្រកគាវ ...

ឧ. គេង ៗ នាំគ្នាដើររើសគាវគ្នាត គាវជូងទុកឲ្យម្ដាយរាំជុត ។ នៅទីក្រុងវេលាយប់មានចិនលក់គុយទាវ មីទឹងគាវដោយរទេះរុញ ។

កេរ= ន. និយាយកេរ-ហែកកេរគេ...

ឧ. មនុស្សយើង មិនត្រូវនិយាយហែកកេរពីអ្នកដទៃឡើយ ។

កេរ្តិ៍= ន. កេរ្តិ៍ឈ្មោះល្អ . កេរ្តិ៍ខាងឪពុក . កេរ្តិ៍ខាងម្ដាយ...

ឧ. ដីភូមិនេះជាកេរ្តិ៍តំណែលតាំងពីខ្មោចជីតា ជីដូនខ្ញុំមក ។

កេស= ន. (អា.ថ.កេស) (សក់) ព្រះកេស.កេសា ...

ឧ. ព្រះកេសព្រះអង្គឡើងខ្មៅរលោងស្រិល ។

កែស= ន. ត្រីកែស.ត្រីឆ្អើរកែស ...

ឧ. ម្ដាយខ្ញុំទិញត្រីកែសជាច្រើនយកមកឆ្អើរ ទុក
ធ្វើម្ហូបទៅថ្ងៃក្រោយ ។

កៃ= ន. កែកាំភ្លើង.កាំបិតកែ.កេះកែ . . .

ឧ. ព្រានព្រៃតម្ងោះកែកាំភ្លើង ឮសូរផ្ទុះយ៉ាងខ្លាំងៗ

ក័យ= ព.ផ្សុ.(ភា.ថ.កៃ) វិក័យប័ត្រ=ន. ឧ. របស់ទាំងនេះ
ទិញមកសុទ្ធតែមានវិក័យប័ត្រត្រឹមត្រូវទាំងអស់ៗ

កោដ្ឋ= ន.(ប្រដាប់ដាក់ឆ្អឹងខ្មោច).សុវណ្ណកោដ្ឋ.ខត្តិយកោដ្ឋ.

ឧ. គេរើសឆ្អឹងខ្មោចដាក់ក្នុងកោដ្ឋ រួចយកទៅ
ទុកឯវត្ត ។

កោដិ= ប.សំ.មួយកោដិ.ពីរកោដិ . . .

ឧ.មហាសេដ្ឋីនេះមានទ្រព្យសម្បត្តិកប់រយកោដិៗ

កោត= កិ. កោតសរសើរ.កោតញញើត.កោតក្រែង.កោត
.ស្ញប់ស្ញែង.កោតខ្លាច.កោតតែ. . .

ឧ. ក្មេង ៗ ឥឡូវមិនកោតខ្លាចចាស់ព្រឹទ្ធាចារ្យ

ប៉ុន្មានទេ ។

កំពង់= ន. កំពង់ផែ-កំពង់ចម្លង-កំពង់ផ-កំពង់ទឹក ...

១. នៅតាមកំពង់ផែមានកប៉ាល់ ទូក កាណូតចត ត្រៀបត្រា ។

កំពុង= ទ. កំពុងលេង- កំពុងអាស្រ័យបបរ-កំពុងធ្វើការ ...

១. អូនឯងហៅគេមានការអ្វី បើគេកំពុងតែជាប់ដៃធ្វើកិច្ចការ ។

កំពុង= គុ. ពេញកំពុង.បាយកំពុងចាន.ស្រូវកំពុងល្អី ...

១. អ្នកអើយ! រាល់អង្ករកុំឲ្យកំពុងតៅពេកខាត ខ្ញុំស្តាប់ហើយ ។

កាំ= ន. កាំជណ្ដើរ.កាំរទេះ.កាំស្ទូ.កាំកង់.កាំបិត ...

១. គេយកឈើផ្ចឹក ឬ ស្រុក្រំធ្វើកាំជណ្ដើរកជាប់ បានយូរ ។

កម្ម= ន. (ភា.ប.កាំ.) កសិកម្ម.រងកម្ម.ទទួលតាមកម្ម...

ឧ. ក្នុងជាតិនេះ ខ្ញុំទទួលរងកម្មជាងអ្នកដទៃ ។

ក្រាស់= គុ. (ព.ផ្ទ.ស្តើង) ដូងសាច់ក្រាស់.សំពត់ក្រាស់...

ឧ. ពូខ្ញុំគាត់ទិញក្រដាសក្រាស់មកបិទជញ្ជាំង។

ក្រាស= ន. ត្រីត្អើរមួយក្រាស.ក្រាសសិតសក់...

ឧ. ក្រាសដែលយើងសិតសក់រាល់ថ្ងៃ ត្រូវស្អាត ជានិច្ច ។ ត្រីត្អើរកែសមួយក្រាសនេះថ្លៃប៉ុន្មាន?

ក្រិត= កិ. ក្រិតចំណាំ.អព្យាក្រិត . . .

ឧ. ប្រទេសកម្ពុជាកាន់អព្យាក្រិតជាដរាប ទោះ មានសត្រូវមកបៀតបៀនយ៉ាងណាក៏ដោយ ។

ក្រិត្យ= ន. ក្រិត្យវិន័យ.ក្រិត្យក្រម.ធម្មក្រិត្យ . . .

ឧ. ព្រះសង្ឃកាន់ក្រិត្យវិន័យយ៉ាងខ្ជាប់ខ្ជួនតាម ពុទ្ធដីកា ។

ក្រួស= ន. គ្រាប់ក្រួស.ក្រួសអាចម៍ក្អាយ លាយក្រួសនិង ស៊ីម៉ង់ត៍ . . .

ឧ. ចៅកែម៉ុំទិញក្រួស ខ្សាច់ ស៊ីម៉ង់ត៍យកមក
ទុកធ្វើផ្ទះថ្ម ។

គ្រោះ= ន. គ្រោះថ្នាក់.គ្រោះល្អ.គ្រោះជា.គ្រោះអាសន្ន...

ឧ. ប្តីខ្ញុំស្លាប់ដោយគ្រោះថ្នាក់គ្រឡាប់រថយន្ត។

ក្រៀម= គុ. (ព.ផ្ទ.ស្រស់) ក្រៀមក្រោះ.ស្វាយក្រៀម.មុខ
ក្រៀម ក្រៀមក្រំ–ក្រៀមកំព្រឹង ...

ឧ. ថ្ងៃនេះគ្មានម្ហូបអាហារបរិភោគទេ មានតែ
ក្រៀមក្រោះបន្តិចបន្តួច ។

គ្រាម= ន. (ប្រជុំភូមិ.ស្រុក) ឧ. មាតុគ្រាមរបស់ខ្ញុំ ។

ក្រេស= កិ.វិ. ក្រោកក្រេស.លឿនក្រេស.រត់ក្រេស . . .

ឧ. ខ្ញុំកំពុងតែនិយាយនឹងក់ ស្រាប់តែក់ក្រោក
ដើរចេញក្រេសធ្វើកហើ ។

ក្រែះ= គុ. (មិនធំ) មនុស្សក្រែះ-ស្វាក្រែះ

ឧ.កូនក្មេងនេះមិនធំសោះ នៅតែក្រែះដដែល។

ក្រែង= កិ. (ញរញើត-ខ្លាច) ក្រែងតែ- ខ្លាចក្រែង- ក្រែងលោជា...

១.ខ្ញុំក្រែងតែលោកមិនបានអញ្ជើញមកទេដឹង?

ក្រែង= ន. (ខាង១) ជាយក្រែង- នៅតែក្រែង...

១. ក្បាលពុកមាខ្ញុំទំពែកសក់អស់ នៅសល់តែជាយក្រែងបន្តិច ។

ក្រម= ន. (អា.ប.ក្រំ) ច្បាប់ក្រម-ក្រមជំនុំ-ក្រមការ...

១. ចៅក្រមជំនុំជំរះក្តី ដោយយុត្តិធម៌ ។

ក្រំ= គុ. ក្រំក្រោ-ក្រំខ្លួន-ក្រំក្នុងចិត្ត-ក្រៀមក្រំ...

១. ខ្ញុំឈឺម្តងនេះក្រំក្រោធ្វើការអ្វីមិនកើតទេ ។

ក្លស់= ន. (ដូចឆត្រ) បើកក្លស់ បាំងក្លស់...

១. សម្តេចឪយាងចុះពីអាកាសយានដ្ឋាន មានគេយកក្លស់មកបាំងថ្វាយព្រះអង្គ ។

ប្លស់= កិ. ប្លស់ការប្លស់ផារ - ប្លស់ទឹកមុខ ប្លស់សរសៃ-

ថ្លស់ជើងថ្លស់ដៃ...

ឧ. ចូរនាងកុំលេងលោតទន្ទ្រាំលើគំនរឥដ្ឋប្រ-យ័ត្នដួលថ្លស់ជើងថ្លស់ដៃពិការអស់មួយជីវិត ។

ក្លា = គុ. ក្លាហាន-ក្លៀវក្លា-ក្លាសំដី...

ឧ. ពួកទាហានជាតិយើងក្លាហានណាស់ នៅពេលចូលប្រយុទ្ធនឹងខ្មាំង ។

ខ្លា = ន. ខ្លារខិន-ខ្លាដំបង-ខ្លាត្រី-ខ្លាឃ្មុំ...

ឧ. ក្នុងពពួកសត្វខ្លាទាំងអស់ មានតែខ្លារខិនទេដែលសាហាវជាងគេ ។

ក្លាស់ = កិ. ក្លាស់អាវ-មូលក្លាស់-ក្លាស់ហោប៉ៅ...

ឧ. ម្តាយខ្ញុំយកកន្លាស់កមាសដាំពេជ្រ មកក្លាស់ត្រង់កអាវក្លឹបចៃក្លួន ។

ខ្លះ = និ. អ្នកខ្លះ-ខ្ញុំខ្លះ-គេខ្លះឯងខ្លះ-ខុសខ្លះត្រូវខ្លះ...

ឧ. ក្នុងពិធីបុណ្យនេះមានមនុស្សខ្លះទៅ ខ្លះមក

ពុំដាច់ឡើយ ។

ក្លែង= កិ. ក្លែងគេ-ក្លែងក្លាយ-ក្លែងខ្លួន-ក្លែងសំដី...

ឧ. អ្នកក្លែងក្រដាសប្រាក់ នឹងត្រូវផ្ដន្ទាទោស។

ខ្លែង= ន. សត្វខ្លែង-បង្ហើរខ្លែង-ខ្លែងញី ឬ ខ្លែងធំ...

ឧ. ខ្លែងជាសត្វចង្រៃ វាឆាបកូនមាន់កូនទាស៊ី

ជាអាហារ ។

## ខ

ខន្ធ= ន. (អា.ថ.ខាន់) រលត់ខន្ធ-រំលាយខន្ធ-ខន្ធប្រាំ...

ឧ. លោកយាយគាត់បានរំលាយខន្ធបាត់ពេល

យើងទៅហើយ ។

ខ័ន្ធខាត់= ន. ព្រះខ័នភង្ស-ជម្ងឺខាន់ស្លាក់...

ឧ. ព្រះខ័នភង្សតំកល់ក្នុងព្រះបរមរាជវាំង តែ

សព្វថ្ងៃមានគេថែរក្សាជាប្រក្រតី ។

ខណ្ឌ= ន. (គា.ថ.ខាន់) ខណ្ឌសីមា-ខណ្ឌជញ្ជាំង...

១. ផ្ទះខ្ញុំខណ្ឌជញ្ជាំងក្ដារធ្វើជាបន្ទប់ ៗ ។

ខុរ= ១.ស. (គា.ថ.ខុល) ខុរៗ- ស្រមុកខុរ ៗ ...

១. ប្អូនខ្ញុំកដេកស្រមុកឮស្ងូរខុរៗ ក្បែរខ្ញុំ ។

ខុល= គុ. ផ្អកខុល-ប្រហុកខុល...

១. នៅទីនេះដូចជាធុំក្លិនប្រហុកខុលឬ ?

ខួ= ន. ខួក្ដាម-ខួបង្កង-ខួអណ្ដែង...

១. ថ្ងៃនេះស្ងួសម្ងួខួក្ដាមអាស្រ័យម្ដង ។

ខួរ= ន. ខួរឆ្អឹង-ខួរក្បាល-មនុស្សគ្មានខួរ...

១. ខួរក្បាលមនុស្សយើងមានលលាដ៍ និងសក់ការពារពីក្រៅ ។

ខៀន= ន. ក្ដារខៀន-សំពត់ខៀន...

១. ស្រីចាស់ជាន់ដើមច្រើនស្លៀកខៀនចងក្បិន

ឃាន= ន. ឃានវិញ្ញាណ... ១. មនុស្សយើងមានឃានវិញ្ញាណ

ប្រាំគឺកាយវិញ្ញាណ, ចក្ខុវិញ្ញាណ, ជីវ្ហាវិញ្ញាណ,

សោតវិញ្ញាណនិងឃានវិញ្ញាណ ។

ខ្វៃ = កិ. ដែកខ្វៃ-ខ្វៃក្ដារ-ខ្វៃប្រហោង-ខ្វៃឈើ...

ឧ. ជាងឈើខ្វៃក្ដារនឹងដែកខ្វៃយ៉ាងមុត ។

ខ័យ = កិ. (អា.ជ.ខ្វៃ) អាយុខ័យចុះ បុញ្ញក្ខ័យ...

ឧ. មនុស្សបច្ចុប្បន្ននេះអាយុខ័យចុះមកត្រឹមតែ

៧០ ឬ៨០ឆ្នាំ តែប៉ុណ្ណោះ ។

ខោ = ន. ខោជើងវែង-ខោខ្លី-ខោស្ពាប់ក្បៅ...

ឧ. សិស្សទាំងឡាយ ចូរនាំងសំអាតខោអាវ

នាំងឲ្យបានស្អាតល្អជានិច្ច ។

ខោរ = ន. ស្វាខោរ=ស្រដៀងនឹងស្វាក្រេះ...

ឧ. សត្វស្វាមានច្រើនពួកណាស់ គឺស្វាឪស្វា

ក្រោស ស្វាក្រេះ ស្វាព្រាហ្ម និងស្វាខោរ ។

ខ្លា = ន. ខ្លាឃ្មុំ-ខ្លាត្រី-ខ្លាដំបង...

១. ខ្លាជាសត្វសាហាវណាស់ វាចាប់សត្វឯទៀតស៊ីជាអាហារ ។

ក្លា = គុ. គៀវក្លា-ក្លាហាន-ក្លាសំដី...

១. បុរសនេះនិយាយក្លាសំដីណាស់ ។

ខ្លែង = ន. សត្វខ្លែង-ខ្លែងឆាប-ខ្លែងធ្នូ...

១. នៅរដូវលំហើយ ក្មេងៗនាំគ្នាធ្វើខ្លែងបង្ហើរលេងពាសពេញវាលស្រែ ។

ក្លែង = កិ. ក្លែងគេ-ក្លែងពាក្យ-ក្លែងក្លាយ...

១. មាណពនេះប្រសប់ក្លែងសំដីធ្វើដូចជាស្រី ។

ខ្លះ = និ. ខ្លះនៅខ្លះទៅ-ខ្លះសើចខ្លះហៅ...

១. អ្នកជម្ងឺវិកលចរិតនេះនិយាយត្រូវខ្លះខុសខ្លះ

ក្លាស់ = កិ. (ខ្លាស់) ម្ជុលក្លាស់-ក្លាស់គអាវ...

ឧ. ខ្ញុំទិញម្ជុលក្ដាស់មួយប្រអប់ទុកក្ដាស់ក្រ-
ដាសផ្សេងៗ ៗ

ខ្វេះ= កិ. លូកខ្វេះ-ខ្វេះហោប៉ៅ-ខ្វេះដី-ខ្វេះសារសៃ...

ឧ. ចោរលួចខ្វេះរនុកបន្ទប់ ឆក់យកអីវ៉ាន់អស់ៗ

ខ្វែះ= កិ.វិ. របូតខ្វែះ-របើកខ្វែះ-របេះខ្វែះ...

ឧ. ខ្ញុំគ្រាន់តែកាន់បន្តិចស្រាប់តែរបូតខ្វែះតែម្ដងៗ

## គ

គ= គុ. (មិនចេះនិយាយស្ដី) -មនុស្សគ-ធ្វើគធ្វើថ្លង់...

ឧ. មនុស្សនេះគហើយថែមទាំងថ្លង់ទៀតផងៗ

គរ= ន. ដើមគរ - សំឡីគរ - ញាត់គរធ្វើពូកខ្នើយ...

ឧ. នៅស្រែចំការ កសិករច្រើនដាំដើមគរនៅ
តាមជាយរបងផ្ទះ ដើម្បីយកសំឡីទុកប្រើប្រាស់ៗ

គរ= កិ. (ប្រមូលជាគំនរ) គរឧស-គរខ្សាច់-គរគ្រួស...

ឧ. ពូសំទិញខ្សាច់គ្រួសនឹងឥដ្ឋមកគរទុកសំរាប់

សង់ផ្ទះ៤ ឬ ៥ ល្វែងទុកជួលឲ្យអ្នកដទៃ ។

គន់= កិ. គន់គូរ - គន់មើល - រិះគន់ ...

ឧ. ហោរានេះគន់គូរលេខអត្ត: ជូនភ្ញៀវរបស់គាត់ ។

គន្ធ= ន. (អា.ជ.គន់) គន្ធពិដោរ - គន្ធរស - គន្ធជាតិ ...

ឧ. ផ្កាកូឡាបមានគន្ធពិដោរក្រអូបឈ្ងុយ ។

គណ= ន. (អា.ជ.គន់) មេគណ-អនុគណ-ចៅហ្វាយគណ ...

ឧ. លោកគ្រូអនុគណ និមន្តទៅសូត្រមន្តនៅផ្ទះលោកចៅហ្វាយស្រុក ។

គត់= គុ. (ព.ផ្ទុ.សេស) គត់គូ - គត់មត់ - លេខគត់គូ ...

ឧ. អាយុគត់តែត្រូវនិមន្តលោកស្រោចទឹកបម្លងគ្រោះចេញ ។

គត= ន. (អា.ជ.គត់) ធ្វើគត - សុវណ្ណគត - អស្តង្គត - ទីវង្គត ...

ឧ. ព្រះអង្គទ្រង់ទីវង្គតដោយសេនាព្រះអង្គម្នាក់ធ្វើគត

គល់= ន. គល់ឈើ - គល់ដង្គត់ ...គល់ស្លា ...

ឧ. ជនអន្ធការនេះដើរជំពប់ ជើងនឹងគល់ដង្គត់ ឈើបែកឈាមហោច ។

គុល= ឧ. ស. ផ្អើលគុល - គុលឡើង - គុលៗ ...

ឧ. មនុស្សផ្អើលគុល តើមានការអីនៅក្នុងផ្សារ ?

គាង= គុ. (កន្ទក) ស្នែងគាង - ស្មាគាង ...

ឧ. ស្មាកម្លោះនេះឡើងគាងមើលទៅសម្បើមណាស់ ។

កៀង= កិ. កៀងគោ - កៀងទា - កៀងមាន់ ...

ឧ. យប់ហើយកូនកៀងមាន់ កៀងទាបញ្ចូលទ្រុងទៅ ។

គាត= ន. ជ្រលក់គាត - បង់គាត ...

ឧ. បងស្រីខ្ញុំចេះបង់គាតធ្វើសំពត់ហូល ។

កៀត=ន. (ប្រដាប់សំកប់ឲ្យក្មេងរៀនដើរ) ធ្វើកៀត-ដើរកៀត

ឧ. ប្អូនខ្ញុំចេះដើរដោយសារឪពុកខ្ញុំគាត់បង់កៀត

ឲ្យរៀនដើរ ។

គាប= កិ. គាបផ្កាគោត - គាបកណ្ដាប់ស្រូវ ...

ឧ. គេគាបកណ្ដាប់ស្រូវ នឹងឃ្នាប ឈើ ហើយបោកលើក្ដារបោក ដើម្បីជំរុះគ្រាប់ ។

កៀប= កិ. កៀបស្លូវចម្លើយ - ឧ ក្រុមព្រះនគរបាលជាតិយក ដង្កៀបដែកមកកៀបស្លូវចំឡើយអ្នកទោសម្នាក់ ។

គុណ= ន. លេខគុណ - ចំណោទលេខគុណ ...

ឧ. ចំណោទនេះមានលេខគុណច្រើនខ្លាំងណាស់ ។

គុណ= គុ. (គេនឡើង) គុណមួយជាពីរ - គុណជាម្ភៃ ...

ឧ. មិនឲ្យខ្ញុំសុំខ្ចីអង្ករ១គោសិន ចាំខ្ញុំសងវិញគុណមួយជាពីរបុះ ។

គុណ= ន. (ព.ផ្ទុ.ទោស) គុណមាតាបិតា ធ្វើគុណ-គុណគ្រូ...

ឧ. មនុស្សផងឡូវធ្វើគុណ ច្រើនតែត្រឡប់បានជាទោសទៅវិញ ។

គុណ= ន. គុណធារ - គុណលំពែង - គុណដំបង ...

១. អ្នកចម្បាំងត្រូវចេះ គុណធារ គុណលំពែង ដើម្បីចូលប្រយុទ្ធផ្ទាល់ខ្លួន ។

គូ= ន. គូព្រេង - គូកន - គនគូ - គូស្រករ ...

១. ស្វាមីភរិយានេះពិតជាគូព្រេងគេពីអតីតជាតិ ។

គួរ= កិ. គួរគំនួរ - គួររូប - គួរអាស ...

១. មុននឹងគួរត្រូវគិតឲ្យហ្មត់ចត់ជាមុនសិន ។

គេ= បុ. គេឯង - គេកលគ្នា - គេធ្វើការ - គេស៊ីគេចុក ...

១. មើលហ្ន៎ ! គេទៅណាច្រើនគ្នាម៉េះ ?

គេហ៍= បុ. (ស្រីមេផ្ទះ) ១. នែគេហ៍នេះ! កូនយើងវានាំគ្នាទៅឯណាអស់ទៅហើយ ?

គោ= ន. សត្វគោ-គោមួយនឹម-គោឡើងក-សត្វគោហ្ម ...

១. ឪពុកខ្ញុំមានគោឡើងកមួយនឹមយ៉ាងល្អ ។

គោរ= ន. (អា.ថ.គោឬគោល) ក្អកគោរជើង...

ឧ. ក្មេងនេះ ហោលជុំអិដ្ឋទៅត្រូវភ្នែកគោ ដើង អ្នកដំណើរឡើងស្រយន់ ពុំអាចដើរទៅមុខទៀតបានឡើយ ។

គោល = ន. ហោះគោល-និយាយថាគោល-គោលដី...

ឧ. ឪពុកខ្ញុំយកឈើគ្រាក់ទៅបោះគោលដី ទុកជាចំណាំតទៅដល់កូនដល់ចៅ ។

គុំ = កិ. គុំគា-គុំគួន បង់គុំនំ...

ឧ. អាម៉ុកគុំរាយអាម៉ែនបំបែកក្បាល ។

គុម្ព = ន. គុម្ពឬស្សី-គុម្ពត្រែង-គុម្ពផ្កា-គុម្ពោតព្រៃ...

ឧ. មើលចុះបេកមួយគុម្ពៗនេះបែកកូនច្រើនណាស់ព្រោះដីមានដីជាតិល្អ ។

គំ = កិ. គំបាយ-បាយគំទឹក...

ឧ. ម៉ែៗ យកទឹកមកគំបាយក្តាំងនេះឲ្យខ្ញុំ ។

គម = ព.ឋ្យ.(អា.ថ.គំ) និគម-សមាគម-គមនាគមន៍...

ម. សម័យនេះនៅគ្រប់ទិសមជឈបទ ប្រជាជនខ្មែរ

រៀនគ្រប់ៗគ្នា ។

គ្រា = ន. គ្រានេះ–គ្រាក្រ–គ្រាមានអាសន្ន–គ្រាឥឡូវនេះ...

ម. មនុស្សយើងយល់គ្នានៅគ្រាមានអាសន្ន ។

គ្រាហ៍ = កិ. គ្រាហ៍គ្នា·គ្រាហ៍យកទៅ គ្រាហ៍អ្នកជម្ងឺ...

ម. គិលានុបដ្ឋាយិកានេះ គ្រាហ៍អ្នកជម្ងឺយកទៅ

បន្ទប់វះកាត់ ។

គ្រាម = ន. ម. មាតុគ្រាម ។

ក្រៀម = គុ. ក្រៀមកំព្រឹសៗ - មុខក្រៀមផ្អេះ ..

ម. អ្នកនេះមុខក្រៀមប្រហែលជាមានកើតជម្ងឺអ្វី

កង្វល់ខ្លួនហើយមើលទៅ ។

គ្រាស = ន. បន្ទគ្រាស-ស្បូវគ្រាស.គ្រាសកន្ទង...

ម. មនុស្សនេះមើលមាំងៗ ដូចជាគ្រាសកន្ទង ។

គ្រៀស = ន. វែងគ្រៀស-គ្រៀសបុស្សី...

ឧ. គេកាប់ឬស្សីមកច្រៀកវែងធ្វើគ្រៀសរុំខ្មោច ។

គ្រោះ = ន. រងគ្រោះ-ចង្រៃគ្រោះ-គ្រោះកាច...

ឧ. ចូរយើងប្រយ័ត្ន គ្រោះថ្នាក់ចរាចរឲ្យមែនទែន ។

ក្រួស = ន. ក្រួសអាចម៍ផ្កាយ-ទ្រាំលេបថ្នាំលេបក្រួស...

ឧ. ខ្ញុំស៊ូទ្រាំអត់ធ្មត់ លេបថ្នាំលេបក្រួសទៅចុះ ។

គ្រុំ-គ្រុម = គុ.ស. សន្ធឹកគ្រុំៗ-ផ្គរលាន់គ្រុំៗ-ឈើរលំគ្រុំ...

ឧ. យប់មិញមេឃមីរងងឹតយ៉ាងខ្លាំង គេឮសន្ធឹកផ្គរលាន់គ្រុំៗ ពាសពេញផ្ទៃអាកាស ។

គ្រំ = ន. សត្វគ្រំ-គ្រំប៉ោក-គ្រំចំពុះទា...

ឧ. ក្មេងៗនាំគ្នាទៅរាវលៀស រាវគ្រំនៅឯបឹង ។

## ឃ

ឃាន = ន. ឃានវិញ្ញាណគឺជាវិញ្ញាណសំរាប់ហិតក្លិន ។

ឧ. មនុស្សយើងមានវិញ្ញាណប្រាំគឺ: កាយវិញ្ញាណ

ចក្ខុវិញ្ញាណ ជិវ្ហាវិញ្ញាណ សោតវិញ្ញាណនិង ឃានវិញ្ញាណ ។

ខៀង= ន. សំពត់ខៀន-ការខៀន...

១. សម័យបុរាណ ស្ត្រីខ្មែរច្រើនស្លៀកសំពត់ខៀនចងក្បិន ។

## ង

ង= គុ. (ព.ជួ.គ្រង់) ទូកង-ងដូចជងកណ្ដៀវ-រំពាត់ងុង

១. ទូកងនេះមានចំណុះប្រហែល ៥០ នាក់ ។

ងរ= កិ. ងក់ងរ-ស្រីងរងក់-ក្មេងងរមិនញុំបាយ...

១. ស្រីនេះមាយាណាស់ ងរចុះងរឡើងធ្វើឲ្យប្រុសៗអន្ទះ ។

ងា= កិ. (យា) ងាដៃ-ងាដំបង-ងាជើង-ងារំពាត់...

១. មាណពនេះងាដៃទះប្រពន្ធគាត់ កុំតែបានគេចាប់ទាន់កុំអី... ។

ងារ= ន. គោរមងារ-ងារជា-ហ្វូងប្រទានងារដល់មន្ត្រី...

ឧ. លោកចៅហ្វាយស្រុកនេះងារជាភក្ដីសង្គ្រាមៗ

ងារ= ន. មួយងារ-ពីរងារ-ក្បាលងារ-កន្ទុយងារ...

ឧ. ព្រឹកនេះបងប្រុសខ្ញុំភ្ជួរស្រែបានតែមួយងារទេៗ

ងុំ= ព.ផ្ស. រងុំៗ - ងុំៗ...

ឧ. ផ្ទះអាកុចយប់មិញនិយាយគ្នាឮសូររងុំៗទាល់ភ្លឺ

ងំ= គុ. បាយងំ-ដំឡូងស្ងោរងំហើយ...

ឧ. ម៉ែ! ម៉ែ! បាយងំហើយឬនៅ? ខ្ញុំឃ្លានណាស់ៗ

## ច

ច= ន. ឧ. ខ្ញុំកើតឆ្នាំច ខែផល្គុន ថ្ងៃអង្គារ ៗ

ចរ= កិ. គោចរ-ចរលីលា-ត្រាច់ចរ-ចរាចរ...

ឧ. មហាឫសី គោចរទៅចង្ក្រមណ៍ភាវនា ៗ

ចក្ក-ចក្រ= ន.(អា.ថ.ពាក់) កង់ចក្រ-ចក្រពត្តិនិយម ព្រះ

រាជាណាចក្រ ទោចក្រយាន-ត្រីចក្រយានយន្ត...

ឧ. រូបសំណាកព្រះឥសូរមានកងចក្រ នៅព្រះហស្តម្ខាងៗទៀតមានព្រះខាន់ ។

ចាក់= កិ. ចាក់ចោល–ចាក់ទឹកកាំបិត–ចាក់ក្រឡេក–ចាក់ទឹកដូង ចាក់ពុម្ពអក្សរ-ចាក់ស្រែ...

ឧ. សិល្បករនេះកំចាក់ត្លុកយ៉ាងក្រមាច់ក្រមើម ។

ចណ្ឌ= គុ. ទឹកចណ្ឌ–ប្រចណ្ឌប្រពន្ធ...

ឧ. យកទឹកចណ្ឌ(សុក)ទៅថ្វាយព្រះរាជាសោយ ។

ច័ន្ទ-ចន្ទ្រ= ន. ព្រះច័ន្ទ–ថ្ងៃច័ន្ទ–ចន្ទ្រគ្រាស...

ឧ. ព្រះចន្ទរះពេញវង់នាថ្ងៃពេញបូរមី ។

ច័ន-ចាន់= ន. ផ្លែច័នទុំ–នំច័ក្កច័ន–ដើមចាន់...

ឧ. មីងក្លួងគាត់លក់នំច័ក្កច័ន ផ្លែអាយព្រាបបាយ ។

ចន្ទន៍= ន. ឈើខ្លឹមចន្ទន៍–ដុតខ្លឹមចន្ទន៍...

ឧ. គេយកឈើខ្លឹមចន្ទន៍ មកដុតថ្វាយស្តេច ។

បារ= កិ. បារបង់-បារស្ទឹកតែ បារអណ្តើក...

១. អ្នកឯងទៅកាប់កូនឈើយកមកបារដើរ ស្ទឹក

ត្រែ ការពារកុំឲ្យមានទាកកាយ ។

បារ= ន. ដើមបារ-ផ្កាបារ-លាបពណ៌ផ្កាបារ...

១. ទូកនេះលាបពណ៌ផ្កាបារ ។

ប៉ារុ= ន. (ខ្សែមាស) ពាក់ប៉ារុ-ខ្សែប៉ារុ...

១. នៅថ្ងៃចូលឆ្នាំស្រីៗ ពាក់ប៉ារុលេងឈូង-លេង

អង្គុញទាញព្រ័ត្រយ៉ាងសប្បាយ ។

បិត= កិ. បិតបន្ទៃ-បិតត្រសក់ (បិតសិប=ប.សំ.) ...

១. ម៉ែខ្ញុំបិតបន្ទៃច្រើនមុខស្ទូសម្ទូកកូរ ។

បិត្ត-បិត្រ= ន. បិត្តល្អ-បិត្តអាក្រក់-ល្អវិចិត្រ-វិចិត្រករ...

១. កុមារនេះបូលបិត្តកំទិងប្រៀនជាងរៀនសូត្រ ។

បូរ= កិ.នុ. បូរបា-បូរសិស្ស-បូរអ្នក-បូរនាន...

១. បូរសិស្សឯទៀតយកតម្រាប់តាមក្មេងល្អនេះ ។

ចូរ= កិ. (ចូកឲ្យខូង) ចូរដី-ចូរជាចន្លូរ ...

១. ឯងយកបបដីមកចូរដីត្រង់នេះធ្វើផ្លូវទឹកហូរ ។

ចូល= កិ. ចូលរៀន-ចូលធ្វើការ-ចូលផ្ទះ-ចូលទ្រុង ...

១. ពេលព្រឹកខ្ញុំចូលរៀនម៉ោង ៧ កន្លះ ល្ងាចចូលរៀនម៉ោង ១៤ កន្លះ ។ ទីនេះហាមមិនឲ្យចូល ។

ចៀរ= កិ. ចៀរដើមសក់ - ចៀរស្លឹកចេក - ចៀរក្រដាស ...

១. សិស្សនាំគ្នាចៀរក្រដាសពណ៌ធ្វើការហត្ថកម្ម

ជា= ន. (ពស់ជា) ១. ពាក្យចាស់ដំណាលតៗមកថា បើបងប្អូនប្ដីប្រពន្ធ ទាំងពីរនាក់ឃើញពស់ជា មុខជាព្រាត់ប្រាសគ្នាជាមិនខានឡើយ ។

ជា= គុ.(ព.ផ្ទុ.ឈឺ) ជាសះស្បើយ-ជាជម្ងឺ-ដំបៅជាហើយ ...

១. ម្ដេចទៅជម្ងឺឯង បាជាស្រួលបួលហើយឬ ?

ជា= និ. ខ្ញុំជា ... ឯងជា ... វាជាអ្នកនេសាទត្រី ។

១. អ្នកនេះជាមនុស្សល្អជាឬទេ ?

ចៀម= ន. សត្វចៀម – ទឹកដោះចៀម – រោមចៀម ...

ឧ. គេចិញ្ចឹមសត្វចៀមយកសាច់ និងរោមវា ។

ជាម= ន. (ចានជាម) សុំចាំងជាម ៗ ...

ឧ. ដួសបាយមួយចានជាមមកឲ្យម៉ែកូន !

ចៀស-ជៀស= កិ. ជៀសវាង-ជៀសចេញ-ជៀសឲ្យឆ្ងាយ ...

ឧ. ចូរអ្នកពល់គ្នាជៀសវាងនូវអំពើទុច្ចរិតគ្រប់បែបយ៉ាង ៗ

ជាស= ន. (ដូចបន្ទុយ) សត្វជាស – ដីកជាស – រន្ធជាស ...

ឧ. សត្វជាសច្រើននៅព្រៃភ្នំ ។

ចោត= គុ. ជណ្ដើរចោត – ច្រាំងចោត – ភ្នំចោត ...

ឧ. ច្រាំងទន្លេនេះចោតណាស់ដើរប្រយ័ត្នរអិលធ្លាក់

ចោទ= កិ. ចោទសួរ – ចោទឆ្លើយ – ចោទបញ្ហា ...

ឧ. លោកពិនិត្យមើលបញ្ហានេះគេចោទយ៉ាងណាខ្លះ

ចំណោត= ន. (ដែលចោត) ចំណោតភ្នំ – ចំណោតច្រាំង ...

ឧ. ត្រង់ចំណោតភ្នំនេះមានរុក្ខជាតិដុះច្រូងច្រាំង ។

ចំណោទ = ន. (ប្រស្នា) រកចំណោទ–ដោះចំណោទ ...

ឧ. សិស្សរៀនធ្វើចំណោទលេខចែកនិងលេខគុណ

ប្រស = ឧ.ស. ព្រួសប្រស ៗ · ទង្គិចគ្នាព្រួសប្រស ៗ ..

ឧ. អ្នកចម្បាំងកាប់គ្នានឹងដាវព្រួសប្រស ៗ ។

ប្រោះ = កិ. ប្រោះម្សៅ–ទឹកហូរប្រោះ–ប្រោះទឹកត្រី ...

ឧ. ទឹកទន្លេហូរប្រោះបាក់ច្រាំងបន្តិចម្តង ៗ ។

ប្រាស = ន. ប្រាសដុសធ្មេញ–ប្រាសដុសសេះ ...

ឧ. ពល់ព្រឹកខ្ញុំដុសធ្មេញនឹងប្រាសដាក់សាប៊ូបន្តិចផង ។

ប្រាស = កិ. មាន់ប្រាស–ពស់ប្រាស ...

ឧ. មេមាន់កាល់កូនវា  កុំចូលទៅជិតប្រយ័ត្នវា
ប្រាសខ្ទាក់ភ្នែក ។

ជ្រិះ = កិ. ជ្រះក្អែល–ជ្រះស្រឡះ–លាងឲ្យជ្រះ ...

ឧ. មុននឹងបរិភោគអាហារត្រូវលាងដៃឲ្យជ្រះធូលីសិន

ប្រៀង=កិ. ប្រៀងពីរោះ–ប្រៀងកំសាន្ត–ប្រៀងគ្នា ...

១. ក្នុងចំណោមអ្នកចម្រៀងទាំងអស់ មានតែនាង
នេះទេដែលប្រៀងពីរោះជាងគេ ។

ជ្រៀង=គុ. (ទ្រេត) អក្សរជ្រៀង...

១. សិស្សនេះសរសេរអក្សរជ្រៀងស្ទើតួល្អណាស់

ប្រៀប=គុ. (ព.ផ្ទ.អ៊ូអៃ) ស្ងាត់ប្រៀប–ស្ងប់ប្រៀប...

១. កាលយប់ពុំដែលស្ងាត់ទេ ចុះហេតុអ្វីយប់នេះក៏
ស្ងាត់ប្រៀបគ្មានឮសូរមាត់ សូរកសោះ ។

ជ្រាប កិ. ទឹកជ្រាប–សូមទ្រង់ជ្រាប–សូមទានជ្រាប...

១. ពាងជ្រាបទឹកលេចសើមជោកដី ។

ប្រៀក=កិ. ប្រៀកជាបន្ទុះ–ប្រៀកឫស្សី–ប្រៀកជៀត ...

១. មាខ្ញុំប្រៀកឫស្សីជាបន្ទុះតូចៗវែងធ្វើព្រួលពំងត្រី

ជ្រាក=គុ. (ព.ផ្ទ.ហាប់ប្អូម៉ង)–ជ្រាកៗ–សាច់សំពត់ជ្រាក ។

១. សាច់សំពត់មុយអានេះជ្រាកៗមិនសូវល្អទេ ។

# ឆ

ឆន្ទ=ន. (អា.ថ.ឆាន់) ឧ. តាមឆន្ទៈរបស់ប្រជារាស្ត្រទៅចុះ

បើរាស្ត្រយល់ព្រមផង ៗ

ឆាន់=កិ. ឆាន់ចង្ហាន់–ឆាន់ត្រង់–លោកឆាន់បាយ…

ឧ. យើងគិតធ្វើបុណ្យនិមន្តលោកឆាន់ម្ដងឬ ?

ឆ្ការ= កិ. (ត្រួសត្រាយ-កាប់) ឆ្ការព្រៃ–ឆ្ការគុម្ពឫស្សី…

ឧ. កសិករនាំគ្នាឆ្ការព្រៃនាមយកដីដាំដំណាំផ្សេងៗ

ស្ការ=ន. សត្វស្ការ–ស្ការចាប់មាន់…

ឧ. ស្ការជាសត្វចង្រៃ វាចាប់មាន់ទាស៊ីជាអាហារ ៗ

បាស្កា-បាសកា=ន. (ឈើគ្រង្គ)·លេងបាស្កា·ចាញ់បាស្កា.

ឧ. ព្រះបាទព្រហ្មទត្តទ្រង់ក្រសាលបាស្កាជាមួយ

ស្ដេចគ្រុឌ ៗ

ឆ្នៀង= ន.(របៀងផ្ទះ)–ឆ្នៀងជុំវិញ–ឆ្នៀងផ្ទះ...

១. ផ្ទះខ្ញុំមានឆ្នៀងជុំវិញសំរាប់ដើរ ។

ឆ្នាង=ន.(ប្រដាប់នេសាទ) ឆ្នាងត្រាំ–ឆ្នាងអញ្ចាត់ត្រី...

១. កាលណាអត់ម្ហូប បងស្រីខ្ញុំយកឆ្នាងទៅ អញ្ចាត់ត្រីក្នុងបឹង ។

ឆ្មា= ន. សត្វឆ្មា–ឆ្មាបា–ឆ្មាមេាង–ឆ្មាចាប់កណ្តុរ...

១. ឆ្មាមិននៅកណ្តុរឡើងរាជ្យ ។ ឆ្មាចាប់កណ្តុរ ជាសត្វចង្រៃដែលជាមេចម្លងជម្ងឺពិសមកមនុស្ស ។

ឆ្មារ= គុ. (អា.ថ.ឆ្មាល់) សំឡេងឆ្មារ–អំបោះឆ្មារ–ក្រួបឆ្មារ

១. ម្តាយខ្ញុំទិញក្រួបឆ្មារយកមកជ្រក់មាន់ស្ងោរ ។

ឆ្វេង= ន. ដៃឆ្វេង–ជើងឆ្វេង–ខាងឆ្វេង...

១. កាលណាខ្ញុំឈរបែរមុខទៅទិសបូព៌ា នៅខាងក្រោយខ្នងខ្ញុំគឺទិសបស្ចិម នៅខាងឆ្វេងដៃខ្ញុំគឺទិសឧត្តរ ហើយនៅខាងស្តាំដៃគឺទិសទក្សិណ ។

ឈ្វេង = កិ. ឈ្វេងយល់ - ទ្រង់ឈ្វេងយល់...

១. ព្រះអង្គទ្រង់ឈ្វេងយល់សព្វគ្រប់ទៅឃើញថា

ឈ្វេង = គុ. ទឹកថ្វាឈ្វេង - ក្លិនក្រអូបឈ្វេង...

១. បុប្ផានេះមានគន្ធពិដោរក្រអូបឈ្វេង ៗ

## ជ

ជរ = ន. ចាក់ជរ - ដេរជរ - ជរជើងសំពត់...

១. សម័យឥឡូវស្រីៗច្រើនស្លៀកសំពត់មានជរជើងៗ

ជ័រ = ន. ជ័រលុប - ជ័រទឹក - ជ័រចុង...

១. ឪពុកខ្ញុំទិញជ័រទឹកមកតាក់ទូកកុំឲ្យជ្រាបទឹក ៗ

ជង់ = ន. ជង់ដាក់កុក - ជង់លលក - កុកជាប់ជង់ - (ជង់ត្រី-ជង់ឈើស្រួច=កិ.)

១. មានពាក្យស្លោកថា "កុកហើរលើមេឃលែងអីជាប់ជង់" ៗ

ជង្ឃ= ន. (អា.ជ.ជង់) (ស្មង់ជើង) (ស្លាប់ព្រះជង្ឃ = ស្រោមជើង)...

១.គិលៀនយកស្លាប់ព្រះជង្ឃមកពាក់ថ្វាយស្តេចៗ

ជប់= គុ. (គ្រេប.ស្រុញ.) បន្ទះឫស្សីជប់-ឈើនេះជប់...

១. ឫសពីសពន់នេះវៀវស្តួចល្អណាស់ ពាសតែមានជប់ត្រង់នេះបន្តិចកុំអីយកទៅធ្វើដងសន្ទូចបាន

ជុប= ន. (ប្រដាប់នេសាទត្រី) ដាក់ជុប-ត្រីជាប់ជុប...

១. ឮគេថាត្រីជាប់ជុបយកមកធ្វើម្ហូបមិនសូវមានរសជាតិទេ ៗ

ជន= ន. (អា.ជ.ជន់) ជនានុជន-ប្រជាជន-ជនបទ-ជនណា

១. ប្រជាជនខ្មែរយើង ចូលចិត្តធ្វើស្រែជាងរកស៊ីធ្វើជំនួញ ៗ

ជន្ម= ន. (អា.ជ.ជន់) (អាយុ) ជន្មវស្សា-ព្រះជន្ម-ជន្មាយុ

១.សូមឲ្យព្រះអង្គមានព្រះជន្មយឺនយូរកប់រយឆ្នាំៗ

ជន់= កិ. ជោរជន់-ទឹកជន់-ជន់ហូរហៀរ...

ឧ. ក្នុងឆ្នាំនេះ ទឹកជន់ឡើងលិចស្រែចម្ការច្បារដំ-ណាំអស់ ។

ជុន= ន. (ចិន) ស្រាមួយជុន-ទឹកត្រីមួយជុន...

ឧ. ស្រាមួយជុននេះមានចំណុះ ៣៥ លីត្រ ។

ជល់= កិ. (ទង្គិច) ជល់មាន់-ជល់ត្រីក្រឹម-គោជល់គ្នា ...

ឧ. យើងត្រូវជៀសវាងកុំលេងល្បែងជល់មាន់ជល់ត្រីក្រឹមដែលជាល្បែងមានទោស ។

ជលចរ=ន.(អា.ថ.ជល់ចរ) (ដំណើរតាមទឹក) ជលយាន-ជលមគ្គ ជលនេត្រ-ជលធារ-ជលយន្ត ...

ឧ. ជលមគ្គនៃប្រទេសកម្ពុជាមានទន្លេចតុមុខជាប្រធាន ។

ជុល= កិ. (ប៉ះ) ជុលសំពត់-ជុលកន្ទេល-ជួសជុល...

ឧ. ដើម្បីឲ្យផ្លូវថ្នល់ជាប់បានយូរត្រូវឲ្យស្ហាប់ជួស

ផុលនៅកន្ទួងណាដែលវារបើកក្រហេងក្រហូងៗ

ជា = ន. (ពស់ជា) ១. ពស់ជាវាមិនចឹកដូចពស់ឯទៀតទេ

វាច្រើនតែប្រាសទឹកស្រកី ៗ

ជា = និ. ខ្ញុំជាសិស្សសាលា – ឯងជាអ្នកកសិករ – ពូម៉ែតជា

១. ខ្លួនខ្ញុំជាអ្នកស្រុកអ្នកភូមិនៅទីនេះដែរ ៗ

ជា = គុ. (ព.ផ្ទុ.ឈឺ) សុខជាឬទេ? ជាហើយឬ? សុខ

សប្បាយជាទេ ៗ

១. ក្មួយខ្ញុំដែលឈឺនោះឥឡូវវាជាស្រួលបួលហើយ

ចៀរ = កិ. ចៀរកំណាត់សំពត់–ចៀរសក់–ចៀរស្មុក ...

១. ជាងកាត់សក់នេះ គ្រាន់តែចៀរកោរជើងសក់

បន្តិចយកថ្លៃដល់ ១០រ ៗ

ជាម = ន. ចានជាម–មួយជាមពីរជាម...

១. ពូខ្ញុំឃ្លានបាយ គាត់អាស្រ័យអស់ពីរចានជាមៗ

ចៀម = ន. សត្វចៀម–រោមចៀម...

ឧ. នៅប្រទេសត្រជាក់ គេចិញ្ចឹមសត្វចៀមដើម្បី
យករោមវាធ្វើសំលៀកបំពាក់ ។

ជាស=ន. (ដូចបន្ទុយ) រន្ធជាស-ជីកជាស...
ឧ. គេនាំគ្នាទៅជីកជាសយកមកធ្វើម្ហូបអាស្រ័យ ។

ជៀស-បៀស=កិ. ចៀសចេញ-ចៀសវាង-ចៀសឲ្យឆ្ងាយ...
ឧ. សូមឲ្យសត្រូវបរាសចៀសឲ្យឆ្ងាយពីព្រះអង្គ ។

ជាវ= កិ. ជាវស្បង់ចីពរ-ជាវព្រះត្រៃបិដក-ជាវព្រះពុទ្ធរូប.
ឧ. ឧបាសក ឧបាសិកាទាំងនេះបានបរិច្ចាគបច្ច័យ
ជាវព្រះពុទ្ធរូបមួយព្រះអង្គយកទៅដាក់វត្ត ។

ជៀវ=គុ. និយាយគ្នាឲ្យជៀវ-លេងជៀវ...(សត្វប្រជៀវ=ន)
ឧ. ក្មេងៗនិយាយគ្នាឲ្យជៀវ រកតែចាស់ទុំស្ដាប់លោក
ទេសន៍ពុំបាន ។

ជី= បុ.ស. (បណ្ឌិតឬអន្ទិត) ជីក្រង-ស្រុកជីហែ-ពាមជីកង...
ឧ. ជីប៉ុលសឹកពីសាមណេរពីកាលណាហ្នឹង ?

ជី= ន. ដីអាចម៍គោ–ដីអាចម៍ប្រចៀវ–ដាក់ជី ...

ឧ. ដើម្បីឲ្យផលដំណាំដុះបានល្អ ត្រូវឧស្សាហ៍ដាក់ជីអាចម៍គោ ជីអាចម៍ជ្រូក ជីអាចម៍ប្រចៀវជាដើម ។

ជីរ= ន. (គ្រឿងកាត់បំពាប) ជីរនាងវង–ជីរក្រសាំងទំហំ...

ឧ. បងស្រីខ្ញុំទៅផ្សារទិញក្រូចឆ្មារមានជីរគ្រប់មុខយកមកញាំភ្លាត្រីក្អក ។

ជួ= គុ. (ធ្វើងការខ្ទើង) មនុស្សជួរ–មនុស្សជួជាតិ ...

ឧ. កូនលោកពូបានធ្វើទាមុនជួណាស់ ខ្ញុំហៅពីរបីមាត់ពុំស្ដីគេខ្ញុំឡើយ ។

ជួរ= ន. មួយជួរ–តម្រង់ជួរ–តម្រៀបជួរ–ឈរជាជួរ ...

ឧ. ផ្ទះនៅក្នុងភូមិខ្ញុំ គេសង់រៀបរៀងជាជួរ ល្អមើលណាស់ដោយសារមន្ត្រីឃុំចេះរៀបចំ ។

ជួស= កិ. (ដាក់ជំនួស) ជួសកន្ទេល–ជួសរនាប–ជួសជុល...

ឧ. ម្ដាយខ្ញុំកាត់ស្លឹកត្នោតយកមកជួសកន្ទេលដែលរហែក

ជោះ= កិ. ជោះអង្គុញ, ជោះបន្ទា, ជោះពងមាន់ ...

ឧ. យាយខ្ញុំជោះបន្ទាដែលមុតជើងគាត់ ។

ជោក= កិ. ទទឹកជោក, សើមជោក, ស្រវឹងជោក, ជោកជាំ...

ឧ. អ្នកប្រមឹកនេះ ស្រវឹងជោកដើរទោរទៅខាង ឆ្វេងទោរទៅខាងស្តាំ បីដូចជាគ្មានវិញ្ញាណសោះ ។

ជោគ= ន. ថ្ងៃមានជោគ, មានជោគជ័យ, ជោគវាសនា ...

ឧ. ថ្ងៃនេះជាថ្ងៃមានជ័យជោគគួរតែយើងចេញដំណើរ

ជំនុំ= កិ. ជំនុំជំរះ, ជំនុំការ, (កណ្តាលជំនុំ=ន.)

ឧ. ចាងហ្វាងសាលាដំបូងកំពុងតែជំនុំជំរះក្តី ។

ជំនំ= គុ. អាវជំនំ, ខោជំនំ, របស់ជំនំ, សំពត់ជំនំ ...

ឧ. នែម៉ែក! សារុងឯងវាជំនំទៅហើយដាក់ពាន ឲ្យស្ងួមយាយបក់ទៅ ។

ជ្រិង់= កិ. ជ្រង់តាំ, ឈរជ្រង់ ...

ឧ. ឯងនៅឈរជ្រង់តែមួយកន្លែងហ្នឹងហើយ ។

ជ្រុង= ន. ជ្រុងស្រែ, ជ្រុងតុ, ជ្រុងសសរ, កង់បួនជ្រុង ...

ឧ. អាវិលនេះដួលត្រូវនឹងជ្រុងតុបែកក្បាលហូរឈាម

ជ្រួយ= កិ. (ធ្វើឲ្យរបើកឡើង) ជ្រួយបាយ, ជ្រួយដីឲ្យធូ ...

ឧ. កសិករ និង កសិការនាំគ្នាជ្រួយដីឲ្យធូ ដើម្បីឲ្យដំណាំដុះបានល្អ ។

ជ្រោយ= ន. (ដីដុះលយ) ជ្រោយចង្វា, ជ្រោយដង ...

ឧ. មានពាក្យស្លោកថា «ហុតទឹកសំឡសម្ងឹងកាក ពាញប្រាក់ក្រោកសម្ងំជ្រោយ ។

ជ្រួស= កិ. (ឃ្លាងគ្នា) ជ្រួសផ្លូវ, ជ្រុលជ្រួស, ជ្រួសគ្នា ...

ឧ. សូមលោកមេត្តាអភ័យទោស ធ្វើម្ដេចបើខ្ញុំជ្រុលជ្រួសសំដីបន្តិចទៅហើយ ។

ជ្រោះ= ន. ជ្រោះភ្នំ, ទឹកជ្រោះ, ប្រយ័ត្នធ្លាក់ជ្រោះ ...

ឧ. ទឹកនេះថាឈ្មោះហូរធ្លាក់ពីជ្រោះភ្នំឯណោះមក

ជ្រោក= គុ. (ព.ថ្ម.ម៉ង្ឈ) សាច់ជ្រោក, ជ្រោក ១ ...

ឧ. សំពត់នេះសាច់ជ្រាកៗ មិនសូវល្អទេ ។

ច្រៀក = កិ. ច្រៀកឬស្សី, ច្រៀករពាក់, ច្រៀកឆៀត...

ឧ. ពូខ្ញុំច្រៀកផ្ដៅធ្វើតុ កៅអីយ៉ាងល្អៗ ទុកលក់ ។

ជ្រាប = កិ. ជ្រាបសព្វសាច់, ក្អមជ្រាបទឹក, ឲ្យបានជ្រាប...

ឧ. សូមជំរាបមកលោកឪពុក អ្នកម្ដាយសូមជ្រាបៗ

ជ្រៀប = គុ. ស្ងាត់ជ្រៀប, ស្ងប់ជ្រៀប...

ឧ. ក្នុងព្រៃនេះស្ងាត់ជ្រៀប គេគ្មានឮសូរអ្វីសោះៗ

ជ្រៀង = គុ. (ទេរ, ទ្រេត) អក្សរជ្រៀង...

ឧ. ខ្ញុំសរសេរអក្សរជ្រៀងល្អជាងអក្សរមូល ។

ច្រៀង = កិ. ច្រៀងមួយបទ, ច្រៀងអាយ៉ៃ...

ឧ. ក្មេងៗឥឡូវចូលចិត្តច្រៀងបទសម័យណាស់ៗ

# ឈ

ឈ្ងៀម = គុ. ឈ្ងៀមកៅស៊ូ, ឈ្ងៀមបាយខ្ទោច...

១. អ្នកណាដុតអ្វីធុំក្លិនឈ្ងៀមម្ល៉េះ ?

ស្ងៀម=កិ. ស្ងាត់ស្ងៀម-ស្ងៀមឈឹង-ស្ងៀមស្ងួន...

១. ក្មេងៗនៅឲ្យស្ងៀមស្តាប់ចាស់ៗជំនុំការ ។

ឈ្នាង=ន. (ប្រដាប់នេសាទត្រី)- ឈ្នាងត្រាំ-កណ្តាប់ឈ្នាង-

មុខឈ្នាង, គូថឈ្នាង...

១. បងខ្ញុំអញ្ជាក់ម្តងៗបានត្រីកន្ទុះគូថឈ្នាង ។

ឈ្នៀង-ផ្នៀង=ន. (ល្បៀងផ្ទះ) ផ្នៀងផ្ទះ...

១. ផ្ទះសម័យ គេច្រើនធ្វើផ្នៀងជុំវិញសំរាប់ដើរ ។

ឈ្វេង=កិ. ឈ្វេងយល់, ទ្រង់ឈ្វេងយល់...

១. ព្រះអង្គទ្រង់ឈ្វេងយល់យ៉ាងណាក្នុងរឿងនេះ

ឈ្វេង=គុ. ទឹកថ្លាឈ្វេង, ក្លិនក្រអូបឈ្វេង...

១. ផ្កាកូឡាបមានក្លិនក្រអូបឈ្វេង ។

ឆ្វេង= ន. ជើងឆ្វេង, ប្រើដៃឆ្វេង, ឆ្វេងតែឯង...

១. ដៃស្តាំធ្វើការច្រើនជាងដៃឆ្វេង ។

ឈ្លាស= គុ. (ប៉ិន, ស្ទាត់) ឈ្លាសវៃ, ប្រាជ្ញាឈ្លាសវៃ...

ឧ. សិស្សនេះមានបញ្ញាឈ្លាសវៃគ្រប់មុខវិជ្ជា ។

ឈ្លៀស= កិ. (កេណ្ឌ) ឈ្លៀសមនុស្ស, ឈ្លៀសសត្វគោក្របី

ឧ. រាជការឈ្លៀសរទេះគោ ក្របីយកទៅដឹកដី ។

# ញ

ញ= ន. ដើមញ, ផ្លែញ...

ឧ. ដើមញគេដាំសំរាប់យកស្លឹកធ្វើអាម៉ុកឬផ្សំថ្នាំកែពេគ ។

ញ័រ= កិ. ញាប់ញ័រ, ញ័រទទ្រើក, ញ័ររំប្រប់...

ឧ. ក្មេងៗងូតទឹកត្រជៀករងាញ័រមាត់រណ្តំធ្មេញ ។

ញាណ= ន. ដឹងញាណ, ទ្រង់ញាណ, វិញ្ញាណ...

ឧ. ព្រះអង្គទ្រង់ញាណ ។

ញៀន= កិ. ញៀនល្បែង, ញៀនអាភៀន...

ឧ. មានពាក្យស្លោកថា "ញៀនស្រី-ញៀនស្រា-

កញ្ចាកកៀន... ។

ញោស=គុ. (ជ្រុល) ញោសពេក, ទុំញោស...

ឧ. ផ្លែស្វាយនេះទុំញោសពេកណាស់ទៅហើយ។

ញោះ=កិ. (វាយតិចៗ) ញោះមួយក្រញាំ, ញោះមួយដំបង

ញោះមួយម៉ាត់មួយក...

ឧ. ខ្ញុំញោះមួយម៉ាត់មួយកទៅវិញដែរ បើវាដូច

ជាញោសពេក ។

# ដ

ដិ= ន. កំពង់ដ, ច្នង់ដ, ខ្ទកដ...

ឧ. ខ្ទកដនេះច្នង់ទៅច្នង់មកឃើតណាស់ ។

ដ៏= និ. ដ៏ប្រសើរ, ដ៏ប្រពៃ, ដ៏មានបុណ្យ, ដ៏ក្រៃលែង...

ឧ. លោកដ៏មានគុណទាំងពីរ សូមលោកទាំងទេ្វ-

ហានៅឲ្យបានប្រកបដោយសេចក្ដីបរមសុខចុះ ។

ជរ= គុ. ជរដំបៅ,ជរបូស,ជរជម្ងឺ...(ត្រជរ,កំជរ=កិ.)

១. ឯងត្រជរដើរទៅណាប្រយ័ត្នជរបូសឡើងវិញៗ

ជា= ន. ថ្មជា, ផ្ទាំងថ្មជា...

១. នៅលើកំពូលផ្ទាំងថ្មជាធំបគ្រឹងៗ នៅរកេតរកូត ៗ

ជារ= ន. ជារខ្មោច,បុណ្យជារ ..

១. ថ្ងៃនេះគ្រួសារខ្ញុំធ្វើបុណ្យជារយ៉ាងអធឹកអធមៗ

ជាស់= កិ. ជាស់ឲ្យភ្ញាក់, ជាស់តឿន...

១. យើងត្រូវទម្លាប់ជាស់កូនឲ្យភ្ញាក់ពីព្រលឹមរាល់ៗព្រឹកៗ

ជាស= កិ. ជាសស្គរ, ជាសទ្រ, ជេរជាស...

១. គេយកស្បែកគោឬស្បែកពស់ថ្លាន់ មកជាស ធ្វើស្គរ ធ្វើតាប៉ុ ឬទ្រជាដើម ៗ

ជុស= កិ. ជុសសាប៊ូ, ជុសក្អែល, ជុសធ្មេញ...

១. ចូរយើង១សប្តាហ៍ងូតទឹក ជុសសាប៊ូក្នុងមួយ អាទិត្យយ៉ាងតិចណាស់ពីរដងដែរ ៗ

ដុះ= ក. ដីដុះ, គ្រាប់ស្វាយគ្រាប់ស្ពៃដុះ, ដំណាំដាំដុះ...

១.រុក្ខជាតិដុះដង្ហែគ្នា រៀងរៀបជាជួរល្អមើលណាស់ៗ

ដែក= ន. ដែកគោល, ដែកលួស, ដែកថែប ...

១. ធុងនេះធ្វើអំពីដែកសង្កសីលាបពណ៌លឿង យ៉ាងល្អស្រស់ ។

តេជះ=ន.(សា.ប.តេជ:)តេជដៃ,ព្រះតេជគុណ,តេជានុភាព

១.ព្រះតេជគុណទៅអធិការនិមន្តទៅឯណាហើយ?

# ត

តុ= ន. (សា.ប.តុក) តុកៅអី, តុឈើ, តុដែក...

១. សិស្សត្រូវសំអាតតុនិងជើងម៉ាដែលអង្គុយរៀន ឲ្យស្អាតជានិច្ច ព្រោះជាទម្លាប់មួយយ៉ាងប្រពៃ ។

តុកកែ-តុំកកែ= ន. សត្វតុកកែ, តុកកែយំ, ពស់តុកកែ ...

១. សត្វតុកកែជាសត្វមានប្រយោជន៍ដែរ ព្រោះ

កាស៊ីសត្វល្អិតដូចជាមូសរុយជាដើម ។

តួ= ន. តួឯកល្ខោន, តួខ្លួន, តួផ្ទះ, តតួ...

ឧ. តួផ្ទះនេះមានទំហំធំគ្រាន់បើដែរ ។

ទួ-ទូ= កិ. ទូទៅ, មនុស្សទួទៅ, វិជ្ជាទួទៅ...

ឧ. មនុស្សទួទៅច្រើនតែមានសេចក្ដីលោភគ្រប់ៗគ្នា

តៀប= ន. (ដូចគោក) ឧ. ដាក់បាយទឹងតៀបបរិភោគ ។

ទៀប= ន. ដើមទៀប, ផ្លែទៀប, ទៀបលខ័, ទៀបបារាំង ...

ឧ. ដើមទៀបមួយដើមនេះមានផ្លែស្អកស្កះ ។

ទៀប= គា.និ. ទៀបទឹង, ទៀបភ្លឺ, ថ្ងៃទៀបអស្តង្គត

ឧ. យប់មិញទៀបភ្លឺមានភ្លៀងធ្លាក់មួយមេយ៉ាងធំ

ទាប= គុ. (ព.ផ្ទ.ខ្ពស់). ទាបទ្រនាប់, ទាបថោក ...

ឧ. ចូរយើងកុំប្រព្រឹត្តនូវអំពើទាបថោកឲ្យសោះ ។

តេជះ=ន.(អា.ថ.ដៃកដ:) ព្រះតេជគុណ, តេជគុណ, តេជដៃ

ឧ. ព្រះតេជគុណនិមន្តមកនេះមានការអីបាន ?

ដែក= ន. ដែកស៊ីវីឡាត, ដែកស្និត, ដែកលួស ...

ឧ. មាស៊ីនរុញដីនេះធ្វើអំពីដែកទាំងដុលៗ ។

តុម្ព= ន. តុម្ពកំពោរ ឬ អកកំពោរ

ឧ. ម្ដាយខ្ញុំយកប្រាក់ណែនទៅជួលជាងឲ្យធ្វើតុម្ពកំពោរ

តុំ= ប. គិមតុំ ...

ឧ. អ្នកនេះគិមតុំៗ រកកន្លែងអង្គុយ ។

ត្បិត= ប. រឹតត្បិត, ត្បិតត្បៀត ...

ឧ. ត្រូវយើងចេះត្បិតត្បៀតកុំចាយវាយឥតប្រយោជន៍

ដ្បិត= និ. ដ្បិតខ្ញុំ, ដ្បិតអ្នក, ដ្បិតតែ ...

ឧ. ខ្ញុំយករបស់ទាំងនេះមកជូនលោក ដ្បិតលោក

មានគុណបំណាច់លើរូបខ្ញុំ ព្រមទាំងគ្រួសារខ្ញុំ ។

គ្រប់= ន. គ្រប់វែង, គ្រប់ខ្វរ, គ្រប់ចានទាប ...

ឧ. ដើមគ្រប់មួយដើមដុះនៅកៀនរបងផ្ទះខ្ញុំ ។

ទ្រាប់= កិ. ទ្រាប់ក្រដាស, ទ្រាប់ក្រមា, ទ្រាប់ដៃ...

ឧ. មុននឹងអង្គុយត្រូវយកក្រដាសឬកូនកន្សែងក្រាប់ពីក្រោមសិន ។

ទ្រព្យ=ន. ទ្រព្យរបស់, ទ្រព្យសម្បត្តិ, ទ្រព្យា...

ឧ. មហាសេដ្ឋីនេះមានទ្រព្យសម្បត្តិច្រើនឥតគណនា

គ្រៀប=កិ.វិ. គ្រៀបគ្រា, ច្រើនគ្រៀបគ្រា...

ឧ. ក្នុងពិធីបុណ្យនេះមានមនុស្សមកកំសាន្តច្រើនគ្រៀបគ្រា

ទ្រាប= កិ. (សង្កត់ពីលើ), ដើរទ្រាបព្រៃ, កុំទ្រាបពីលើខ្ញុំ...

ឧ. កុំដើរទ្រាបព្រៃប្រយ័ត្នសត្វកាច ។

ទ្រាប =ន. ទំទ្រាបបាយ, កូរទ្រាបបាយ ...

ឧ. ទំទ្រាបបាយនេះកូរមិនទាន់ដាច់ទឹកទេ ។

គ្រៀល= ន. ផ្លែគ្រៀល, ដើមគ្រៀលដោះក្របី...

ឧ. ដើមគ្រៀលច្រើនដុះនៅតាមភ្លឺស្រែ ។

ទ្រាល=កិ.(ដេកពោប)ទ្រាលលើក្តារ,ដេកទ្រាល ពោបទ្រាល

ឧ. ខ្ញុំទ្រាលលើក្តារនៀនេះគេដាក់ស្រួលណាស់។

ត្អួ = ន. ដើមត្អួ, ខ្សត្អួ, កាប់ដើមត្អួ ...

ឧ. អ្នកស្រុកនាំគ្នាទៅកាប់ដើមត្អួយកមកធ្វើអុសដុត

ត្អួរ = គុ. មុខត្អួរ, ធ្វើមុខត្អួរ ...

ឧ. ប្អូនឯងកុំធ្វើមុខត្អួរដាក់កៀរយ៉ាងនេះ ៗ

# ល

ថ្លុក = ន. ថ្លុកជ្រាំ, ថ្លុកកំពត, ថ្លុកទឹកសំអុយ ...

ឧ. យើងត្រូវលុបថ្លុកទឹកសំអុយកុំឲ្យកើតមូស ៗ

ត្លុក = ន. តួត្លុក, ត្លុកកំប្លែង, ចាក់ត្លុក ...

ឧ. សិល្បករនេះចាក់ត្លុកយ៉ាងក្រមាប់ក្រមើម ធ្វើឲ្យ

ទស្សនិកជនសើចសប្បាយយ៉ាងរីករាយ ៗ

ផ្លាស់ = កិ. ផ្លាស់ការផ្លាស់ងារ, ផ្លាស់ទឹកមុខ, ផ្លាស់សរសៃ ...

ឧ. ខ្ញុំគ្រាន់តែនិយាយលេងបន្តិច ស្រាប់តែផ្លាស់ទឹកមុខភ្លាម

ក្លស់ = ន. (ដូចឆត្រ), បាំងក្លស់, តម្កោះក្លស់ ...

ឧ. សម្ដេចយាងត្រួតពលមានអ្នកចាំងក្លស់ដើរតាមពីក្រោយ

# ទ

ទ = ន. ទទឹក, ទស័ង្កសី, ទបង្ហូរទឹក ...

ឧ. ទបង្ហូរទឹកផ្ទះខ្ញុំធ្វើអំពីដែកស័ង្កសី ។

ទរ = កិ. (ជេរ) ទរម្ដាយគ្នា, ទរគ្នា, អុញទរគ្នាហើយ...

ឧ. ក្មេងពីរនាក់នេះឈ្លោះគ្នាទរម្ដាយគ្នាទៅវិញទៅមក

ទង់ = ន. ទង់ជ័យ, ទង់ព្រលឹង, ទង់ខ្មោច ...

ឧ. ផ្ទះនេះចងទង់ព្រលឹងច្បាស់ជាមាននរណាស្លាប់ហើយ

ទុង = ន. សត្វទុង, ហ្វូងទុង, ទុងស៊ីត្រី ...

ឧ. ទុងជាបក្សីព្រៃ ស៊ីត្រីជាអាហារ ។

ទណ្ឌកម្ម = ន. (អា.ថ.ទាន់.) ធ្វើទណ្ឌកម្ម, ដាក់ទណ្ឌកម្ម ...

ឧ. ត្រូវដាក់ទណ្ឌកម្មចំពោះសិស្សណាដែលខ្ជិលៗ

ទន្ត = ន. (អា.ថ.ទាន់) (ធ្មេញ) ព្រះទន្ត ...

៖. ព្រះទន្តព្រះនាងសង្ឃបក្ខុក ។

ទាន់= គុ. ដើរឱ្យទាន់ - ទាន់ពេលវេលា - ទាន់បង្ហាន់លោក

៖. ពាក្យស្លោកថា «បើដេញទាន់កុំជាន់កែង» ។

ទន់= គុ. (ព.ផ្ន.រង) ទន់ល្មន់, ទន់ភ្លន់, ទន់ល្មើយ, ទន់ល្មក...

៖. ចាស់ៗ ចូលចិត្តពិសាចំណីណាដែលទន់ ៗ ។

ទុន= ន. ដើមទុនរកស៊ី, នាយទុន, មានទុនច្រើន ...

៖. យើងមានដើមទុនល្មមរកស៊ីធ្វើជំនួញបានហើយ ។

ទប់= កិ. ទប់ចិត្ត, ទប់ទល់, ទប់កម្លាំង, ទប់កំហឹង ...

៖. ត្រូវបេះទប់កំហឹងឱ្យកុំឱ្យខឹងជ្រុលហួសប្រមាណ ។

ទព្យ= ន. (ភា.ថ.ទប់) ទព្យសម្ភារៈ ...

៖. នៅខ្វះទព្យសម្ភារៈច្រើនណាស់ក្នុងការស្ថាបនា

ទល់= កិ. តទល់, ទប់ទល់, ទល់លាមក, ទល់នោម ...

៖. ឯងយកបន្ទល់មកទល់ផ្ទះប្រយ័ត្នរលំ ។

ទុល= កិ. ទុលការ, ទុលដី, ទុលហោប៉ៅ ...

ឧ. ស្អីទុលៗ នៅក្នុងគំនរចំបើងឯនោះ ?

ទល់= កិ. (អា.ថ.ទាល់) ទល់គំនិត, ទល់ប្រាជ្ញ, ទល់ក្រ ...

ឧ. នៅក្នុងភូមិខ្ញុំពុំសូវមានមនុស្សទល់ក្រប៉ុន្មានទេ

ទាល់= គុ. ផ្លូវទាល់, ទាល់ប្រាក់ចាយ ...

ឧ. ផ្លូវនេះទាល់ដើរទៅមុខទៀតពុំរួចឡើយ ។

ទស= ប.សំ(អា.ថ.ទស់)(ដប់) ទសកៈ, ទ្វាទសកៈ, ទសបារមី

ឧ. កែវចរណៃនេះមួយទ្វាទសកៈថ្លៃប៉ុន្មាន ?

ទស់= កិ. ទស់ជួស់, យកព្រួលមកទស់ទឹកព្រែក ...

ឧ. គេទស់ជួស់នៅក្នុងព្រែកដើម្បីចាប់ត្រី ។

ទោះ= និ. ទោះបី, ទោះល្អក្តី, អាក្រក់ក្តីទោះបើ ...

ឧ. ទោះល្អក្តីអាក្រក់ក្តីក៏ជាបងប្អូនយើងដែរ ។

ទា= ន. សត្វទា, ពងទា, បាយទា, ទាសំពៅ, ទាអង្កាម

ឧ. អ្នកស្រុកនៅភូមិខ្ញុំនាំគ្នាចិញ្ចឹមទាមួយផ្ទះបួនឬ

ប្រាំគ្រាន់ យកពងអាស្រ័យ ឬលក់ទៀតផង ។

ទារ= កិ. ទារពន្ធដា, ទារប្រាក់, ទារបំណាងដៃ ...

១. កូនក្មេងនេះកាំរអុកម្ដាយយក ទារទិញរូបតុក្កតា ។

ទាង= ន. (ស្មើគកស្មើថៃ) មាន់ទាង ...

១. បងខ្ញុំចិញ្ចឹមមាន់គក មាន់ថៃ មាន់ទាងនិងមេមាន់

ជាច្រើនប្រយោជន៍យកសាច់និងពង ។

ទៀង= គុ. ទៀងត្រង់, ទៀងទាត់, ទៀងពេលវេលា ...

១. យើងត្រូវនិយាយឲ្យទៀង កុំក្រឡាស់សំដី ។

ទាន= ន. សុំទាន, ធ្វើទាន, ទានប្រោស ...

១. សប្បុរសជនទាំងនេះបានបរិច្ចាគទានដល់អ្នកក្រ

ទៀន= ន. អុជទៀន, អុជទានគោល, ទៀនមួយហោ ...

១. លោកតាអាចារ្យទិញទៀនធូបយកទៅសុំសីលឯវត្ត

ទាប= គុ. (ព.ផ្ទុ.ខ្ពស់) រាបទាប, ទាបទ្រនាប់, ថោកទាប...

១. ល្បែងស៊ីសងជាប្រាក់ជាល្បែងទាបថោកបំផុត

ទៀប= ន. ដើមទៀប, ទៀបទុំ, ទៀបខ្ចី ...

ឧ. ផ្លែទៀបដែលមិនទាន់ទុំនោះឥឡូវក៏ទុំញាសពេកៗ

ទៀប= គ.ទិ. ទៀបភ្លឺ, ទៀបដល់, ទៀបនឹងដាច់ខ្យល់ស្លាប់...

ឧ. យប់មិញទៀបភ្លឺមានភ្លើងឆេះផ្ទះគេជិតខាងខ្ញុំៗ

តៀប= ន. (ដូចគោក) ឧ. តៀបនេះលាបខ្ញុកម្រក្សណ៍រលោង

ស្រិល ៗ

ទិព្វ-ទិព្យ= គុ. (គ.ថ.ទីប) គ្រឿងទិព្វ, ភ្នែកទិព្វ...

ឧ. ព្រះឥន្ទ្រាធិរាជទ្រង់មានភ្នែកទិព្វគ្រឿងទិព្យៗ

ទីប= ព.ផ្សំ. (ប្រទីប=ន.) អុជប្រទីប, ប្រទីបផ្កាលា ...

ឧ. នៅពិធីបុណ្យអុំទូក មានអុជប្រទីបផ្កាលាភ្លឺ

ព្រោងព្រាតពាសពេញតែផ្ទៃទន្លេ ៗ

ទិញ= កិ. ទិញនំ, ទិញបន្លែបង្ការ, ទិញអីវ៉ាន់ ...

ឧ. ផ្ទះខ្ញុំមានលក់ចេញ ទិញចូលរបស់ចាស់ៗ ៗ

ទៀញ= គុ. (ក្រែះ) ឧ. មនុស្សដើរទៀញធ្មេញល្អិត ៗ

ទូ= ន. ទូឈើ, ទូដែក, ទូកញ្ចក់ ...

ឧ. ទូកព្នាក់នេះធ្វើអំពីឈើបេងក្វឹរលោង ។

ទូរ= កិ. (ប្រៀបធៀប) ទូរទាត់, ទូរគ្នា ...

ឧ. លោកយកថ្ងូរដែលលោកចង់ជូរនោះមកទូរគ្នាសិនមើល ។

ទុក= កិ. ទុកដាក់, ទុកចិត្ត, ទុកស្មើទឹង ...

ឧ. ការនេះសូមលោកទុកចិត្តលើខ្ញុំចុះ ខ្ញុំនឹងធ្វើជូនតាមបំណងរបស់លោកបាន ។

ទុក្ខ= ន. (ព.ផ្ទ.សុខ) កើតទុក្ខ, ទុក្ខព្រួយ, ទុក្ខសោក ...

ឧ. សព្វថ្ងៃខ្ញុំកើតទុក្ខ ព្រោះជីដូនខ្ញុំគាត់ទើបតែនឹងធ្វើមរណកាលនៅពេលថ្មីៗនេះ ។

ទួ.ទូ= កិ. ទួទៅ, មនុស្សទួទៅ, វិជ្ជាទួទៅ ...

ឧ. វិជ្ជាទួទៅក្នុងលោកនេះគួរតែសិស្សត្រូវព្យាយាមសិក្សាឲ្យបានហ្មត់ចត់គ្រប់ៗគ្នា ។

តួ= ន. តួ, តួកាយ, តួផ្ទះ ...

ឧ. តួឯកល្ខោនច្រៀងពីរោះគ្រាន់បើ ។

ទេ= និ. ទេ! ទេ! ខ្ញុំមិនដឹងទេ, ត្រូវទេ? ទេ! អញ្ជើញទៅចុះ...

១. ខ្ញុំមិនដឹងទេ កុំមកប្រកាន់ខ្ញុំយ៉ាងហ្នឹង ។

ទេរ= គុ. ទ្រាំងទេរ, សសរទ្រេតទេរ, ទេរទៅខាង...

១. ទ្រាំងទន្លេនេះទេរ មិនសូវហោតប៉ុន្មានទេ ។

ទេសន៍=ន. ស្តាប់លោកទេសន៍, ស្តាប់ទេសន៍, ទេសនា ...

១. ឧបាសក ឧបាសិកាកំពុងផ្ទៀងស្តាប់លោកទេសន៍

ទេស=កិ.វិ.(សាត់ព្រាត់)ដើរទេស, បរទេស(ស្រុកទេសៈ=ន.)

១. ជននេះដើរទេសគ្រប់ស្រុកគ្រប់ខេត្តនៃកម្ពុជា ។

ទេះ= ព.ស្យ. (រទេះ= ន.) រទេះគោ, រទេះក្របី, រទេះសេះ...

១. កាលពីដើមអ្នកស្រុកធ្វើដំណើរដោយរទេះសាឡី ។

ទៃ= ន. (ថង់), ទៃប្រកអង្ករ, ស្ពាយទៃ...

១. អ្នកអើយ! ស្ពាយទៃទៅឯណាដូចជាប្រញាប់ម្ល៉េះ?

ព្រះទ័យ=ន.(អា.ថ.ទៃ) ព្រះទ័យស្មោះត្រង់, ទន់ព្រះទ័យ ...

១. សម្តេចឪទ្រង់មានព្រះទ័យទន់ភ្លន់ ទៅកាន់ប្រ-
ជារាស្ត្រគ្រប់ឋានៈមិនរើសមុខ ។

ទ្រោ= ប.សំ. (ពីរ) ទោចក្រយាន, អនុសេនីទោ, ឯក, ទោ,

ឧ. រាល់ព្រឹកនិងល្ងាច ខ្ញុំជិះទោចក្រយានយន្ត ទៅសាលាដោយប្រុងប្រយ័ត្នខ្លាចមានគ្រោះថ្នាក់ចរាចរ ។

ទ្រោវ= គុ. (ទ្រេត) ដំណើរទោរៗ, មែកឈើទោរលើដំបូល...

ឧ. អ្នកប្រមឹកដើរទោរទៅឆ្វេងទោរទៅខាងស្តាំ ។

ទុំ= គុ. (ព.ផ្ទុ.ខ្ចី) ស្លឹកឈើទុំ, ចាស់ទុំ, ល្មុតទុំ, ទៀបទុំ...

ឧ. ក្មេងសម័យឥឡូវមិនសូវគោរពចាស់ទុំប៉ុន្មានទេ ។

ទុំ= កិ. ចាបទុំ, ក្អែកទុំ, លលកទុំលើមែកឫស្សី...

ឧ. បក្សីតាំងគូនេះទុំលើទ្រនំរយ៉ាងសុខក្សេមក្សាន្ត

ទុម=ព.ផ្សេ.(អា.ថ.ទំ)(រមទម ឬ រម្យទម=គុ.)ឬកពាររមទម...

ឧ. ក្មេងនេះមានឬកពាររម្យទមគួរជាទីស្រឡាញ់ ។

ទ្រង់= កិ. (រាក់) ទ្រង់គ្រឿងអលង្ការ, ទ្រង់ព្រះអម្ពរ...

ឧ. ព្រះនាងទ្រង់គ្រឿងអលង្ការភ្លឺចិញ្ចែង ។

ទ្រង់=បុ.ស. ទ្រង់ព្រះសណ្ដាប់, ទ្រង់យាងទៅ...

ឧ. សូមទ្រង់ព្រះមេត្តាប្រោស ។ សូមទ្រង់ជ្រាប។

ទ្រង់= ន. ទ្រង់ទ្រាយ, ទ្រទ្រង់, ទ្រង់តាមទ្រនាប់...

ឧ. ទ្រង់ទ្រាយរបៀបនេះមិនមែនអន់ប៉ុន្មានទេ ។

ទ្រុង= ន. ទ្រុងមាន់, ទ្រុងទា, ទ្រុងដាក់ត្រី, ទ្រុងជ្រូក...

ឧ. ឈ្មួញសត្វដើរទិញមាន់ទាដាក់ក្នុងទ្រុង ។

ទ្រព្យ= ន. ទ្រព្យសម្បត្តិ, របស់ទ្រព្យ, ភោគទ្រព្យ...

ឧ. សម្បត្តិទ្រព្យទាំងនេះខ្ញុំរកដោយកម្លាំងញើស។

ទ្រាប់= កិ. ទ្រាប់ក, ទ្រាប់គូថ, ទ្រាប់ទ្រនាប់...

ឧ. ឯងយកក្រមាមកទ្រាប់កសិនសឹមលីឈើនេះទៅ។

ទ្រាប= ន. កូរទ្រាបបាយ, នំទ្រាបបាយ...

ឧ. ម្ដាយខ្ញុំយកអង្ករដំណើបទៅកូរនំទ្រាបបាយ ។

ទ្រាប= កិ. (សង្កត់ពីលើ) ទ្រាបព្រៃ, ទ្រាបត្រី...

ឧ. បងខ្ញុំយកឈ្នក់ទៅទ្រាបត្រីនៅក្នុងបឹងគេជា។

ត្រៀប= កិ.វិ.ត្រៀបត្រា, មនុស្សឈរត្រៀប...

ឧ. មនុស្សឈរត្រៀប ចាំមើលហេតុការណ៍នេះ។

ត្រាល= កិ.ត្រាលលើគ្នា, ដេកត្រាល, គោបត្រាល...

ឧ. ប្អូនខ្ញុំវាដេកត្រាលលើគ្នាគ្រោលប្រឡាក់សុទ្ធតែដី។

ត្រៀល= ន. ផ្លែត្រៀល, ដើមត្រៀល, ត្រៀលដោះគ្រប...

ឧ. ផ្លែត្រៀលទុំមានរសជាតិជូរអែមៗ ។

ធន= ន. (សា.ប.ធន់) ធនធាន, ទ្រព្យធន...

ឧ. ធនធានទាំងនេះបានមកដោយសារខំប្រឹងរក។

ធន់= កិ. (ទ្រាំ) អត់ធន់, ធន់ជម្ងឺ, ធន់ក្តៅនិងត្រជាក់...

ឧ. គោធន់នឹងកំដៅព្រះអាទិត្យជាងក្របី ។

ធុន= ន. (បែប, យ៉ាង, ពី.) ធុនអាក្រក់, ធុនល្អ, របស់ធុនអន់

ឧ. របស់នេះមានច្រើនធុនណាស់កុំប្រឡំ ។

ធុំ= កិ. ធុំក្លិន, ធុំក្រអូប-ធុំស្អុះ...

ឧ. នៅទីនេះដូចជាធុំក្លិនក្រអូប ខ្ញុំធុំឬ ?

ធំ= គុ. (ព.ផ្ទ.តូច) ធំទូលាយ, ធំធេង, ធំល្វឹងល្វើយ ...

ឧ. ក្របីមាឌធំជាងគោ ហើយខ្លាំងផង ។

## ន

ន៎-ហ៎= និ. នុ៎ះន៎, អុញហ្ន៎, អ៊ីទៅហ្ន៎...

ឧ. នុ៎ះហ្ន៎ គេហ៎នៅឯណោះ ប្អូនរកគេមានការអ្វី ?

នា= អា.និ. នាអាកាស, នាលោកិយ, នាបច្ចុប្បន្ន, នាដងព្រៃ...

ឧ. យន្តហោះបណ្ដែតខ្លួននាលើអាកាសវេហា ។

នារ= គុ. (ជ្រុបដំពល) ដីនារ, រត់នារ...

ឧ. ដីខ្សាច់នាររហូតដល់មាត់ទឹក ។

នប់= គុ. (ក្រមុល-កន្ទុប) ស្នែងនប់... ឧ. គោស្នែងនប់ ។

នព្វន្ត= ន. (អា.ថ.នប់.) ក្បួននព្វន្ត, នព្វគុណ, លេខនព្វន្ត...

១. សម័យសម្តេចឪ អ្នកស្រុកប្រុសស្រីចេះអក្សរ

និងលេខនព្វន្តគ្រប់ៗគ្នា ។

ន័យ= ន. មានន័យ, អត្ថន័យ, និយាយមានន័យ...

១. ចូរអ្នកពន្យល់អត្ថបទនេះមើល តើមានន័យដូចម្តេច?

នៃ= អា. និ. ១. សំលៀកបំពាក់នៃលោក នៃអ្នក ល្អហើយ

សមផង ។

នាក់= សព្ទ.(ចំនួន) មនុស្សប៉ុន្មាននាក់?, បច្ចាមិត្ត៥០នាក់...

១. សមាគមនេះ មានសមាជិកប៉ុន្មាននាក់ហើយ?

អ្នក= បុ.ស. លោកអ្នក, អ្នកស្រី, អ្នកស្រែចំការ...

១. អ្នកស្រីអញ្ជើញទៅណាមកណាហ្នឹង ?

នាដ= ន. (របាំ) ១. នាដការនេះច្រៀងពិរោះ រាំក៏ស្រស់ ។

នាថ= ន. (ច្រើនប្រើក្នុងកាព្យឃ្លោង) ១. នាងនាថដើរទៅ

សំដៅព្រៃជ្រៅ សំសាន្តស្ពានស្ងាត់... ។

នាម= ន. នាមត្រកូល, ព្រះនាមថា, ព្រៃនាម...

ឧ. ខ្ញុំសុំបញ្ជាក់គោត្តនាមនិងនាមផ្ទាល់របស់អ្នក ។

ទៀម = ព. ផ្ស. (ទំនៀម = ន.) ទំនៀមបុរាណ, ទំនៀមទំលាប់

ឧ. ទំនៀមទំលាប់ខ្មែរយើង គួរសមគ្នាដោយលើកដៃសំពះសួរគ្នាទៅវិញទៅមក ។

ទាល = ន. ប្រទាលនាល ឧ. គ្រូមើលជម្ងឺនេះរេះប្រទាលនាលមកផ្សំថ្នាំឲ្យអ្នកជម្ងឺម្នាក់ ។

ទាលិ-ទាឡិ = ន. ទម្ងន់មួយទាលិ, អង្ករមួយទាលិ, ១ ទាឡិ

ឧ. បើអ្នកទៅផ្សារ ខ្ញុំសុំផ្ញើប្រាក់ទិញសាច់ជ្រូកមួយទាឡិឲ្យខ្ញុំផង ។

និមិត-និម្មិត = កិ. (ប្រែ-កាឡា) ទ្រង់និមិតព្រះអង្គ, សុបិន្តនិមិត

ឧ. ព្រះនាងទ្រង់សុបិន្តនិមិតឃើញថា... ។

និមិត្ត = ន. (តំណាង) និមិត្តរូប, មានខ្ញុំជានិមិត្តរូប...

ឧ. ក្នុងរឿងនេះសូមលោកកុំព្រួយ មានខ្លួនខ្ញុំជានិមិត្តរូប ។

និង = និ. ខ្ញុំនិងអ្នក, បងនិងអូន, គោនិងក្របី ...

ឧ. គោក្របីសេះទិញដំរីជាសត្វពាហនៈ ។

ហ្នឹង= វិ.ស. ហ្នឹងហើយ, ហ្នឹងមែន, ហ្នឹងឯង...

ឧ. ដំណើរហ្នឹងច្បាស់ជានាំឲ្យខូចការណ៍ជាមិនខាន

នឹង= គុ. នឹងថ្កល់, នឹងហ្ន៎, នឹងខ្លួន, នឹងធឹង, ខ្ញុំនឹងទៅ, ត្រូវនឹង

ឧ. ប្តូរឯងអង្គុយឲ្យនឹងកុំកម្រើកខ្លួនឲ្យសោះ ។

នុះ = សព្វ. នុះៗ, នុះហ្ន៎...

ឧ. នុះន៍ មើលទៅឃើញលឹមៗនោះ ។ នុះៗផ្ទះខ្ញុំៗ

នោះ= វិ.ស. ឯនេះឯនោះ, នោះហើយ, ត្រង់នោះ, វត្តនោះ...

ឧ. សំបុត្រដែលឯងផ្ញើមកនោះ បងបានមើលដឹង

សេចក្តីសព្វគ្រប់អស់ហើយហេតុនេះសូមអ្នកកុំបារម្ភ ។

នៃ= និ. (ទិង) ម្តាយនៃកូន, គ្រូនៃសិស្សទាំងឡាយ...

ឧ. ឪពុកម្តាយនៃបុត្រពីតាបានចំណាយប្រាក់ធ្វើ

បុណ្យយ៉ាងអធិកអធម ។

នៅ= កិ. នៅឯណា, នៅធ្វើការ, នៅទីនេះ...

១. ប៉ាឯងនៅផ្ទះឬទេ? បាទ! ឪពុកខ្ញុំគាត់មិននៅ
ទេលោកតូ! ចុះលោកតូរកគាត់មានការអ្វី ?

## ឞ

បង្កៀរ= ប. បង្គោះបង្កៀរ...

១. ខ្ញុំខំបង្គោះបង្កៀរអស់ហើយបានតែប្រាក់ប៉ុណ្ណឹង
ទេយកមកសងលោកគ្រូពេលនេះ ៗ

បង្គា=ន. (ព្រានសមុទ្រដូចជាកំពឹស) បង្គាក្រៀម ...

១. ម្តាយខ្ញុំប្រើខ្ញុំឲ្យទិញបង្គាយកមកដាក់ស្ងោរគ្រឡាប

បណ្តុះ=កិ. (ដើម«ដុះ») បណ្តុះបណ្តាល, បណ្តុះសណ្តែក-
បណ្តុះជាតិ បណ្តុះពូជ ...

១. ម្តាយខ្ញុំបានបណ្តុះសណ្តែកមួយក្អម ធ្វើល្បាយ
នំបញ្ចុកទុក ប្រគេនលោកតានៅថ្ងៃស្អែកព្រឹក ៗ

បន្តុះ=កិ. (ដើម«តុះ») បន្តុះបន្អាប់, បន្តុញបន្តុះ ...

១. យើងមិនត្រូវបន្តុះបន្អាប់មិត្រនៅកណ្តាលជំនុំឡើយ ៗ

បន្ទាស់= ន. មានបន្ទាស់, មានច្រើនបន្ទាស់ ...

ឧ. ការនេះបើគ្មានបន្ទាស់ ខ្ញុំធ្វើតែម្នាក់ឯងពុំរួចទេ

ពន្ទះ= កិ. ពន្ទះស្បែក, ពន្ទះភ្លឹង. ពន្ទះគ្នា ...

ឧ. ជាតិពាមប្រសប់ពន្ទះស្បែកគោណាស់ ។

បន្ទៀក= កិ. (ប្រើចំពោះតែត្រីទេ) ត្រីបន្ទៀក ...

ឧ. ត្រីបន្ទៀកច្រើនណាស់ក្នុងត្រពាំងនេះ ។

ពន្ទាក= ពន្ទាកដែក, ជាប់ទឹងពន្ទាក, សំលៀងពន្ទាក ...

ឧ. ជាងឈើជាប់ឈើធ្វើជណាប់ ទឹងពន្ទាក ។

បត់= កិ. (ធ្វើឲ្យទៅជាមានផ្នត់) បត់ក្រដាស, បត់ខោអាវ

បត់ជើងបត់ដៃ, បត់បែន, បត់ជាផ្នត់ ៗ ...

ឧ. បូអ្នកបត់ភួយបត់មុងនៅពេលក្រោកពីនិទ្រា

បទ= ន. បទចម្រៀង, បទល្មើស, បទឧក្រិដ្ឋ, (ជនបទ=ន.) ...

ឧ. ជននេះប្រព្រឹត្តបទល្មើសទឹងច្បាប់សម្រាប់រដ្ឋ ។

បក្ខ.បក្ស= ន. (ពួក, បនកៀន) គណៈបក្ខ, បក្សពួក ...

ឧ. កុំបណ្ដោយកូនឲ្យមានបក្សពួកច្រើនពេក ។

**ប៉ាក់**= កិ. ប៉ាក់ដេរ, ប៉ាក់កូនកន្សែង, ប៉ាក់ស្រោមខ្នើយ

ឧ. សិស្សស្រីៗ រៀនដេរប៉ាក់ក្នុងមួយអាទិត្យតែម្ដង

**បច្ចាមិត្ត**= ន. (អា.ថ.ប៉ាច.) បច្ចុប្បន្ន, បច្ចេកទេស ...

ឧ. លោកធ្វើការនេះពុំសូវមានបច្ចេកទេសគ្រប់គ្រាន់ទេ

**ប៉ាច់**= ឧ.ស. ប៉ាច់ៗ, ឮសូរប៉ាច់ៗ, ដាល់គ្នាប៉ាច់ៗ...

ឧ. គូប្រដាល់នេះវាយគ្នាប៉ាច់ទៅប៉ាច់មកពុំឈ្នះពុំចាញ់សោះ

**បដិបត្តិ–ប្រតិបត្តិ**= ន. ការប្រតិបត្តិ, សេចក្ដីបដិបត្តិ...

ឧ. ការប្រតិបត្តិនេះត្រឹមត្រូវល្អហើយទៀងទាត់ផង

**បដិបត្ត–ប្រតិបត្ត**= កិ. ត្រូវប្រតិបត្ត, ចូរបដិបត្ត ...

ឧ. បើយើងប្រតិបត្តការអ្វីមួយហើយ ត្រូវតែព្យាយាមធ្វើឲ្យទាល់តែសម្រេចការនោះ ។

**ប្រណិបតន៍**= កិ. (គោរព) សូមប្រណិបតន៍, ក្រាបប្រណិបតន៍

ឧ. សូមក្រាបប្រណិបតន៍មកលោកឪពុកនិងអ្នកម្ដាយ ។

បន្ទុំ= កិ. (ធ្វើឲ្យទុំ) បន្ទុំចេក, បន្ទុំស្វាយ, បន្ទុំល្មុត ...

១. ម្ដាយខ្ញុំបន្ទុំចេក ក្នុងឃ្លុបស៊ីម៉ង់ត៍ទុកលក់ ។

បន្ទុំ= កិ. (ធ្វើអ្វីឲ្យទំលើអ្វីមួយទៀត) ដាក់បន្ទុំៗ ...

១. បងប្រុសខ្ញុំគាត់បន្ទុំល័ខ (ចងល័ខ) នៅលើ
ដើមសង្កែនិងដើមកគោះនៅក្បែរផ្ទះខ្ញុំ ។

បា= បុ.ស. មេបា, ចូរបា, (គោបា= ន) ...

១. ចូរបារាល់គ្នាគោរពប្រតិបត្តិមាតាបិតាអ្នក ។

បារ= កិ.(យកចេញ) បារអង្ករ, បារអាចម៍ដី, បារលុយពីហោប៉ៅ

១. ឯងបារអាចម៍ដីពីក្នុងរណ្ដៅ យកទៅចាក់ត្រង់
កន្លែងទំនាបនាមុខផ្ទះឯនោះកុំឲ្យវាជ្រាំ ។

បាត– ន. បាតឆ្នាំង, បាតខ្ទះ, បាតទន្លេសមុទ្រ, បាតគុក...

១. ម្ហូបនេះឆ្ងាញ់ណាស់ នាំគ្នាស៊ីលិទ្ធបាតចាន ។

បាទ= និ. ខ្ញុំបាទ, ខ្ញុំប្របាទ, ព្រះបាទម្ចាស់...

១. ខ្ញុំបាទជាអ្នកធ្វើស្រែចម្ការ ។ បាទម៉ែ! ។

បាទ= ន. (ជើង) ព្រះបាទ, ក្រោមល្អងធូលីព្រះបាទ...

ឧ. សូមក្រាបក្រោមល្អងធូលីព្រះបាទជាម្ចាស់ ៗ

បាត្រ= ន. បាត្រលោក, ទ្រនំបាត្រ, ពប់បាត្រ...

ឧ. ថ្ងៃនេះគេធ្វើបុណ្យពប់បាត្រព្រះសង្ឃ ៗ

បាស= ន. ស្លឹកបាស, ដើមបាស, ប្រហើរស្លឹកបាស...

ឧ. ថ្ងៃនេះគិតស្ងោរសំឡប្រហើរស្លឹកបាសឆ្ងាញ់ ៗ

ប៉ះ= កិ. បះបោរ, បះជើង, បះគូថ, របះរបោរ...

ឧ. ប្រជារាស្ត្របះបោរធ្វើបាតុកម្មប្រឆាំងនឹងចក្រពត្តិនិយម ដែលវាមកសង្កត់សង្កិន ៗ

ប៊ិត= កិ. (បិតនឹងកាំបិត) បិតបន្ទះឫស្សី, បិតស្រា, បិតជាន់គោត, បិទបន្ទោះ (កាំបិត=ន) ...

ឧ. បងប្រុសខ្ញុំបិតផ្តៅកាប់ធ្វើសន្ទែកមួយគូ ៗ

ប៊ិទ= កិ. (ធ្វើឲ្យជិត) បិទបាំង, បិទទ្វារបង្អួច, បិទឡេវ...

ឧ. ជនកំសាកច្រើនតែធ្វើសំបុត្របិទមុខ ៗ

បុក= កិ. បុកអង្ករ, បុកគល់ឈើ, បុកស្លា, បុកស្រូវ...

ឧ. បើបានបុកស្រូវកុំពោលអង្កាម... ៗ យាយ ៗ

ពិសាស្លាបុក ស្ដោះទឹកមាត់ក្រហមប្រលាសពេញដីៗ

បុគ្គលិក=ន. (អា-ថ.បុគ...) បុគ្គល, បុគ្គលិកសិក្សា...

ឧ. បុគ្គលិកសិក្សាជាច្រើន បាននាំគ្នាចូលសមា-

គមគរុសង្គ្រោះ ៗ

បុស្ស=ន. (ខែទីពីរ) ឧ. ខ្ញុំកើតឆ្នាំរោង ខែបុស្ស ថ្ងៃអង្គារ ៗ

បុះ= កិ. ឈើបុះឈាមជើង, គោបុះគ្នា...

ឧ. គោបុះគ្នា បាក់ស្នែងៗបុះទៅបុះដល់ណាទៀតៗ

បូ= ន. (បន្ទះកំណាត់សម្ពត់) បង់បូ, បូពណ៌ក្រហម ខៀវ...

បូព៌= ន. (ទិសខាងកើត) ទិសបូព៌, ចុងបូព៌ាប្រទេស...

ឧ. ព្រះទិនករពះនៅទិសបូព៌ ហើយអស្តង្គតនៅ

ទិសបស្ចិម ៗ

បួ= ប. បឹងបួ, ឧ. នៅរដូវប្រាំងឆ្នាំនេះ ទឹកទន្លេស្ទឹងបឹងបួ

ទាំងឡាយវើងហួតហែងអស់ ។

ប្បូរ= ន. បួរគោ, ឆ្នាក់បួរ...

ឧ. គោបានេះឆ្នាក់បួរស៊ើរតែដល់ដី ។

ប្បោះ= កិ. បោះពុម្ព, បោះឡ្ប, បោះបង់ចោល...

ឧ. សៀវភៅបញ្ជាក់សទិសសព្ទនេះបោះពុម្ពជាលើកដំបូង ។

តាបស= ន.(អា.ថ.បស់) តាបសឫសី, មហាតាបស...

ឧ. តាបសឥសីនិមន្តទៅចង្ក្រមណ៍ភាវនាធម៌ ។

បំរាស់= ប. បំរើបំរាស់... ឧ. កូនឯងទៅនៅជាមួយនឹងគេទៅ

ហើយខំបំរើបំរាស់គេឲ្យមែនទែន កុំធ្វេសប្រហែស ។

បំរះ= កិ. ត្រើបំរះ, បំរះនេនៀល...

ឧ. ឯងបំរះទៅខាងនេះក៏ពុំរួច បំរះទៅខាងនោះក៏

ពុំរួច ព្រោះមានសុទ្ធតែបន្លានៅជុំវិញខ្លួនខ្ញុំ ។

ប្រព្រឹត្តិ= ន. សេចក្ដីប្រព្រឹត្តិ, អំពើប្រព្រឹត្តិ, ការប្រព្រឹត្តិ...

ឧ. ការប្រព្រឹត្តិនូវអំពើអាក្រក់ នាំឲ្យវិនាស ។

ប្រព្រឹត្ត=កិ. ចូរអ្នកប្រព្រឹត្ត, កុំប្រព្រឹត្ត, ត្រូវប្រព្រឹត្ត...

១. យើងត្រូវប្រព្រឹត្តសុចរិតទៀងត្រង់ជាដរាប ។

ប្រមាណ=ន. (ស្មាន) កុំប្រមាណ, ប្រមាណជា...

១. យប់មិញប្រមាណជាម៉ោង១២ អគ្គិភ័យឆេះផ្ទះមួយឆេះភ្លឺសន្ធោសន្ធៅ ។

ព្រមាន=កិ. (រំឭក) កុំព្រមាន, ខ្ញុំព្រមានលោក...

១. នៅពេលនេះ ខ្ញុំសុំព្រមានអស់លោកអ្នក ...

ប្រមាថ=កិ. (មើលងាយ. ធ្វើបាប) មនុស្សប្រមាថសត្វ, កុំប្រមាថចាស់, ប្រមាថអ្នកដទៃ ...

១. មានពាក្យចាស់ថា «ក្មេងៗប្រមាថចាស់រាំងអាយុខ្លី» ។

ប្រមាទ=កិ. (ធ្វេសប្រហែស) ប្រមាទការ...

១. ឯងប្រមាទការនេះពន់ពេក បានជារាំងខូចការ ខូចការយ៉ាងហ្នឹង ។

ប្រសប់=គុ. ប៉ិនប្រសប់, ប្រសប់ធ្វើការ, ប្រសប់ណាស់...

ឧ. មានពាក្យថា «អ្នកបេះដប់មិនស្មើនឹងអ្នកប្រ-

សប់មួយ» ។

ព្រះសព=ន. បូជាព្រះសព, លោកគ្រូព្រះសព ...

ឧ. យើងធ្វើបុណ្យរំលាយព្រះសពនៅថ្ងៃ ខែ ឆ្នាំ ។

ប្រសព្វ=កិ. ប្រសព្វមុខ, ប្រសព្វគ្នា, ដេរប្រសព្វមុខ...

ឧ. ទឹកទន្លេនិងទឹកស្ទឹងហូរប្រសព្វគ្នា ធ្លាក់ទៅក្នុងសមុទ្រ ។

ប្រស=ឧ. ស. ប្រស ៗ, ព្រួសប្រស ៗ...

ឧ. ដំរីកាច់មែកឈើព្រួសប្រស ៗ ឯនោះ ។

ប្រោះ=កិ. ប្រោះត្រី, ប្រោះអណ្ដើក, ប្រោះទឹក...

ឧ. បងស្រីខ្ញុំគាត់ប្រោះត្រីទៅក្នុងផើងមួយយ៉ាងធំ ។

ប្រោស=កិ. ប្រោសពោល, ពានប្រោស...

ឧ. អាមុីយកគ្នាទៅប្រោសម្ដេចក៏មិនយកក្ដែទៅផង ។

ប្រាស=កិ. ប្រាសចាក, ប្រាសពោល, ព្រាត់ប្រាស...

ឧ. យើងត្រូវប្រាសចាកអំពើអយុត្តិធម៌គ្រប់បែប ។

ព្រះ = ន. ព្រះពុទ្ធ, ថ្វាយបង្គំព្រះ, ព្រះជាម្ចាស់...

ឧ. ឧបាសក ឧបាសិកានាំគ្នាថ្វាយបង្គំព្រះ ។

ប្រែះ = កិ. ប្រេះដេក, ប្រេះជើងប្រេះដៃ, ប្រេះខ្លួនទំរេត...

ឧ. អ្នកជម្ងឺប្រេះខ្លួនដេកយ៉ាំងថ្ងូរ ។

ប្រី = ន. (ស្រដៀងដើមកក់) ប្រូតប្រី, ក្រងប្រី...

ឧ. ឪពុកមាខ្ញុំគាត់ទៅដកដើមប្រី យកមកក្រងធ្វើ

ជាកណ្ដាប ទុកធ្វើជញ្ជាំងផ្ទះគាត់ ។

ប្រិយ = គុ. ប្រិមប្រិយ, ប្រិយមិត្ត...

ឧ. ព្រះប្រិយមហាក្សត្រទ្រង់មានព្រះរាជឧត្ដារថា

ប្រឹស = ន. (មុខទ្រូវម្លូលប) ប្រឹសលប, ប្រឹសទ្រូ...

ឧ. បងប្រុសខ្ញុំបេះធ្វើទ្រមុខប្រឹសពីរ ។

ប្រឹស = គុ. គ្រាន់បើប្រឹសៗ, រាបានប្រឹស ៗ ជាងមុន...

ឧ. អ្នកជម្ងឺនេះមានកម្លាំងប្រឹសៗ ហើយ ។

ប្រឹស្ឋ=ន.(អា.ថ.ប្រឹស)ព្រះប្រឹស្ឋ(ខ្នង) ឧ.ព្រះប្រឹស្ឋព្រះអង្គ។

ប្រឹះ= ឧ.ស. ក្រៀងប្រឹះៗ, លើមប្រឹះៗ ...

ឧ. យប់មិញលើមប្រឹះៗពាល់ភ្លឺបណ្ដាលឲ្យមានកក់ជ្រាំ។

ប្រើស=ន. សត្វប្រើស, ស្នែងប្រើស...

ឧ. ប្រើសជាសត្វចតុបាទព្រៃ ស៊ីស្មៅជាអាហារ។

ប្រុស=ន.(ព.ផ្ទុ.ស្រី)កូនប្រុស,ក្មេងប្រុស,កូនប្រសាប្រុស...

ឧ. ប្រុសៗឥឡូវបេះដកបេះស្ងួនដូចជាស្រីៗដែរ ។

ប្រុះ= គុ. (បំរុះពណ៌) ភ្លឺប្រុះព្រាយ ...

ឧ. នៅទីក្រុងភ្នំពេញ វេលាយប់គេអុជចង្កៀងភ្លឺ

ប្រុះព្រាយពាសពេញទីក្រុង ។

ប្រួញ= កិ. (បង្រួញ, រួញ) ប្រួញសេចក្ដី, ខ្លាចព្រួញខ្លួន...

ឧ. កូនក្មេងនេះខ្លាចខ្មោចឡើងប្រួញខ្លួន ។

ព្រួញ=ន. (កូនសរ) ធ្នូព្រួញ, ព្រួញមាស ...

ឧ. យុទ្ធោបករណ៍ដំនាន់ដើម គេប្រើស្នា ធ្នូ ព្រួញ

សំពែងជាដើម ។

ប្រួល= ឋ. ប្រែប្រួល, ប្រែប្រួលៗ ...

ឧ. កូនខ្ញុំកក្ដៅស្អុះដេកប្រែប្រួលៗ ពាល់ក្ដៅ ។

ព្រួល= ន. កំពង់ព្រួល, វែងព្រួល, ត្រីព្រួល ...

ឧ. គេបិតបន្ទោះឫស្សីវែងជាព្រួលសំរាប់កំពង់ត្រី ។

ព្រួល= គុ. ក្រហមព្រួលៗ, ខ្មៅព្រួលៗ ...

ឧ. កន្លែងនេះក្រហមព្រួលៗ វាកើតអីហ្នឹង ?

ប្រៀង= កិ. ប្រៀនប្រដៅ, ប្រិតប្រៀន ...

ឧ. គ្រូប្រៀនប្រដៅចង់ឲ្យតែសិស្សល្អ ។

ព្រាង= ន. ព្រានព្រៃ, នាយព្រាន, ព្រានប្រមាញ់ ...

ឧ. ព្រានប្រមាញ់ ដើរទៅបាញ់សត្វម្រឹគនៅក្នុងព្រៃ ។

ប្រៀប= កិ. (ប្រដូច, ដូរ) ប្រៀបធៀប, ប្រៀបប្រដូច, ទាញប្រៀប, គ្មានអ្វីមកប្រៀបផ្ទឹមបានឡើយ ...

ឧ. ហានះយើងកុំយកទៅប្រៀបធៀបនឹងគេនោះ ។

ព្រៀប= គុ. បបរព្រៀបចាន, ទឹកព្រៀបច្រាំង ...

ឧ. ទឹកទន្លេឡើងព្រៀបច្រាំង ។

ព្រាប= ន. សត្វព្រាប. ព្រាបនាំសារ ...

ឧ. សត្វព្រាបច្រើនរស់នៅលើដំបូលព្រះវិហារ ។

ប្រេង= ន. ប្រេងកាត, ប្រេងសាំង, ប្រេងដូង, ប្រេងល្ង ...

ឧ. ចង្កៀងម៉ាំងស៊ុងនេះផុតប្រេងកាត ។

ព្រេង= គុ. គូព្រេង, ពីព្រេងនាយ, ចាស់ព្រេងចាស់ព្រឹទ្ធ ...

ឧ. រឿងព្រេងបុរាណច្រើនតែពីរោះ ៗ ។

ប្រេះ= កិ. ប្រេះឆា, ពាងប្រេះ, ក្អមប្រេះ ...

ឧ. ពាងស៊ីម៉ង់ត៍នេះប្រេះលេចទឹកហូររឹមៗ ។

ប្រែះ= ឧ.ស. ឮប្រែះៗ, សូរប្រែះៗ ...

ឧ. នរណាយកអំបិលទៅដុតក្នុងចង្ក្រានឮសូរប្រែះៗ ។

ប្លៀក= កិ.វិ. សម្លឹងប្លៀកៗ, មើលប្លៀកៗ, ប្លៀកៗ ...

ឧ. ឆ្កែដេកសម្លឹងសាច់គោប្លៀកៗ មិនដាក់ភ្នែក ។

ភ្អៀក= កិ. (ផ្អៀងខ្លួន)(និយាយចំពោះតែសត្វដំរី) ក្អៀកខ្លួន.

១. ដំរីក្អៀកខ្លួនបំរុងនឹងគ្រលែងយោងគោល ។

ផ្អៀក= កិ. (ត្រីមាត់) ត្រីផ្អៀក, មានត្រីផ្អៀកច្រើន ...

១. នៅត្រពាំងនេះមានត្រីផ្អៀកច្រើនណាស់ ។

ប្អៀវ= គុ. (រហ័សណាស់) រហ័សប្អៀវ ...

១. បុរសនេះដើររហ័សប្អៀវរកតែមើលមិនទាន់ ។

ភ្អារ= គុ. ភ្អារមាត់ភ្អារក, សម្លភ្អារ ...

១. សម្លកកូរនេះភ្អារៗមានបង់អំបិលឬទេ ?

## ឧ

ផុង= កិ. ជាប់ផុង, ផុងជើង, ផុងខ្លួន ...

១. រទេះផុងភក់ថុកយ៉ាងជ្រៅគោអូសមិនរួចទេ ។

ភុង= ន.ស. ភុងៗ, ព្ភុង, ស្បរភុងៗពីរបីជង

១. ស្បរស្អីព្ភុងៗ ឯនាយខាងណោះ?

ផ្ចិត= ន. ចងផ្ចិត, ជ្រុះផ្ចិត, ទងផ្ចិត ...

១. មុននឹងកាត់ទងផ្ចិតទារកដែលទើបនឹងកើត ត្រូវលាងកាំបិតឬកន្ត្រៃ នឹងទឹកអាល់កុលឬយកទៅដុតឬគ្រាន់តែកោលនឹងអណ្តាតភ្លើងក៏បាន ។

ផ្សិត= ន. ផ្សិតបំពង់, ផ្សិតគរ, ផ្សិតបេក ...

១. សមិទ្ធិសង្គមរាស្ត្រនិយម លូតលាស់ដូចផ្សិតត្រូវទឹកភ្លៀងនៅរដូវវស្សា ។

ផ្លៀក= គិ. (ត្រីមាត់) ត្រីផ្លៀក, មានត្រីផ្លៀកច្រើន ...

១. មានត្រីផ្លៀកច្រើននៅក្នុងថ្លុកមួយជុំនេះ ។

ប្លៀក= គិ.វិ. មើលប្លៀកៗ, សម្លឹងប្លៀកៗ ...

១. បុរសនេះឃើញគេសម្លឹងប្លៀកៗ គ្មានពព្រិចភ្នែក

ភ្លៀក= គិ. (ផ្អៀងខ្លួន) (និយាយចំពោះតែដំរី) ភ្លៀកខ្លួន ...

១. ដំរីភ្លៀកខ្លួនរហ័សក្លែត ។

ផ្សារ= ន. ទៅផ្សារ, ក្នុងផ្សារ, លក់អីវ៉ាន់ឯផ្សារ ...

ឧ. ម្ដាយខ្ញុំគាត់ទៅផ្សារទិញអីវ៉ាន់យកមកធ្វើបុណ្យ

ផ្សារ= ក. (ធ្វើឲ្យជិត) ផ្សារពាន, ផ្សារប៉ោត, ផ្សារគូថឆ្នាំង

ឧ. ឪពុកខ្ញុំជួលជាងមកផ្សារទេសក្ដស៊ី ។

ផ្សា= គុ. ផ្សាមុខរបួស, ផ្សាក្អក អាណិតខ្លោចផ្សា ...

ឧ. អ្នករងគ្រោះនេះផ្សាគ្រប់មុខរបួសដែលត្រូវទីន គ្រាប់កាំភ្លើងរបស់ខ្មាំង ។

៣

ព= ក. ពកូន, ពពោះ, ពប្អូនដើរលេង ...

ឧ. ម្ដាយពកូនទៅដៃម្ខាង ដឹកដៃកូនម្នាក់ទៅដៃ ម្ខាងទៀត ។

ពរ= ន. ជូនពរ, ឲ្យពរ, ពរសព្វសាធុការ, ទទួលសាពរ.

ឧ. ឪពុកម្ដាយឲ្យពរសព្វសាធុការដល់កូនប្រុសកូនស្រី

ពរ= ក. (បិទ.លាប) ពរទូក ...

ឧ. កូនឯងទៅទិញជ័រទឹកយកមកពារទូកឲ្យជិតប្រ-
យ័ត្នជ្រាបទឹក ។

ពង់= កិ. ក្បោកពង់. ពង់ខ្ទុះ, បុកពង់ ...

ឧ. ក្បោកពង់រំសាយកន្ទុយដូចជាផ្ចិត ។

ពង្ស= ន. ពូជពង្ស, ពង្សាវតារ ...

ឧ. ក្មេងនេះពូជពង្សវាមិនអូនថយប៉ុន្មានទេ ។

ពុង= ន. បង់ពុង, បង់ខ្សែពុង ...

ឧ. ស្រីៗ បង់ពុងក្រមារទៅដងទឹក ។

ព័ត= កិ. (បក់)(អា.ថ.ពាត់) ព័តថ្វាយ...

ឧ. គីលៀនយកផ្តិតមកព័តថ្វាយព្រះមហាក្សត្រ ។

ពត្តិ= (អា.ថ.ពាត់) ចក្រពត្តិនិយម ..

ឧ. ពួកចក្រពត្តិវាសង្កត់សង្កិនទនគរណា ដែលទន់
ខ្សោយខាងសេដ្ឋកិច្ច ។

ព័ទ្ធ= កិ. (អា.ថ.ពាត់) ព័ទ្ធជុំវិញ, ហ៊ុំព័ទ្ធ ...

ឧ. ផ្ទះខ្ញុំមានរបងពទ្ធជុំវិញដើម្បីការពារសត្រូវ ។

ពាត់= ព.ផ្ស. (រំពាត់=ន.) រំពាត់ផ្តៅ, រំពាត់ខ្សែតី, រំពាត់ក្តគោ

ឧ. រំពាត់ខ្សែតីនេះធ្វើពីផ្តៅត្រះមានគល់ហើយរៀវចុង ។

ពណ៌= ន. ពណ៌ក្រហម, តាំងពិពណ៌អចៃទ្រូយ, ពិពណ៌អន្តរជាតិ... ឧ. សាលតាំងពិពណ៌ អចៃទ្រូយស្ថិតនៅទីក្រុងភ្នំពេញនិងនៅខេត្តនានា ។

ទំព័រ= ន. មួយទំព័រ, មួយរយទំព័រ, កន្ទះទំព័រ...

ឧ. សៀវភៅក្រាស់នេះមាន ១៥០០ ទំព័រ ។

ពន់= គុ. ពន់ពេក, ពន់ប្រមាណ, ពេកពន់, អពន់ប្រមាណ

ឧ. អ្នកឯងធ្វើយ៉ាងនេះ ជាអាក្រក់ពន់ពេកហើយ ។

ពន្ធ= ន. ពន្ធដា, ទារពន្ធ, ពន្ធអាករ...

ឧ. អ្នកជំនួញត្រូវបង់ពន្ធប៉ាតង់ជូនរាជការ ។

ពុន= កិ. ពុនសង្រែកជង់រែក, ពុនសម្លាយ, ពុនទ្រូ, ពុនលប

ឧ. ពូនើតពុនសក្រែកដងរែងទៅរកកណ្ដាប់ស្រូវ ៗ

ព័ន្ធ= កិ. (អា.ថ.ពាន់) ព័ន្ធជើងព័ន្ធដៃ, ពន្ធនាគារ...

ឧ. មហាពន្ធនាគារស្ថិតនៅក្រោយវត្តឧណ្ណាលោម

ពាន់= ប.សំ. មួយពាន់ពីរពាន់, មួយពាន់មានមួយរយដប់ដង

ឧ. ខ្ញុំធ្វើពជការមានបៀវត្សប្រចាំខែ តែបីបួនពាន់
រៀលប៉ុណ្ណោះទេ ៗ

ពល= ន. (អា.ថ.ពល់)(កម្លាំង) ពលទាហាន, ពលយោធា
ពលថ្មើរជើង លើកពល, បង់ពល ...

ឧ. ពលទាហានលើកព្យុហយាត្រាទៅទិសមរភូមិ ៗ

ពល់= ព.ផ្ស.(រំពល់=គុ.) រំពល់ទុក្ខ, កុំរំពល់...

ឧ. ឯងធ្វើយ៉ាងនេះនាំឲ្យរំពល់គេឯងកល់គ្នា ៗ

ពស់= ន. ពស់វែក, ពស់ព្រលិត, ពស់ចឹក, (កំពស់=ន.)...

ឧ. សត្វពស់វ៉ាក៏ជាសត្រូវនឹងមនុស្សយើងដែរ ៗ

ពោះ= ន. ឈើពោះ, ពោះវៀន, ពោះវៀនធំពោះវៀនតូច,

ឧ. កុំឲ្យកូនញុំាចំណីផ្ដួសផ្ដាសរាំខូចពោះខូចពុងៗ

ពន្លាក= ន. ដែកពន្លាក, ដាប់ទឹងពន្លាក, សំលៀងដែកពន្លាក

ឧ. ដាងឈើដាប់ឈើធ្វើដំណាប់ទឹងពន្លាក ៗ

បន្លៀក= កិ. ត្រីបន្លៀក, (ប្រើចំពោះតែត្រី)...

ឧ. ត្រីបន្លៀកច្រើនណាស់នៅក្នុងថ្លុកនេះ ៗ

ពន្លះ= កិ. ពន្លះស្បែក, ពន្លះឆ្អឹង, ពន្លះគ្នា...

ឧ. សាសន៍ចាមប្រសប់ពន្លះស្បែកគោណាស់ ៗ

បន្លាស់= ន. ធ្វើការមានបន្លាស់, ខោអាវមានច្រើនបន្លាស់...

ឧ. បងប្រុសខ្ញុំ មានខោអាវច្រើនបន្លាស់ណាស់ៗ

ពព្រុស= គុ. សពព្រុស, លឿងពព្រុស...

ឧ. សំពត់ខ្មៅនេះ បែកព្រុយឡើងសពព្រុស ៗ

ពព្រូស= ឧ.ស. ពព្រូសបំប្រុះ, ពព្រិសពព្រូស...

ឧ. មាន់បន្ទ្រះពព្រិសពព្រូសពេញតែក្នុងទ្រុង ៗ

ពាត= កិ. (ដាក់ពាសពីលើ) ចងពាត, វាយពាត, ដាក់ពាត

១. ជាន់នេះយកដែកសង្កសីមួយសន្លឹក ទៅក៏យ
ពាក់គ្រង់កន្ទន់ទទឹក ។

ពាទ្យ= ន.(អា.ថ.ពាត) ភ្លេងពិណពាទ្យ...

១.ភ្លេងពិណពាទ្យព្រះរាជទ្រព្យលេងពិរោះស្តាប់ៗ

អាពាធ=កិ.(អា.ថ.ពាត)(ឈឺ) ទ្រង់អាពាធ, មានអាពាធ...

១. ព្រះសង្ឃអង្គណាមានអាពាធ សូមនិមន្តទៅ
មន្ទីរពេទ្យព្រះសង្ឃនៅឯរាជធានីភ្នំពេញ ។

ពារ= កិ. (ប៉ះប្តូចន្ថិច) ពារជង្គង់, ពារគេពារឯង, ការពារ...

១. មនុស្សម្នាក់ដើរពារជង្គង់ឈើបែកជើង ។

ពៀរ= ន. កម្មពៀរ, ចងពៀរ, ពៀរវេរា...

១. កុំចងកម្មចងពៀរនឹងរាជ្ញើអ្វី ព្រោះគ្នានៅក្មេង
សេចក្តីណាស់ ។

ពី= ន. ពីនេះពីនោះ, ពីមួយទៅមួយ, ចេញពីផ្ទះទៅ...

១. គូសង្សារពីរនាក់នេះអង្គុយនិយាយគ្នាពីនេះពី-

នោះយ៉ាងរែកកយក្រោយពន្លឺព្រះចន្ទ្រនាថ្ងៃពេញបូណ៌មី ។

ពីរ= ប.សំ. (ចំនួន) ពីរនាក់, ពីរឆ្នាំ, ពីរទឹម, ពីរគូ...

ឧ. ឪពុកខ្ញុំកាត់ស្បែកជើងពីរសម្រាប់ទុកផ្លាស់ប្ដូរ

ពុត= ន. ធ្វើពុត, ដេញពុត, សម្លាប់ពុត...

ឧ. សិស្សខ្ជិលហាធ្វើពុតជាឈឺ រួចសុំច្បាប់អ្នកគ្រូឈប់ ។

ពុធ= ន. (អា.ថ.ពុត) ថ្ងៃពុធ...

ឧ. ថ្ងៃពុធខាងស្អែកនេះ ខ្ញុំនិងគ្រួសារខ្ញុំនាំគ្នាទៅ
លេងឯខេត្តបាត់ដំបង ។

ពុទ្ធ= ន. (អា.ថ.ពុត) ព្រះពុទ្ធ, ព្រះពុទ្ធអង្គ, ពុទ្ធបូជា, ពុទ្ធប្រវត្តិ

ឧ. ព្រះពុទ្ធអង្គទ្រង់និមន្តទៅទេស្នាប្រោសព្រះមាតា ។

ពត់= កិ. ពត់ដងសន្ទូច, ពត់ខ្សែលួស, ពត់ឈើឲ្យកោង...

ឧ. កុំពត់ឈើស្រឡៅ កុំប្រដៅស្រីខូច ។

ពុល= គុ. (អា.ថ.ពុល) ពុលសាបពុលឈាម, ហើមមុខពុលពោរ

ឧ. កុំវាយខ្ញុំច្រើនពេក វាពុលសាបពុលឈាមខ្ញុំអស់ហើយ ។

ពុល = គុ. ថ្នាំពុល, ពុលខ្លួច, ពុលលោក, ពុលឡាន...

ឧ. អ្នកធ្វើដំណើរតាមជលយានច្រើនតែពុលលោក

ពុម្ព = ន. (អា.ថ.ពុំ) បោះពុម្ព, ពុម្ពអក្សរ, រោងពុម្ព, ទំពុម្ព...

ឧ. រោងពុម្ពឧដុង្គស្រីស្ថិតនៅតាមផ្លូវវិថីព្រះសីហនុ ។

ពុំ = និ. ពុំចេះ, ពុំនៅ, ពុំដល់, ពុំបាច់, ពុំដឹង, ពុំលែងឡើយ...

ឧ. ខ្ញុំធ្វើអ្វីក៏ដោយពុំចេះត្រូវចិត្តចៅហ្វាយនាយខ្ញុំទេ ។

ពេចន៍ = ន. ពាក្យពេចន៍, សុន្ទរពេចន៍ ...

ឧ. ក្នុងអត្ថបទនេះគេសរសេរមានពាក្យពេចន៍ ពីរោះគ្រាះក្រាយល្អណាស់ ។

ពេច = ព.ផ្ស.(រំពេច=ន. ពពេច=ន.) មួយរំពេច, សត្វពពេច..

ឧ. សត្វពពេចទំលើមែកឫស្សី ស្រាប់តែមួយរំពេចនោះធ្លាក់មកដី ដោយគ្មានហេតុផលអ្វីសោះ ។

ពិច = ព.ផ្ស.(ពពិច=គុ.) សើមពពិច, ដីបែកពពិច, ពពិចពព្ចាច់

ឧ. ភ្លៀងប្រឹះៗយ៉ាងនេះមុខជាបែកដីសើមពពិចហើយ ។

ពេជ្រ= ន. មាសពេជ្រ, ទំហូពេជ្រ, បន្តោងពេជ្រ...

១. នៅពិធីបុណ្យផ្សេងៗ ស្ត្រីខ្មែរពាក់មាសពេជ្រគ្រប់ៗគ្នា ។

ពៃ= ន. (កូនល្អីតូចហើយរាក់) ១. កូនឯងយកស្រូវមួយពៃ

ទៅដូរនំញាំទៅ ហើយទុកខ្លះឲ្យឪពុកឯងផង ។

ពៃរ៍= ន. ទោសពៃរ៍.. ១. ខ្ញុំមិនយកទោសពៃរ៍អ្វីទេ ឲ្យតែ

វ៉ានិយាយត្រង់តាមសំនួរដែលខ្ញុំបានសួរវ៉ានោះ ។

ពោរ= គុ. ពេញពោរ, ពពឹកក្អែកពោរ, ពោរហូរហៀរ...

១. បុរសនេះដឹកស្រូវពោរទេះគោអូសស្ទើរពុំរួច

ពោធិ៍= ន.(អា.ថ.ពោ) ក្រមពោធិ៍, ដើមពោធិ៍, ពោធិ៍សាត់...

១. ដើមពោធិ៍ធំៗ ច្រើនដុះនៅក្នុងវត្តអារាម ។

ព្យួរ= កិ. ព្យួររូបថត, ចងព្យួរ, ព្យួរទោស, ព្យួរក...

១. ជនទុច្ចរិតនេះតុលាការព្យួរទោស ព្រោះគេបន្ធូនបាត់ៗ

ភ្ជួរ= កិ. ភ្ជួររាស់, ភ្ជួរស្រែចំការ, ភ្ជួរនឹងនង្គ័ល...

១. ព្រឹកនេះឪពុកខ្ញុំភ្ជួរស្រែបានតែមួយថ្នាលទេ ។

ព្រ័ត្រ= ន. ទាញព្រ័ត្រ, វេញព្រ័ត្រ, ព្រ័ត្រស្បែកក្របី, កាត់ព្រ័ត្រ

ឧ. នៅថ្ងៃចូលឆ្នាំថ្មី ប្រជាជនទាំងប្រុសទាំងស្រី ទាំងចាស់ទាំងក្មេងនាំគ្នាលេងទាញព្រ័ត្រ បោះអង្គុញ, ចោលឈូង លោតអន្ទាក់ ឬប្រៀងគគ្នាជាដើម ៗ

ព្រាត់= កិ. ព្រាត់ប្រាស, ព្រាត់ប្ដីប្រពន្ធ, ព្រាត់គូសង្សារ...

ឧ. គូព្រេងមិនព្រាត់ អាយុមិនអស់មិនស្លាប់ ៗ

ព្រិប= គុ. ទឹកភ្នែកព្រិបៗ, រស្មីព្រិបៗ, (ដំរីព្រិប= កិ.)

ឧ. រលឹមព្រិបៗ យ៉ាងនេះជាកសព្វដីល្អណាស់ ៗ

ព្រេប= ន. ដើមព្រេប, អំបោសព្រេប...

ឧ. បងប្រុសខ្ញុំទៅកាប់ដើមព្រេបមកធ្វើអំបោស ៗ

ព្រឹក= ន. ព្រឹកព្រហាម, ព្រឹកព្រាង, ព្រឹកមិញ, រាល់ព្រឹក...

ឧ. រាល់ព្រឹកខ្ញុំជួយធ្វើការម្ដាយខ្ញុំសិនទើបខ្ញុំទៅសាលា ៗ

ព្រឹក្ស= ន. ពោធិព្រឹក្ស, ព្រឹក្សា...

ឧ. ព្រះពុទ្ធជាម្ចាស់ ព្រះអង្គទ្រង់បានត្រាស់នៅ

ក្រោមដើមពោធិព្រឹក្ស ។

ព្រឹក្សា= ន. (ដើមឈើនានា) ព្រឹក្សានានា, ព្រៃព្រឹក្សា...

ឧ. នៅក្នុងព្រៃមានព្រឹក្សានានាដុះប្រជែងគ្នា ។

ប្រឹក្សា= កិ. (ពិគ្រោះ-ជំនុំ) ប្រឹក្សាគ្នា, ប្រឹក្សាការ...

ឧ. ការនេះចាំខ្ញុំប្រឹក្សាជាមួយគ្រួសារខ្ញុំសិន ។

ព្រឹត្តិ= ន. ព្រឹត្តិការណ៍នានា, ព្រឹត្តិការណ៍អន្តរជាតិ...

ឧ. ក្នុងសប្តាហ៍នេះមានព្រឹត្តិការណ៍ចំឡែកៗ ។

ព្រឹទ្ធ= គុ. (មានអាយុច្រើន-វែង) ចាស់ព្រឹទ្ធចាស់ព្រេង, ព្រឹទ្ធាចារ្យ, ព្រឹទ្ធសមាជិក, ចាស់ព្រឹទ្ធាចារ្យ ...

ឧ. ចូរយើងស្តាប់ហើយគោរពខ្លាចចាស់ព្រឹទ្ធាចារ្យ

ព្រុស= កិ. ភ្លៃព្រុស, និយាយដូចភ្លៃព្រុស, ភ្លៃព្រុសពោរ...

ឧ. ភ្លៃព្រុសមិនដែលខាំ ភ្លៃគ្រហឹមខាំជាប់កែង ។

ព្រួស= ១.ស. ព្រួសប្រាស, ព្នួសព្រួស, ដួលព្រួស...

ឧ. ខន្សែយពោលសម្រុកព្រៃព្នួសព្រួស ។

ព្រួស= ន. ដើមព្រួស, ផ្លែព្រួស ...

។. ដើមព្រួសច្រើនដុះនៅឯព្រៃភ្នំ ។

ព្រួញ= ន. (កូនសរ) ហើសដូចព្រួញ, បាញ់ព្រួញ, ព្រួញមាស

។. អ្នកចំបាំងនេះ បាញ់ព្រួញត្រង់ណាស់ ។

ប្រួញ= កិ. (រួញ, បង្រួញ) ប្រួញខ្លួន, ប្រួញសេចក្តី ...

។. ប្អូនខ្ញុំខ្លាចខ្មោចឡើងប្រួញខ្លួន ។

ព្រួល= ន. វែងព្រួល, រាំងព្រួល, ទស់ព្រួល, ត្រីព្រួល ...

។. អ្នកនេសាទនេះរាំងព្រួលមិនឲ្យត្រីចេញ ។

ព្រួល= គុ. ខ្មៅព្រួលៗ, ក្រហមព្រួលៗ, ផ្អិនព្រួលៗ ...

។. កន្ទួងនេះឡើងខ្មៅព្រួលៗ ចង់កជាពិស ។

ប្រួល= ប. ប្រែប្រួល. សំដីប្រែប្រួល ...

។. ចូរយើងកុំប្រែប្រួលសំដីរបស់យើងដែលបាន និយាយរួច ព្រោះមនុស្សគេយកសំដីដំរីគេយកភ្លុក ។

ព្រួស= កិ. ស្តោះព្រួស, ព្រួសពិស, ព្រួសទឹកមាត់...

ឧ. សម័យឥឡូវគេមិនចូលចិត្តនឹងគ្រូស្ដាះព្រួសទេ ។

ព្រោះ=កិ. ព្រោះស្រូវ, ព្រោះគ្រាប់ស្ពៃ, ព្រោះសណ្ដែក...

ឧ. អ្នកដាំបន្លែព្រោះគ្រាប់ស្ពៃនៅលើថ្នាលមួយ ។

ព្រោះ = និ. ពីព្រោះ, ព្រោះតែ, ព្រោះហេតុនេះ ...

ឧ. ព្រោះតែឯងហើយបានជាខូចការណ៍គេអស់ ។

ព្រៀប= គុ. ទឹកព្រៀបប្រាំង, សម្លព្រៀបឆ្នាំង ...

ឧ. ទឹកស្ទឹងឡើងព្រៀបប្រាំងដោយសារទឹកភ្លៀង

ប្រៀប=កិ.(ប្រដូច,ធូ) ប្រៀបផ្ទឹម,ប្រៀបស្មើគ្នា,ប្រៀបធៀប

ឧ. ប្រទេសកម្ពុជាយើង បើប្រៀបធៀបទៅនឹង
អារ្យប្រទេសឃើញថា... ។

ព្រាប= ន. សត្វព្រាប, ព្រាបនាំសារ, ផ្ទះព្រាប ...

ឧ. កងខេមរភូមិន្ទ មានបញ្ចឹមសត្វព្រាបមួយបែប
ទុកសំរាប់នាំសារនៅពេលទៅប្រតិបត្តិការឆ្ងាយៗ ។

ព្រេង= គុ. រឿងព្រេង, ព្រេងនាយ, គូព្រេង, ចាស់ព្រឹទ្ធ

ចាស់ព្រេង ...

ឧ. កាលពីព្រេងនាយមនុស្សពុំចេះខ្លាចគ្នាទេ ។

ប្រេង= ន. ប្រេងដូង, ប្រេងកាត, ប្រេងក្រវាញ, ប្រេងខ្យល់

ឧ. រថយន្តនេះដុតប្រេងសាំងឬប្រេងម៉ាស៊ុត ។

ព្រែ= ន. សម្ពត់ព្រែ, ព្រែលាត, ព្រែផ្កា ...

ឧ. សំពត់ព្រែមួយអានេះមានផ្កាមួយៗ ។

ប្រែ= កិ. (ត្រឡប់, ក្រឡាស់) ប្រែទឹកមុខ, ប្រែចិត្ត, ប្រែទំនុក

ឧ. បងប្រុសខ្ញុំចេះបកប្រែភាសាបរទេស ។

ព្រំ= កិ. ព្រំដំបូល, ព្រំផ្ទះ, , ព្រំសាលា ...

ឧ. ផ្ទះខ្ញុំភ្លៀងមកម្ដងៗ លេចតែត្រង់ព្រំ ។

ព្រំ= ន. ព្រំដែន, ព្រំប្រទល់, ព្រំដី, កំរាលព្រំ, ក្រាលព្រំ

ឧ. ពលទាហានជាអ្នកការពារព្រំប្រទល់ប្រទេស

ព្រហ្ម= ន. មុខព្រហ្ម, ស្ពានព្រហ្ម, ព្រហ្មវិហារធម៌, ព្រហ្មលិខិត

ឧ. ឪពុកម្ដាយតែងមានព្រហ្មវិហារធម៌ចំពោះកូន ។

ព្រះ= ន. ព្រះជាម្ចាស់, ព្រះពុទ្ធ, ព្រះទ្រង់ញាណ...

ឧ. ព្រះពុទ្ធទ្រង់និមិត្តព្រះអង្គជា... ។

ប្រះ= កិ. ប្រះដេក, ប្រះខ្លួនទំរេត, ប្រះដៃប្រះជើង...

ឧ. ក្មេងនេះម្តេចក៏ដេកប្រះដៃប្រះជើងយ៉ាងនេះ ?

ប្រាស= កិ. ព្រាត់ប្រាស, ប្រាសអាយុ, ប្រាសបាក...

ឧ. មនុស្សប្រាសបាកសីលធម៌នេះកុំសេពគប់ឡើយ ។

# ភ

ភក្តិ-ភ័ក្តិ= ន. ស្វាមីភក្តិ, មិត្រភក្តិ, ភក្តីភាព...

ឧ. យើងត្រូវមានស្វាមីភក្តិចំពោះព្រះមហាក្សត្រ ។

ភក្ត្រ-ភ័ក្ត្រ= ន. ព្រះភក្ត្រ, ទ្រង់មានព្រះភក្ត្រក្រៀមក្រំ...

ឧ. ភីលៀងយកទឹកមកស្រពព្រះភក្ត្រព្រះអង្គ ។

ភក្សា= ន. (អា.ថ.ភ័កសា) ភក្សាហារ, ស្វែងរកភក្សាហារ...

ឧ. នៅវេលាព្រះទិនករអស្តង្គតក្អាមបក្សីពត្រីបរ

ដូចជាទឹកទុយខ្ទិះស្រោកចេញស្នែងគេកក្បាហារ ។

ភប់ = កិ. (សេពគប់-ប្រសព្វ-រាប់អាន) គប់ប្រសព្វ...

១. យើងមិនត្រូវគប់ប្រសព្វនឹងមនុស្សទុច្ចរិតទេ ។

ភព = ន. (កំណើត) ចាប់ភព, ភពថ្មី, ពិភពលោក...

១. មនុស្សល្ងង់ច្រើនបន់ថា «ស្លាប់ឲ្យឆាប់ ៗ ទៅ នឹងបានទៅចាប់ភពថ្មីទៀត» ។

ភុង = ១.ស. ព្រួសភុង, បែកភុង...

១. នាងនេះទូលក្អមបែកភុងនៅលើក្បាល ។

ផុង = កិ. ជាប់ផុង, ផុងជើង, ផុងខ្លួនផុងប្រាណ...

១. ដើរឲ្យស្រួលបួលប្រយ័ត្នផុងជើងធ្លាក់ទៅដី ។

ភ្ជុំ = ប. ភ្ជុំ... ១. ក្នុងមួយឆ្នាំភ្ជុំតែម្ដងទេ យើងត្រូវចិញ្ចឹមអ៊ីកាន់ជូនដូនជូនជីតា និងឪពុកម្ដាយយើង ។

ភ្ជ័រ = កិ. ភ្ជ័រកាំបិត, ភ្ជ័រដែកផ្លៀងនង្គ័ល, ភ្ជ័រអាចម៍ល័ក្ត...

១. ឯងយកមៀនកាំបិតនេះទៅភ្ជ័រអាចម៍ល័ក្ត ។

ភ្ជួរ= កិ. ភ្ជួរដី, ភ្ជួររាស់, ភ្ជួរស្រែចំការ...

ឧ. គេភ្ជួរដីកប់រយហិកតានឹងម៉ាស៊ីនត្រាក់ទ័រ ។

ព្យួរ= កិ. ព្យួរសង្រែក, ព្យួរទោស ព្យួររណោងរណោង...

ឧ. អ្នកឡើងត្នោតមានព្យួរបំពង់បួនដប់នៅចង្កេះ ។

ភ្លក់-ភ្លក្ស=កិ. ភ្លក្សសំឡ, ភ្លក្សនំ, ភ្លក់លមើល...

ឧ. អ្នកស្រី! ភ្លក្សសម្លនេះលមើលតើសាបឬប្រៃ ។

ភ្លុក= ន. ភ្លុកដំរី, របស់ធ្វើពីភ្លុក, (អ្នកភ្លុកដុតខ្មោច)...

ឧ. មនុស្សគេយកសំដី ដំរីគេយកភ្លុក ។

ភ្លៀក= កិ (និយាយបានតែនឹងសត្វដំរីទេ) ភ្លៀកខ្លួន...

ឧ. ដំរីភ្លៀកខ្លួនរហ័សណាស់ ។

ផ្លៀក= កិ. (ត្រីមាត់) ត្រីផ្លៀក...

ឧ. ក្នុងត្រពាំងនេះមានត្រីផ្លៀកច្រើន ។

ប្លៀក=កិ.វិ. មើលប្លៀកៗ, សម្លឹងប្លៀកៗ...

ឧ. បុរសនេះសំឡឹងមើលគេប្លៀកៗមិនដាក់ភ្នែក ។

ភ្ងារ= គុ. សម្ងភ្ងារ, ភ្ងារមាត់ភ្ងារក, ភ្ងារៗ ...

១. អ្នកជម្ងឺនេះត្អូញថាភ្ងារមាត់គ្មានដឹងរសជាតិអ្វីសោះ ។

ប្ញៀវ= គុ· (រហ័សវក្វត) ប្ញៀវដៃបង្គួត ...

១. អ្នកជិះកង់ប្ញៀវដៃបង្គួតធ្លាក់ទៅក្នុងស្រែ ។

## ម

មគ្គ= ន. (អា.ថ.មាគ៌) មគ្គុទេសក៍, មគ្គផល, ផលមគ្គ ...

១. សម្ដេចឪជាអគ្គមគ្គុទេសក៍មួយដ៏ឆ្នើមក្នុងលោក

មាក់= ព.ផ្សំ. មាក់ក្ងៀ, មាក់ប្រាង, មាក់ប្រេង, មាក់ងាយ

១. ឯងមាក់ងាយខ្ញុំឃើញខ្លួនខ្ញុំទទ័លក្រមួ ?

មាន= កិ. មានប្រាក់, មានបាន, មានល្អមានអាក្រក់ ។

១. មានអ្នកខ្លះឈ្នានិសគេមិនចង់ឲ្យគេរកស៊ីមានបាន ។

មៀន= ន. មៀនកាំបិត, ដើមមៀន, ផ្លែមៀន ...

១. ដើមមៀនមួយដើមនេះមានផ្លែស្អុកស្កុះ ។

មា= ន. (ពូ) ឪពុកមា, មាមីង ...

ឧ. យូរៗ មានិងមីងខ្ញុំគាត់អញ្ជើញមកលេងផ្ទះខ្ញុំម្ដង ។

មារ=ន.(ដំណើរកាច់. ឧបសគ្គ)មារវៃជ្រក, មារពធិពជក្រុងមារ

ឧ. ពាញ់បានមកព្រះ ឈ្នះបានទៅមារ ។

មី= ន. (ដូចគុយទាវ) ឆាមី, មីទឹក, មីគោក ...

ឧ. ម្ដាយខ្ញុំប្រើខ្ញុំឲ្យទៅឆាមីមួយចានយកមកជូនគាត់ ។

មីរ= គុ. មីរដេរដាស, មីរត្រៀបត្រា, ច្រើនមីរ, ក្បាលឲ្យមីរ

ឧ. ថ្ងៃនេះមេឃមីរស្រទំដោយពពកខ្មៅមីរដេរដាស

មិត្ត-មិត្រ=មិត្តភក្ដិ, មិត្តទ្រុស្តមិត្ត, មិត្តភាព, មូលមិត្តជិតឆ្ងាយ

ឧ. មានមិត្តភក្ដិខ្ញុំជាច្រើន គេបាននាំគ្នាមកជួយ

ក្នុងពិធីបុណ្យនេះឲ្យអធិកអធមឡើង ។

មិទ្ធៈ= ន. (អា.ថ.មិតធ:)(ការដេកយ) ទ្រង់ព្រះមិទ្ធៈ ...

ឧ. ព្រះនេត្របើកមិនរួចសោះប្រហែលជាទ្រង់ព្រះ

មិទ្ធៈខ្លាំងណាស់ហើយ ។

មួ = កិ. (ខឹង) មុខមួ, មួម៉ៅ, មួមុខ ...

១. ចុះថ្ងៃនេះ លោកដូចជាមួម៉ៅក្ដៅក្រហាយអ្វីខ្លាំងម៉្លេះ

មួរ = ន. ស្រូវមួរ, ដកមួរ, ស្ទូងមួរ ...

១. ម្ដាយខ្ញុំដកសំណាបមួរយកទៅស្ទូងក្នុងត្រពាំង

ម៉ = ព.ផ្ស. សត្វគោម៉, គោហ្ម, ម៉ៃ ...

១. ខ្ញុំទិញម៉ៃមួយសទ្ទឹកយកមកជ្រលក់អាវនិងខោ

ហ្ម = ន. (អា.ថ.ម៉) ហ្មដំរី, គោហ្ម, ពេទ្យហ្ម ។

១. ហ្មដំរីនេះកាប់ដំរីទឹងកង្វេរមុតឈាមហោម ។

ម៉ត់ហ្មង-ហ្មត់ហ្មង = គុ. ល្អម៉ត់ហ្មង, ហ្មត់ចត់ ...

១. កូនក្រមុំនេះមានបុកពាល្អម៉ត់ហ្មង ។

ម៉ដ្ធ-ម៉ដ្ឋ = គុ. (ព.ផ្ទុ គគ្រាត, គគ្រើម) សាច់ម៉ដ្ឋ, ម្សៅម៉ដ្ឋ...

១. អ្នកស្រីនេះសាច់សម៉ដ្ឋឥតគ្មានស្នាកស្នាមទេ ។

ហ្មត់ = កិ. វិ. អស់ហ្មត់, ចាយហ្មត់, ហ្មត់លើង ...

១. យប់មិញមានចោរចូលមកលួចទ្រព្យសម្បត្តិ

ផ្ទះពួយឹមហ្មត់គ្មានសល់អ្វីបន្តិចបន្តួចឡើយ ។

ហ្មត់ចត់ = គុ. ធ្វើការហ្មត់ចត់, និយាយហ្មត់ចត់ ...

ឧ. ចូរធ្វើការឲ្យបានហ្មត់ចត់កុំធ្វេសប្រហែសឡើយ

ម៉ែ = ន. ឪម៉ែ, ម៉ែនិងកូន, កូនម៉ែ, ម៉ែក្មេក ...

ឧ. ខ្ញុំស្រឡាញ់ម៉ែឪខ្ញុំណាស់ព្រោះគាត់មានគុណ
លើរូបខ្ញុំជាយ៉ាងខ្លាំង ។

មេរុ = ន. (អា.ថ.ម៉ែ) ភ្នំព្រះសុមេរុ ...

ឧ. ព្រះអាទិត្យបាំងបាត់នឹងភ្នំព្រះសុមេរុ ។

មេរុ = ន. (អា.ថ.មេន) វាលព្រះមេរុ, ធ្វើមេរុ, បុណ្យមេរុ...

ឧ. សមាជជាតិ គេធ្វើនៅវាលព្រះមេរុខាងជើង
ព្រះមរមេកជវាំង ។

ម្រ័ក្សណ៍ = ន. (អា.ថ.ម្រាក់) លាបម្រ័ក្សណ៍, ខ្ទកម្រ័ក្សណ៍

ឧ. កញ្ចើនេះលាបខ្ទកម្រ័ក្សណ៍ឡើងខ្មៅស្រិល ។

ម្រាក់ = ន. (ពួក.ម៉ាក) កើម្រាក់, ខ្ញុំត្រូវជាម្រាក់នឹងវា ...

ឧ. អ្នកៗ ខ្ញុំសុំអ្នកធ្វើជាផ្ញើប្រាក់នឹងខ្ញុំបានឬទេ ?

# យ

យន់ = កិ. យន់ដំណេក, យប់យន់, យន់ជើង, យន់ត្របកភ្នែក

ឧ. យប់យន់ណាស់ទៅហើយ ខ្ញុំងងុយគេងណាស់ម៉ែ!

យន្ត-យន្ត្រ = ន. (អា.ថ.យន់) រថយន្ត, យន្តហោះ, យន្តដេរ

ឧ. យន្តហោះនេះហោះកំពស់ប្រហែលមួយពាន់ម៉ែត្រពីដី។

យ័ន្ត-យ័ន្ត្រ = ន. (អា.ថ.យាន់) គូរយ័ន្ត, សាក់យ័ន្ត ...

ឧ. ពូមីលសាក់រូបយ័ន្តក្បាលប្រាំបីពេញទាំងខ្លួន

យុត្តិធម៌ = ន. (អា.ថ.យុតតិ.) (ត្រឹមត្រូវ), យុត្តិធម៌ ...

ឧ. ក្រសួងយុត្តិធម៌សំរាប់ជំនុំជំរះគេខុសត្រូវជូនប្រជារាស្ត្រ

យុទ្ធ = ន. តយុទ្ធ, ប្រយុទ្ធ, យុទ្ធនាការ ...

ឧ. យើងត្រូវតយុទ្ធនឹងខ្មាំងយកជ័យជំនះឲ្យទាល់តែបាន

យល់ = កិ. យល់យោគ, យល់ព្រម, ពុំទាន់យល់, យល់ឃើញ

១. យប់មិញខ្ញុំទទួលទានដំណេកទៅយល់សប្តិឃើញល្អ

យុល = គុ. យុលមុខ, យុលហោប៉ៅ ...

១. គេនាំដាក់គ្រាប់ក្រួសឲ្យឡើងយុលហោប៉ៅទេ

# រ

អារក្ស = ន. (អា. ថ. រក្ខ) ជឿនអារក្ស, គោរពអារក្ស, ខ្លាចអារក្ស

១. សម័យឥឡូវនេះខ្មែរលែងជឿខ្លាចអារក្សទៀតហើយ

រាក់ = គុ. (ព. ផ្ទុ. ជ្រៅ) រាក់កំផែល, រាក់ទាក់, រាក់ជ្រៅ ...

១. ត្រពាំងទឹកនេះរាក់ណាស់ទៅហើយ ។

រង់ = កិ. រង់ចាំ, ឈររង់, ពារង់ ...

១. អ្នករង់ចាំខ្ញុំបន្តិចបានទេ? ខ្ញុំមានការបន្តិច ។

រង្គ = ន. (អា. ថ. រង់) (ជាមានសម្បុរលឿង) ជ្រលក់រង្គ,

រង្គសាល, លឿណរង្គ ...

១. នៅទីក្រុងមានរង្គសាលជាច្រើនសំរាប់សប្បាយ

រុងរឿង = គុ. សេចក្តីរុងរឿង, ធ្វើឲ្យរុងរឿង ...

ឧ.សម័យសម្តេចនរោត្តមសីហនុនគរកម្ពុជាយើងរុងរឿងណាស់ដោយព្រះរាជនយោបាយដ៏ឆ្នើមរបស់ព្រះអង្គ ។

រងុំ= ឧ.ស. រងុំៗ, និយាយគ្នាឮរងុំៗ ...

ឧ. អ្នកពល់គ្នា ជំនុំគ្នាឮសូររងុំៗ ខាងណោះ ?

រងំ= គុ. ភ្លេងឮរងំ, ឮឲ្យរងំ ...

ឧ. ក្រុមសិល្បៈតន្ត្រីនេះលេងឮសូរឲ្យរងំតាលក្លុ ។

រដ្ឋ= ន. រដ្ឋកម្ពុជា, រដ្ឋមន្ត្រី, សាធារណរដ្ឋ, ឯកអគ្គរដ្ឋទូត

ឧ. កម្ពុជរដ្ឋយើងបានចងមិត្តភាពជាមួយនឹងសាធារណរដ្ឋចិនប្រជាមានិត ។

រត្ន= ន. (អា.ថ.រតនៈ) រត្នត្រៃ, រតនត្រ័យ, បុរសរត្ន ...

ឧ.សម្តេចឪជាមហាបុរសរត្នយ៉ាងឆ្នើមក្នុងបច្ចុប្បន្ននេះ ។

រត់= កិ. រត់លួន, រត់ប្រណាំង, រត់ខ្ទិត, រត់លឿនខ្ទិត ...

ឧ. អត្តពលករយើងរត់ប្រណាំងឈ្នះគេ ។

រថ= ន. (អា.ថ.រត់) រថយន្ត, រថភ្លើង, រាជរថ ...

ឧ. រថយន្តឈ្នួលនេះផ្ទុកអ្នកដំណើរហួសចំណុះ ។

របស់= ន. របស់របរ, របស់ទ្រព្យ, របស់ខ្ញុំ...

ឧ. របស់ទ្រព្យទាំងនេះបានមកដោយការខំរក ។

របោះ= គុ. ព្រៃរបោះ, របោះ ៗ ...

ឧ. ក្មេងឃ្វាលគោនាំគ្នាដើរក្នុងព្រៃរបោះរកមើលឃ្មុំ ។

របា= ន. (ពង្សាវតារ) របាក្សត្រ, ស្តាប់របា, សូត្ររបាក្សត្រ

ឧ. ថ្ងៃនេះសិស្សត្រូវស្រូវរបាក្សត្រអំពី... ។

របារ= ន. របារជញ្ជាំង, វាយរបារ, ឈើរបារ ...

ឧ. ជាងផ្ទះកំពុងវាយរបារជញ្ជាំងផ្ទះមួយខ្នង ។

រលក= គុ. ភ្លឺរលក, ឡើងភ្លឺរលក, រលករលង់ ...

ឧ. បងស្រីខ្ញុំដុសក្តារក្រាលឡើងភ្លឺរលករលង់ ។

រលក= ន. រលកទឹក, រលកបោកច្រាំង, ពុលរលក ...

ឧ. ទឹកបឹងនេះខ្យល់បក់មកមានរលកបែកផ្កាត្រែង

លលក= ន. សត្វលលក, ពងលលក, លលកទាំងគូ ...

ឧ. សត្វលលកទំលើមែកឫស្សីរោវយ៉ាងពីរោះ ។

រស= ន. (អា.ថ.រស់) រសជាតិ, គន្ធរស, ឱជារស ...

ឧ. សម្លនេះមានឱជារសឆ្ងាញ់ពិសាណាស់ ។

រស់= កិ.(ព.ផ្ន.ស្ងាប់) រស់រាន, ស្ងាប់រស់ជាមួយគ្នា, នៅរស់

ឧ. ខ្ញុំរស់រានមានជីវិតក៏ដោយសារតែលោក ។

រួស= គុ. រួសរាយ, រួសរាន់, គោរួស, រួសមាត់រួសក, ឆ្នាំងរួស.

ឧ. ប្រពន្ធខ្ញុំរារួសមាត់រួសកចំពោះភ្ញៀវណាស់ ។

រាក= កិ. រាករូស, រាកអាចម៍, រាកនោម, រាកពង ...

ឧ. មេមាន់ខ្ញុំរាកពងពេលនៅកណ្ដាលវាលស្មៅ ។

រាគៈ= ន. (អា.ថ.រាគគៈ) ភ្លើងរាគៈ, រាគៈគ្របសង្កត់, រាគចរិត

ឧ. បុរសនេះត្រូវរាគៈគ្របសង្កត់ដើបមុខវលងរួបហើយ

បំរៀក= ន. បំរៀកស្មៅ, បំរៀកស្លឹក, បំរៀកឫស្សី ...

ឧ. សត្វបក្សីពាំបំរៀកស្មៅយកទៅធ្វើសំបុក ។

រាង= ន. រាងពៅ, រាងប្អូនស្រី, រាងក្រអាញ, រាងស្តើង...

ឧ. ក្រដាសក្រាស់នេះរាងប្អូនស្រីទ្រវែង ។

រាង= គុ. រាងចាល, រាងហើយ, រាងហើយឬនៅ...

ឧ. ខ្ញុំរាងចាលលែងប្រព្រឹត្តអាក្រក់ដូចនេះទៀតហើយ ។

រៀង= កិ. ឈររៀងគ្នា, លេខរៀង, រៀងរាបដរាបមក ...

ឧ. ដើមស្វាយដុះរៀងៗគ្នាជាជួរៗលេខរៀងពី ១ ដល់..

រាប= កិ. រាបបាយ, រាបទឹកសម្ល, ទឹករាបពេញស្រែ ...

ឧ. យប់មិញមានភ្លៀងមួយមេ មានទឹករាបពេញស្រែ

រាជ= ន. រាជទ្រព្យ, រាជបុត្រ, រាជសព្ទ, រាជរថ ...

ឧ. ព្រះរាជឱរសព្រះអង្គមុខជាស្នងរាជ្យពីព្រះអង្គហើយ

រាជ្យ= ន. ព្រះខ័នរាជ្យ, សោយរាជ្យ, មកុដរាជ្យ ...

ឧ. ព្រះបាទសុរាម្រិតទ្រង់ឡើងសោយរាជ្យតពី

ព្រះបាទនរោត្តមសីហនុ ។

រាន= ន. (កូនគ្រែ) រានហាល, រានបាយ, រានឈើ ...

ឧ. អ្នកលក់បន្លែដាក់បន្លែលើរានខ្ពស់ពីដី ។

រាន= កិ. (កាប់គាស់) រានព្រៃ, រានដីស្រែចម្ការ ...

ឧ. ឪពុកខ្ញុំរានព្រៃយកដីធ្វើស្រែចម្ការ ។

រៀន= កិ. (ស្វាធ្យាយ) រៀនសូត្រ, ខំរៀន, រៀនធ្វើលេខ ...

ឧ. សិស្សណាៗស្វាហាប់រៀនសូត្រមុខជាប្រឡងជាប់ ។

រាប= គុ. (ព.ផ្ទ.ក្រហេងក្រហូង) រាបស្មើ, រាបសា, រាបទាប

ឧ. ត្រូវចេះប្រើសំដីរាបសាទៅកាន់អ្នកដទៃ ។

រៀប= កិ. រៀបរាប់, រៀបចំ, រៀបទុកដាក់, រៀបមង្គលការ

ឧ. មេផ្ទះត្រូវចេះរៀបចំទុកដាក់ឲ្យមានសណ្ដាប់ ។

រាម= ន. (ឈ្មោះស្ដេចមួយអង្គក្នុងរឿងរាមកេរ្ដិ៍), ព្រះរាម ...

ឧ. ព្រះរាមលើកពលសកលយោធាតាមនាងសីតា

រៀម= ន. (បង) រៀមច្បង, សម្ដេចព្រះរៀម ...

ឧ. ចូរស្ដាប់រៀមច្បងយើងកាលណាអត់ពីឪពុកម្ដាយ ។

រាល= កិ. រេលរាល, រាលដាល, ឆេះរាល ...

ឧ. កុំទីងកលដាលដល់គេឯងដែលគេមិនដឹងខ្លួនៗ

វៀល=កិ. វៀលកែ, កាំភ្លើងវៀលកែ ...

ឧ. ទុកកាំភ្លើងឲ្យស្រួលបួលប្រយ័ត្នវៀលកែត្រូវគេឯង

វៀល=ន. ប្រាក់វៀល, ក្រដាសប្រាក់ ៥ វៀល, ប្រាក់វៀល

ឧ. ម្ដាយខ្ញុំយកប្រាក់វៀលសុទ្ធដប់ណែនទៅជួល

ជាងធ្វើផ្ដិល ជើងពាន និងប្រអប់បារី ៗ

រាវ= ន. (ប្រដាប់ដាក់ចាន) រាវចាន, ដាក់ចានក្នុងរាវ ...

ឧ. អូនអើយ! ចាននៅក្នុងរាវម្ដេចនៅរណ្ដំគ្នា ៗ

រាវ= គុ. (ព.ផ្ទ.ខាប់) វត្ថុរាវ, បបររាវ, ទឹកស៊ីអ៊ីវរាវ ...

ឧ. ប្រេងដូង, ប្រេងកាតទឹកត្រីសុទ្ធតែជាវត្ថុរាវ ៗ

វៀរ= គុ. (ព.ផ្ទ ត្រមោង.ធំ) ពងវៀរ, វៀរពុង, ចង្កេះវៀរ..

ឧ. បន្ទោលរទេះនេះពងវៀរតូចហើយងទៅខាងចុងៗ

រាស់=កិ. ក្ឈួររាស់, រាស់ដី, រាស់ទឹងរនាស់...

ឧ. ពូខ្ញុំគាត់ទៅខ្ចីរនាស់គេយកមករាស់ស្រែ ៗ

រ៉ស់ = ន. ត្រីរ៉ស់, ឆៀតរ៉ស់, ស្ងោរត្រីរ៉ស់ ...

១. ម្ដាយខ្ញុំគាត់ទៅផ្សារទិញត្រីរ៉ស់យកមកធ្វើឆៀត

រា = កិ. រាដៃ, រាជើង, រារង់, ចិត្តរារែក ...

១. បើមិនជួយបូកជួយចែវកុំយកជើងរាទឹក ៗ កុំព

មុខដឹង កុំខទឹងមុខសឹក ៗ

រាហ៊ុ = ន. (អា.ថ.ភ) ថ្ងៃរាហ៊ុ, រាហ៊ុចាប់ចន្ទ ...

១. តាមក្បួនហោរាសាស្ត្រ យប់នេះនៅវេលាម៉ោង

២០ និង៣០ នាទី នឹងមានរាហ៊ុចាប់ចន្ទជាមិនខាន ៗ

រឹត = កិ. (ធ្វើឲ្យតឹង) រឹតបំណង, រឹតរូត, (ស៊ីករឹត = ន.)...

១. ឯងរឹតបំណងវាឲ្យតឹងប្រយ័ត្នវាដោះរបូត ៗ

រិទ្ធិ – ឬ ឫទ្ធិ = ន. រិទ្ធិអំណាច, សំដែងរិទ្ធិ, បុញ្ញឫទ្ធិ, ឫទ្ធានុភាព

១. ដោយអំណាចរិទ្ធានុភាពនៃព្រះអង្គ សត្រូវ

បាក់បបខ្ទបខ្ទាចទាំងអស់ ៗ

រុក = កិ. រុកមួយចង្អុលដៃ, រុកគួន, រុករើ, រុករាន ...

ឧ. ព្រានដើររុកកានទន្ទ្រានព្រៃ ដើម្បីស្វែងសត្វម្រឹគ ។

រុក្ខ= ន. (អា.ប.រុកខៈ) រុក្ខជាតិ, រុក្ខានានា...

ឧ. នៅផ្លូវក្បែររុក្ខជាតិនានាលាស់ស្លឹកខៀវខ្ចី ។

រុត= កិ. រុតត្រី, យកអន្ទ្រុតទៅរុតត្រី...

ឧ. គេយកអន្ទ្រុតទៅរុតត្រីនៅក្នុងបឹងក្បែរភូមិ ។

ពិរុទ្ធ= គុ. (អា.ប.ពិរុធ) ត្រូវពិរុទ្ធ, ជាប់ពិរុទ្ធ, ពាក្យពិរុទ្ធ...

ឧ. អ្នកមុខជាជាប់ពិរុទ្ធគេមិនខានឡើយ ។

រុះ= កិ. រុះរើ, រុះរោល, រុះផ្ទះសាជាថ្មី...

ឧ. កុំរុះរើអីវ៉ាន់ទាំងនេះប្រយ័ត្នខុសបំណាំដៃគេ ។

រូស= កិ. រូសបន្លា, រូសទឹងដៃកអន្ទ្រូស, រូសទឹងលួស...

ឧ. ឯងយកដៃកអន្ទ្រូសមករូសឈើនេះឲ្យស្មើជ្រុង

រុន= ន. (ស្រដៀងដើមកក់) ដករុន, កន្ទេលរុន...

ឧ. ពូខ្ញុំគាត់ទៅដករុនយកមកត្បាញកន្ទេល ។

អរុណ=ន. (អា.ប.អរុន) (ព្រះអាទិត្យ) អរុណរះ...

ឧ. អរុណរះនៅទិសបូព៌ា ហើយអស្តង្គតនៅទិសបស្ចិម

រន្ធ = ន. រន្ធក្តាម, រន្ធបង្រិត, រន្ធកណ្ដៀរ...

ឧ. ស្រមោចនាំគ្នាជញ្ជូនគ្រាប់ស្រូវអង្ករចូលក្នុងរន្ធ

រុំ = កិ. រុំដំបៅ, រុំមុខ, រុំរបួស, រុំក...

ឧ. ខ្ញុំសព្វថ្ងៃនេះជំពាក់គេរុំកោះរុំស្លូតហើយ ៗ

រម្យ = គុ. (អា.ថ.រំ) សមរម្យ, រម្យទម, ឫកពាសមរម្យ...

ឧ. ពង់ពៅនាងនេះល្មមសមរម្យនឹងកូនឯងហើយ ៗ

រំ = ព.ផ្ស. រំលេច, រំលង, រំចង់, រំបេក, រំលោភ...

ឧ. យើងមិនត្រូវរំលោភលើសិទ្ធិអ្នកដទៃឡើយ ៗ

រំលិច = ន. (ដីទម្លាប់មានទឹកលិច) ខាងជើងរំលិច, ទឹករំលិច

ឧ. ស្រីៗនាំគ្នាទៅដងទឹកនៅរំលិចខាងត្បូងភូមិ ៗ

រំលេច = កិ. (ធ្វើឲ្យលេចឡើងមើលឃើញ) រំលេចក្បាច់...

ឧ. ហោជាងព្រះវិហាររំលេចដោយក្បាច់រចនាផ្សេងៗ

ឫក = ន. (មារយាទ.កិរិយា) ឫកល្អ, ឫកអាក្រក់, ឫកថោក,

ឧ. ស្រីនេះមានឫកពាសុភាពល្អណាស់ ។

ឫក្ស= ន. (ជោគ.មង្គល.សួស្ដី) រកឫក្ស, ថ្ងៃមានឫក្សល្អ...

ឧ. ថ្ងៃនេះជាថ្ងៃមានឫក្សល្អ គួរតែយើងទៅ... ។

# ល

លក្ខណ៍-លក្សណ៍=ន. គ្រប់លក្ខណ៍, ខាតលក្សណ៍...

ឧ. កុមារីតាំងតួន ចូរនាងវៀសវាងពាក្យដំនៀល ថា «ស្រីខាតលក្ខណ៍» ។

ល័ក្ខ-លក្ស=ន. (កំណត់-សំគាល់-ចំណាំ) លក្ខ័ណ្ឌ, លក្ស ឈើចំណាំ, និយាយមានល័ក្ខ័ណ្ឌ ...

ឧ. សំដីរបស់លោកនេះ មានល័ក្ខ័ណ្ឌល្អណាស់ គួរយើងស្ដាប់ឲ្យបានហើយ ។

ល័ក្ដ-ល័ខ =ន. ល័ក្ដជុំកន្ទន់, អាចម៍ល័ក្ដ, ល័ខខៀវ, ល័ក្ដ លឿនទុំ, ពោតល័ខ, ម្ទេសល័ក្ដ, បេកល័ខ, ចងល័ក្ដ...

ឧ. កូនសិស្សលោក ទៅទិញល័ក្ដពណិក្រាក់ខ្ទ

មកដ្រលក់ស្បង់ចីពរប្រគេនលោកគ្រូ ។

លាក់= កិ. លាក់ពុត, លាក់ទុក, លាក់លៀម, លាក់កំនួច...

ឧ. មនុស្សខូចច្រើនលាក់ពុត មិនសូវនិយាយត្រង់ទេ

លង់= កិ. លង់ទឹក, លង់គំនិត, លង់លិច, លង់ចិត្ត...

ឧ. ធ្វើដូចម្ដេចបើខ្ញុំលង់ចិត្តលង់គំនិតទៅហើយ ។

លុង់= កិ. (ជីក) លុង់ដី, លុង់ជម្រក, លុង់គល់ឈើ...

ឧ. ក្មេងៗនាំគ្នាលុង់ក្ដីស្រែធ្វើអន្ទង់ឲ្យត្រីចូល ។

លន់= គុ. លន់តួទោស, លើសលន់, លប់លន់, ទ្រលន់...

ឧ. ខ្ញុំសុំលន់តួទោសពីបងម្ដង ទៅចុះធ្វើម្ដេច... ។

លុន= កិ. (បោល) សេះលុន, លុនឲ្យលឿន...

ឧ. សេះតាម៉ីជិះ លុនហុយដីទ្រលោម ។

លប់= ន. (ប្រដាប់សំរាប់ប្រមាញ់) ដាប់លប់, ដាក់លប់...

ឧ. លលកនេះជាប់លប់របស់បងខ្ញុំ ។

លុប= កិ. (ធ្វើឲ្យបាត់មើលមិនឃើញ) លុបដី, លុបអក្សរ...

ឧ. សិស្សម្នាក់ៗត្រូវមានដីឡុបសំពប់លុប ។

លលក=ន. លលកញីឈ្មោល, លលកស, លលកវង់រពីកោះ

ឧ. គេយកលលកឈ្មោលទៅទាក់យកលលកព្រៃ ។

រលក=ន. រលកអន្លង់, រលកបែកផ្កាត្រើន, ពុលរលក...

ឧ. ថ្ងៃនេះសមុទ្រស្ងាត់ច្រៀបគ្មានខ្យល់រលកសោះ ។

លលា=គុ. (ផ្ទុក-ពក្លីពក្លើ) មនុស្សលលា, អាលលាតែ...

ឧ. មនុស្សលលានេះដើរនិយាយតែម្នាក់ឯង ។

លលាដ៍=ន. លលាដ៍ក្បាល, លលាដ៍ដូង...

ឧ. ឆ្អឹងលលាដ៍ក្បាលបន្ទំជាប់គ្នាកងជាប្រអប់មួយ

រលា=គុ. រលាបំណង, រលាខ្សែអំបោះ...

ឧ. ប្អូនខ្ញុំធ្វើឲ្យរលាលួសមួយរមូរយ៉ាងធំ ។

លស់=កិ. (គង្វ-លើគង្វ) លស់លា, គ្រុនលស់, លស់ចោល

ឧ. សូមលោកមេត្តាលស់លាត្រាប្រណី ឲ្យខ្ញុំបាទផង ។

លោះ=កិ. (យកមកវិញ) លោះរបស់, លោះដៃ, លោះខ្ញុំបំរើ

ឧ. បង់ល្អមទៅលោះកូនមកវិញហើយ ឲ្យនៅខ្ញុំ
គេដល់ណាទៀតបើវាធំពេញរូបពេញកង់ហើយ ។

ល្ហួស= កិ. លួសមែកឈើ, លួសមែកឬស្សី លួសខុស...

ឧ. ក្មួយខ្ញុំវាលួសមែកឈើយកមកឲ្យម្ដាយវាទុកដុត ។

ល្ហួស= ន. លួសដែក, លួសសំណ, លួសបន្លា, ខ្សែលួស...

ឧ. ផ្ទះខ្ញុំមានរបងលួសបន្លាព័ទ្ធជុំវិញជារបង ។

លាង= កិ. លាងដៃ, លាងជើង, លាងចាន...

ឧ. មុនបរិភោគអាហារត្រូវលាងដៃឲ្យស្អាតសិន ។

លៀង= កិ. (ចិញ្ចឹម-) លៀងជីវិត, ស៊ីលៀង, លៀងអារក្ស...

ឧ. ផ្ទះនេះយប់មិញគេជប់លៀងអាហារដល់ភ្ញៀវ

លាន= ប.សំ. មួយលានមាន ១០០ ម៉ឺន, ពីរលានរៀល...

ឧ. ឆ្នាំនេះខ្ញុំមានភ័ពសំណាងបានត្រូវឆ្នោត១លាន

លាន= ន. លានសមរភូមិ, ព្រះលានខាងមុខ, លានបោកស្រូវ

ឧ. នៅលើទីលានប្រយុទ្ធគេឮសូរតែសម្រែកជ័យឃោស

លៀន=កិ.(លូតផុតចេញ) លៀនអណ្ដាត, លៀនក្អែក...

ឧ. ក្មេងមិនស្អាត សំបោរលៀនចេញមក ហើយ យកខ្នងដៃជូតរួចយកមកជូតនឹងខោអាវ ។

លាប=កិ. លាបប្រេងលាបម្សៅ, លាបពណ៌, លាបមុខ...

ឧ. ផ្ទះខ្ញុំជួលជាងលាបពណ៌សព្វកន្លែងទាំងអស់ ។

លាភ=ន. មានលាភ, អត់លាភ, លាភធំ, លាភតូច...

ឧ. អ្នកមុនកំសោយ អ្នកក្រោយមានលាភ ។

លៀប=ន.(ឈើក្នុងពួកជ្រៃ) ដើមលៀប, ស្លឹកលៀប...

ឧ. ប្អូនស្រីខ្ញុំទៅបេះត្រួយលៀបយកមកធ្វើអន្លក់

លាស=គុ.(ស្នែងគោចុះចុះក្រោម) ស្នែងលាស...

ឧ. ពូខ្ញុំមានគោស្នែងលាសមួយនឹមដូចគ្នាបេះបិទ

លៀស=ន. លៀសហាល, ឆាលៀស, ករលៀស...

ឧ. ក្មេងៗនាំគ្នាទៅករលៀសនៅក្នុងបឹង ។

លិប=ន.(អា.ថ.ឡូប) ទិសខាងលិច, ខាងលិចផ្ទះ...

ឧ. ព្រះអាទិត្យអស្តង្គតទៅទិសខាងលិច ។

លិប= កិ. (ចូរចំណាំ=លិចបាត់មើលមិនឃើញ) លិចលង់, ទូកលិចក្នុងទឹក, លិចបាត់...

ឧ. សូវស្លាប់បាកុំឲ្យតែស្លាប់មេ សូវលិចទូកកណ្ដាលទន្លេកុំឲ្យតែភ្លើងឆេះផ្ទះ ។

លេប= កិ. (ចូរចំណាំ= លេចឡើងឲ្យមើលឃើញ) លេចចេញ, លេចឡើង, លេចផុត, លេចមុខលេចមាត់...

ឧ. ទឹកឡើងលិចព្រៃព្រឹក្សានានា នៅសល់តែចុងលេចឡើងផុតពីផ្ទៃទឹក ។

លិទ្ធ= កិ. លិទ្ធប្រមុះ, ក្រយៅគោលិទ្ធ, លិទ្ធជើងលិទ្ធដៃ...

ឧ. នំនេះមានរសជាតិណាស់ ខ្ញុំទទួលទានឆ្ងាញ់លិទ្ធមាត់លិទ្ធក ។

លិត=ព.ផ្ស.(ព្រលិត=ន.) ព្រលិតរំបង់, ព្រលិតគ្រគួន...

ឧ. ក្នុងបឹងនេះមានគ្រគួនព្រលិតរំបង់ដុះណែន ។

លុត= កិ. លុតក្រាប, លុតជង្គង់...

១. លោកគ្រូដាក់ទណ្ឌកម្មឲ្យលុតជង្គង់ដល់សិស្ស ណាដែលខ្ជិលរៀន ។

លត់= កិ. លត់ភ្លើង, លត់កំហឹង, លត់ធាតុ...

១. ចូរអ្នកលត់ភ្លើងបង្ក្រាននៅពេលណាអ្នកដណ្តាំ ស្ងោរបាយហើយ ធ្វើយ៉ាងនេះដើម្បីការពារអគ្គិភ័យ ។

លួង= កិ. លួងលោម, លួងចិត្ត, លួងប្អូនកុំឲ្យយំ...

១. បុរសនេះចេះនិយាយលួងចិត្តប្រពន្ធមិនឲ្យខឹង

ហ្លួង= ន. ក្រុមហ្លួង, អាជ្ញាហ្លួង...

១. ហ្លួងដែលសោយរាជសម្បត្តិសព្វថ្ងៃទ្រង់ព្រះនាមអ្វី?

លេស=គុ. អាងលេស, យកជាលេស, ធ្វើជាលេស...

១. ឯងកុំយកកូនក្មេងតូចមួយមកធ្វើជាលេស ។

លេះ-លែះ=ន. គ្មានលេះអី, បានលេះអី, រកលេះគ្មានទេ...

ឧ. អស់ម្ហូបអាហារទៅហើយអ្នកក្រោយបានលេះអីស៊ីៗ

លុំ= (ពាក្យនេះគ្មានប្រើទេ) ៗ

លំ= កិ.វិ. ធ្វើការលំៗ, ផ្លូវលំ, ព្រាស់ឈើលំ...

ឧ. កុំធ្វើការលំៗ យ៉ាំងហ្នឹងពុំបានការទេ ៗ

លំ= ព.ផ្សំ. លំនៅ, រលំ, លំពែង, លំពង់, លំអង, លំហែ, លំអ

ឧ. សូមអញ្ជើញទៅតាមលំដាប់លំដោយគ្នាកុំបីខានៗ

ល្បះ= ន. ល្បះឃ្លា, សរសេរមានល្បះឃ្លា, មានឃ្លាមានល្បះ..

ឧ. សិស្សកំផិលសរសេរគ្មានល្បះឃ្លាបន្តិចសោះ

ល្បាស់= ន.(ស្មឹកដែលទើបលាស់) ល្បាស់ព្រេច, ល្បាស់ស្ពៅ, ល្បាស់ស្មឹកឈើ...

ឧ. នៅដើមឆ្នាំដែលមានភ្លៀងធ្លាក់ជាលើកដំបូង រុក្ខជាតិផងទាំងឡាយលាស់ល្បាស់ខ្ចីខៀវស្រងាត់ៗ

# វ

វង់= ន. ពេញវង់, កកវង់, ល្បែងគប់វង់...

ឧ. ក្នុងពិធីបុណ្យនេះមានក្មេងជាច្រើនវង់មកលេង ជូនជាកំសាន្តដល់ទស្សនិកជនលុះអធ្រាត្រ ។

វង្ស = ន. វង្សត្រកូល, វង្សានុវង្ស, ពូជពង្សវង្សត្រកូល...

ឧ. ក្មេងនេះពូជពង្សវង្សត្រកូលក៏គ្រាន់បើដែរ ។

វដ្ដ = គុ. (អា.ថ.ពាក់) (ដែលវិល) វដ្ដសង្សារ, វដ្ដទុក្ខ...

ឧ. មនុស្សរស់នៅក្នុងវដ្ដសង្សារនេះ តែងតែវិល កើតវិលស្លាប់ជាធម្មតា ។

វឌ្ឍនៈ = ន. (អា.ថ.ពាក់ឈេៈនៈ) វឌ្ឍនធម៌, វឌ្ឍនាការ...

ឧ. ព្រះអង្គទ្រង់មានវ័យវឌ្ឍនាការ ។

វ័ធ = កិ. (អា.ថ.ពាក់) ក្របីវ័ធ, គោវ័ធគ្នា, ជ្រូកព្រៃវ័ធ...

ឧ. គោវ័ធគ្នាបាក់ស្នែងឈាមហូរហាម ។

វត្ត = ន. (អា.ថ.ពាក់) វត្តនៅភូមិខ្ញុំ, វត្តមហាមន្ត្រី...

ឧ. ឧបាសក ឧបាសិកានាំគ្នាទៅសុំសីលឯវត្ត ។

វត្ស.វត្សរ៍ = ន.(អា.ថ.ពាក់) បៀវត្ស, សតវត្សរ៍...

ឧ.វត្តនេះកសាងឡើងជាច្រើនសតវត្សមកហើយ ។

បវត្តិ-ប្រវត្តិ= ន.(អា.ថ.ប:វាត់.ប្រវាត់) (សាវតារ) ពុទ្ធបវត្តិ, ប្រវត្តិសាស្ត្រ, ប្រវត្តិនគរ, ប្រវត្តិនៃសព...

ឧ.សម្ដេចឪទ្រង់មានកេរ្តិ៍ឈ្មោះល្បីល្បាញក្នុងប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា ។

វាត់= កិ. វាយវាត់, វាត់មួយរំពាត់, វាត់ដងសន្ទូច...

ឧ.ខ្ញុំវាត់ដងសន្ទូចឃើញត្រីជាប់នឹងផ្លែសន្ទូច ។

វ័ណ្ដ-វ័ណ្ណ=ន.ឬកិ. (អា.ថ.វ៉ន់) វ័ណ្ណថាំង, វ័ណ្ណផាឌិប, (វ័ណ្ដកន្ទុប=កិ.)...

ឧ. តាលាងយកផ្ដៅមកបិតធ្វើវ័ណ្ដថាំងរែកទឹក ។

វាន់= ព.ផ្ស. (រង្វាន់=ន.) បែករង្វាន់, រង្វាន់ខាន់ហៅ...

ឧ សិស្សណាពូកែជាងគេត្រូវបានរង្វាន់ច្រើន ។

វា= បុ.ស. គ្នាវា, វាទៅឯណា? វាហ្នឹងខូចណាស់...

ឧ. គូកនពីរនាក់នេះកៀកគ្នាវាដើរលេង ។

វារ= កិ. កូនក្មេងវារធ្លាក់ដី, វារដើរបួន, វារទៅវារមក...

ឧ. គ្រឡាបវារទៅ ទើបល្ពៅវារមក ។

វៀរ= កិ. វៀរចាក, វៀរលែង, វៀរតែ...

ឧ. ខ្ញុំនៅតែទៅជាដរាប វៀរលែងតែទីនោះមាន គ្រោះថ្នាក់ដល់ជីវិត ។

វាង= គុ. ផ្លូវវាង, វាងវៃ, ប្រាជ្ញាវាងវៃ...

ឧ. កូននេះមានបញ្ញាវាងវៃជាងក្មេងឯទៀត ។

វៀង= ន. (ក្រុង-រាជធានី) វៀងចន្ទន៍, វរវៀងជ័យ...

ឧ. រាជធានីប្រទេសលាវឈ្មោះវៀងចន្ទន៍ ។

វាច= កិ. វាចស្រូវ, វាចឲ្យស្មើ, វាចដីរេបង...

ឧ. ម្ដាយខ្ញុំវាចស្រូវហាលឲ្យផ្ទិនស្មើ ។

វៀច= គុ. (ព.ផ្ទុ.ត្រង់) វៀចវេរ, ផ្លូវវៀច, ចិត្តវៀច...

ឧ. ផ្លូវវៀចកុំបោះបង់ ផ្លូវណាត្រង់កុំដើរហោង ។

វាត= កិ. វាតវង់, វាតទី, វាតកន្លែងខ្លួក, វាតដីស្រែ...

ឧ. ក្មេងៗ ពាក់វែនលេងល្បែងលោតអន្ទាក់ ។

វិវាទ = ន. កើតវិវាទទទឹងគ្នា, មានវិវាទ, វិវាទការណ៍...

ឧ. គូវិវាទនេះមិនសុខចិត្តនឹងតុលាការកាត់សេចក្ដី ។

វាល = ន. វាលស្រែ, វាលស្មៅ, វាលល្ហល្ហេវ...

ឧ. នៅតាមដងផ្លូវគ្មានព្រៃទេ មានសុទ្ធតែវាល ។

វៀល = កិ. វៀលសាច់ឈើ, វៀលកអាវ, វៀលឲ្យប្រហោង..

ឧ. ជាងឈើវៀលក្ដារធ្វើក្បាច់រចនាលំអកុដិ ។

វិច = កិ.វិ. បត់វិចៗ, វេចៗ...

ឧ. គោបត់កន្ទុយវេចៗ ។ ទង់ជ័យបត់វេចៗ ។

វេច = កិ. វេចនំ, វេចសំពាយ, វេចបង្វិច ...

ឧ. ចុះឯងវេចសំពត់អាវគិតទៅណាហ្នឹង?

វេជ្ជ = ន. (អា.ថ.វេចជៈ) វេជ្ជសាស្ត្រ, វេជ្ជបណ្ឌិត...

ឧ. លោកវេជ្ជបណ្ឌិតកំពុងតែពិនិត្យអ្នកជម្ងឺ ។

វិញ = និ. វិលវិញ, ទៅវិញទៅមក, ត្រឡប់មកវិញ ...

១. បើមាក់ត្រឡប់មកពីផ្សារវិញ ទិញនំបុ័ងផ្ញើខ្ញុំផង

វៀញ= កិ. វេញខ្សែគោ, វេញធ្នូមួយ, វេញអំបោះ ...

១. គេយកជក់ត្នោតវេញធ្វើជាខ្សែគោ ។

វិហា= ន. (អា.ថ.វិហា៏) (អាកាស) អាកាសវិហា ...

១. នៅលើអាកាសវិហាមានពពកខ្មៅមីរដេរដាស

វិហារ= ន. (អា.ថ.វិហា៏) ព្រះវិហារ, បុណ្យឆ្លងព្រះ វិហារ...

១. ព្រះវិហារស្ថិតនៅចំកណ្ដាលទីធ្លាវត្ត ។

វៃ= គុ. វាងវៃ, ឆ្លាតវៃ, ក្លៃវៃត្រចៀកវៃ ...

១. សត្វខ្លែងក្អែកវៃណាស់អាចមើលពីលើអាកាសឃើញ។

វ័យ= ន. (អាយុ) ចំរើនវ័យ, វ័យចំណាស់, វ័យវឌ្ឍនាការ...

១. មនុស្សនេះមានវ័យចំណាស់បន្តិចទៅហើយ ។

## ស

ស= គុ.(ព.ផ្ទុ.ខ្មៅ) សំពត់ស, ស្លៀកសពាក់ស, ទង់ជ័យស

ឧ. យាយនេះស្លៀកសពាក់សកាន់ទុក្ខព្រោះប្ដីគាត់

ទើបនឹងស្លាប់នៅពេលថ្មីៗនេះ ។

ស= កិ. សត្រី, សកេរ្តិ៍, សជាតិ, សសេចក្ដី ...

ឧ. សំដីសជាតិ មារយាទសត្រកូល ។

សរ= ន. (ព្រួញ) កូនសរ, ថ្វៃងសរ ...

ឧ. ព្រះអង្គទ្រង់ថ្វៃងសរ សំដៅទៅសត្រូវ ។

សរ= កិ. (ទឹកឃើញ, ដឹង) សរជាតិ, សរញាណ ...

ឧ. ព្រះពុទ្ធទ្រង់សរញាណ .. ។

សក្តិ-ស័ក្តិ= ន. យសសក្តិ, បុណ្យសក្តិ, ថ្ងៃឡើងសក្តិ.

ឧ. លោកនេះបុណ្យសក្តិមិនអន់ប៉ុន្មានទេ ។

សាក់= ន. ចាក់សាក់, សាក់រូបយ័ន្ត, សាក់យ័ន្តក្បាលប្រាំបី...

ឧ. មនុស្សជាន់ដើមច្រើនតែមានសាក់ពេញទាំងខ្លួន

ស័ង្គ= ន. (អា. ថ. សាំង) ខ្យងស័ង្គ, ផ្លុំស័ង្គ ...

ឧ. ពួកបារគ្បផ្លុំស័ង្គថ្វាយព្រះមហាក្សត្រ ។

សាំង= គុ. (ព.ឆ្ល.ភ្ញាក់ផ្អើល) គោសាំង, មាន់សាំង, ក្របីសាំង.

ឧ. គោនេះសាំងណាស់ ខ្ញុំព្រមតាំងគូកនខ្ញុំអាចជិះវាបាន ។

សង់= កិ. សង់ផ្ទះ, សង់សាលា, សង់ស្ពាន...

ឧ. ឪពុកខ្ញុំទើបតែសង់ផ្ទះថ្មួយខ្នងហើយថ្មីៗ ។

សង្ឃ= ន.(អា.ថ.សង់) ព្រះសង្ឃ, អានិសង្ឃ, ពាក្យសង្ឃ ...

ឧ. ព្រះសង្ឃកាន់ក្រិត្យវិន័យយ៉ាងខ្ជាប់ខ្ជួនតាមពុទ្ធដីកា

សង្ហា= គុ. រូបរាងសង្ហា, សង្ហាណាស់ ...

ឧ. រូបរាងបុរសនេះសង្ហាណាស់ ។

សង្ហារ= ន. ព្រះសង្ហារ, គ្រាព្រះសង្ហារ, សង្ហារឹម, អសង្ហារឹម

ឧ. ទាហានទឹងយុវន៍ពាក់រូបព្រះសង្ហារនៅលើមួក

សត្ត= ប.សំ.(៧) សត្តហៈ, សត្តទិន, សត្តាកិច្ច...

ឧ. ក្នុងសត្តហៈនេះសម្តេចឪយាងទៅសម្ភោធសមិទ្ធ-សក្តិមកស្រុកនិយមនៅតាមខេត្តនានាក្នុងព្រះរាជាណាចក្រ ។

សត្ត-សត្វ= ន. សត្វលោក, សត្តឃាត, សត្វបក្សី...

ឧ. នៅក្នុងព្រៃ ដំរីជាសត្វមាឌធំជាងសត្វដទៃ ៗ

សត្យ= ន.(ទៀងត្រង់-ពិត-ប្រាកដ)ឧ.ពាក្យសច្ចៈពាក្យសត្យ

សាត់= កិ. សាត់ព្រាត់, សាត់អណ្តែតសែតអញ្ជូង...

ឧ. ប្អូនខ្ញុំមិនដឹងជាដើរសាត់អណ្តែតដល់ទីណាទេ

សន្មត-សម្មត= កិ. ខ្ញុំសន្មត, និយាយសន្មត, សន្មតគ្នា...

ឧ. ខ្ញុំសន្មតនឹងលោកថា ខ្ញុំសងលោកនៅថ្ងៃស្អែក ៗ

សន្មតិ-សម្មតិ= ន. ការសន្មតិ, ពាក្យសន្មតិ, សេចក្តីសន្មតិ..

ឧ. បើលោកមានការសន្មតិយ៉ាងនេះនឹងខ្ញុំ ឃើញ

ថាស្រួលហើយ ៗ .

សប់= កិ. សប់កង់, សប់បាល់, សប់ឲ្យតឹង...

ឧ. ឯងយកស្នប់នេះទៅសប់កង់ទោចក្រយានឲ្យខ្ញុំ

សប្ត-សប្តិ-សប្ន= ន.(អា.ថ.សប់) យល់សប្តិ,ដេកយល់សប្ន

ឧ. យប់មិញខ្ញុំយល់សប្តឃើញថា ... ៗ

សព្វ= គុ. (អា.ថ.សប់) សព្វមួយដង, សព្វថ្ងៃ, សព្វកាល...

ឧ. សត្វដង់រៀនដកបមកកាំមិនដែលធ្វើដូច្នេះទេ ។

សព = ន. (អា.ថ.សប់) (ខ្មោច) ហែសព, បូជាសព...

ឧ. សពនេះនឹងដង្ហែទៅបូជានៅចាំងវត្តឧណ្ណា-លោម នាព្រឹកស្អែក វេលាម៉ោង ៩ ។

សព្ទ-សំព្ទ = ន. (អា.ថ.សាប់) កិរិយាសព្ទ, សូរស័ព្ទសំឡេង.

ឧ. នៅក្នុងព្រៃគេឮតែសូរស័ព្ទសម្រែកនៃសត្វ ។

សាប់ = កិ. សាប់ទំពាំង, សាប់ស្វាយ, សាប់ឲ្យញាប់សេ...

ឧ. ថ្ងៃនេះម្ដាយខ្ញុំសាប់ផ្លែល្ហុងធ្វើញាំបរិភោគ ។

សា = កិ. សាកន្ទួល, សាមុង, សាស្រូវ, សាអង្ករ...

ឧ. នរណាដើរសាចុះសាឡើងមុខផ្ទះយើង ?

សា = ន. សាកាច់, ជម្ងឺសា, គោសាកាច់, អាសាកាច់...

ឧ. សេះពួន សាកាច់ឆាប់មួយរំពេច ។

សាស្ត្រ = ប្រវត្តិសាស្ត្រ, ភូមិសាស្ត្រ, វិទ្យាសាស្ត្រ...

ឧ. ទាហានត្រូវរៀនក្បួនយុទ្ធសាស្ត្រឲ្យស្ទាត់មែនទែន ។

សាសន៍=ន. សាសន៍យួន, សាសន៍ចិន, សាសន៍ចាម...

ឧ. នៅស្រុកខ្មែរយើងមានសាសន៍ដទៃមកនៅជាច្រើនៗ

សះ= កិ. សះជា, សះស្បើយ, សះមុខរបួស...

ឧ. ម្ដេចទៅជម្ងឺឯងរជាសះស្បើយហើយឬនៅ ?

សិត= កិ. សិតសក់, សិតទឹក, សិតទៀន, សិតសសរ...

ឧ. ជាងឈើកំពុងតែសិតសសរផ្ទះគេមួយគ្រឿងៗ

សិទ្ធិ= ន. (អា.ថ.សិតធិ) សិទ្ធិការ្យ, សិទ្ធិកម្ម, ស័ក្តិសិទ្ធិ...

ឧ. ថ្នាំលោកគ្រូពូកែស័ក្តិសិទ្ធិណាស់ ៗ

សិរ= ន. (អា.ថ.សេ) (ក្បាល) សិរសា, សិរមាន់...

ឧ. ព្រះអង្គកើយលើរងព្រះសិរផ្ទុំលក់យ៉ាងស្កប់ស្កល់ៗ

សេ= គុ. ញឹកសេ, ញាប់សេ, សាប់ញាប់សេ...

ឧ. នាងនេះធ្វើការឲ្យញាប់ដៃសេគ្មានទំនេរសោះ

សុក= ន. សុកឆ្មា, សុកមនុស្ស, ប្រទាក់ទងសុក...

ឧ. បងប្អូនពីរនាក់នេះកើតមកប្រទាក់ទងសុកនឹងគ្នាៗ

សុខ= ន. (ព.ផ្ទុ ទុក្ខ) សុខសប្បាយ, សុខចិត្ត,សុខទុក្ខ...

ឧ. ខ្ញុំបានសេចក្តីសុខដូចធម្មតាទេ ។

សុក្រ=ន. (អា.ថ.សុក្រ) ថ្ងៃសុក្រ, ផ្កាយសុក្រ...

ឧ. ស្អែកជាថ្ងៃសុក្រ ខ្ញុំសុំពាកមួយថ្ងៃមិនធ្វើការទេ

សូ=ន.(ខ្សែមាសមានសណ្ឋានដូចប្រវក់)ខ្សែសូ, ពាក់ខ្សែសូ

ឧ. ស្រីនេះពាក់ខ្សែសូមួយខ្សែប៉ុនម្រាមដៃនៅចង្កេះ ។

សូរ=ន. ស្តាប់សូរ, ឮសូរ, លាន់សូរ, សូរស័ព្ទ ...

ឧ. យប់ស្ងាត់ជ្រៀប គេគ្មានឮសូរសំឡេងអ្វីក្រៅ
ពីសម្រែកឆ្កែព្រុសព្រះច័ន្ទដែលទើបនឹងរះនាទិសបូព៌ា ។

សូរ្យ= ន.(អា.ថ.សូ)(ព្រះអាទិត្យ) សូរ្យគ្រាស,សូរ្យសែង...

ឧ. ថ្ងៃនេះនឹងមានសូរ្យគ្រាសនៅវេលាម៉ោង១០ ។

សូន= កិ. សូនរូប,សូនរូបអង្គតា, សូនរូបព្រាយបិសាច...

ឧ. រូបចង់ចក់នេះកំពុងសូនរូបព្រាយទុកសែនព្រេន ។

សូន្យ= គុ.(គ្មាន–ទទេ) លេខសូន្យ,ងងឹតសូន្យ,សូន្យឈឹង...

ឧ. ក្នុងបន្ទប់នេះងងឹតស្ទើរតែមើលអ្វីពុំយល់ ។

សួ = កិ. សួស្ពាន, សួមែកឈើ, សួតាមស្មួស្បូវ ...

ឧ. មីងសំមិនបេះសួលើស្ពានឥឡូវធ្លាក់ទឹកប្រួង ។

សួរ = កិ. សួរក, សួរឲ្យឆ្លើយ, សួរសុខទុក្ខ, សួរគេសួរឯង

ឧ. កុំនិយាយដើមពីគេ ប្រយ័ត្នគេសួរមាត់សួរក ។

សួគ៌ = ន. ឋានសួគ៌, ស្រីសួគ៌, បំណាំសួគ៌, ឧសថមកពីសួគ៌...

ឧ. ឈឺធ្ងន់យ៉ាងនេះទោះជា ថ្នាំមកពីសួគ៌ក៏មើលពុំជាដែរ

សោត = និ. ឯងសោត, ខ្ញុំសោត, អ្នកសោតទៀត ...

ឧ. ឯលោកសោតទៀត ក៏មិនត្រូវនិយាយ... ។

ពិសោធន៍ = កិ. ពិសោធន៍ចិត្ត, ធ្វើការពិសោធន៍ ...

ឧ. ខ្ញុំពិសោធន៍សព្វគ្រប់ទៅឃើញថា ការទាំងនេះងាយបំផុត ។

សំ = ន. (ពោមប្រចឹកអ្វីមួយ) ត្រីស៊ីសំ, ត្រីប្រចឹកសំ ...

ឧ. យប់មិញខ្ញុំឮសូរត្រីស៊ីសំ នៅក្បែរគុម្ពស្រូវក្នុង
ស្រែក្បែរផ្ទះខ្ញុំ ។

សំ= ព.ផ្ស. សំខាន់, សំអុយ, សំណើច, សំណាង ...

ឧ. យើងនាំគ្នានិយាយសំណេះសំណាលពីរឿងដើមរបស់យើង ។

សម= គុ. (អា.ថ.សំ) សមគ្នា, គួរសម, សមណាស់, សមគួរ

ឧ. កូនអ្នកបេះគួរបេះសមនឹងកៀវណាស់ ។

សំបាត់= (ពាក្យនេះគ្មានប្រើទេ) ។

សម្បត្តិ-សម្បទ៌= ន. សម្បត្តិទ្រព្យ, ភោគសម្បទ ...

ឧ. លោកសេដ្ឋីនេះមានសម្បត្តិទ្រព្យរាប់មិនអស់

សំបា-សម្បា= កិ.វិ. ខឹងសម្បា, កុំខឹងកុំសំបាអី ...

ឧ. កូនអើយ! កុំខឹងសំបានឹងគេអី គេនៅក្មេងណាស់

សំបារ-សម្បារ= ន. សំបារបេក, ចងនឹងសំបារបេក ...

ឧ. គេកូតសំបារបេកទុករុំអន្សម នឹងចងអីវ៉ាន់ផ្សេងៗ ។

សំរិត-សម្រិត= កិ. សំរិតទឹក, សម្រិតសម្រាំង ...

ឧ. របស់ទាំងនេះខ្ញុំរើសសំរិតសំរាំងទុកជូនលោក

សំរិត–សម្រឹត= គុ. (ព.ផ្ទ.សំរូប) អង្ករសម្រិត ...

ឧ. បើនាងបុកស្រូវកុំបោលអង្ករម ចាស់ទុំលោកហាមអង្ករមជាន់ល្អិត អង្ករសម្រូបទៅជាសម្រិត អង្ករសពិចិត្រដោយសារដៃនាង ។

សំរិទ្ធ–សំរឹទ្ធិ= ន. ព្រះសំរឹទ្ធិ, ផ្តិលសំរឹទ្ធិ, ក្រុងសំរឹទ្ធ ...

ឧ. គ្រូនេះបេះមន្តក្រុងសំរឹទ្ធ ជាន់ភ្លើងមិនខ្លាចក្តៅ

ស្កា= ន. (បាស្កា=ល្បែងឈើគ្រង្គ) លេងបាស្កា, ចាញ់បាស្កា

ឧ. ព្រះបាទព្រហ្មទត្តលេងបាស្កាជាមួយស្តេចគ្រុឌ

ស្ការ= ន. (ស្រដៀងសំពោច) សត្វស្ការ, ស្ការចាប់មាន់ ...

ឧ. ស្ការជាសត្វចង្រៃចាប់មាន់ស៊ីជាអាហារ ។

ឆ្កា= កិ. ឆ្កាព្រៃ, ឆ្កាដៃឆ្កាជើង, ឆ្កាព្រៃគុម្ពោត ...

ឧ. មាណពនេះនិយាយឆ្កាដៃឆ្កាជើងតែម្នាក់ឯង ។

ស្គា= ន. (ស្រដៀងនឹងដើមត្រែង) គុម្ពស្គា, ឫសស្គា ...

ឧ. ព្រៃម្តុំត្រង់នេះ មានច្រើនតែដើមស្គាទ្រុបទ្រុល ។

ស្គាវ= កិ. (សេពមេថុន) ពស់ស្គាវគ្នា, ត្រីស្គាវគ្នា...

១. ពស់ស្គាវគ្នានៅលើមែកឈើសាខាខាងណោះ

ស្ងៀម= កិ. ស្ងាត់ស្ងៀម, ស្ងៀមឈឹង, នៅឲ្យស្ងៀម...

១. សិស្សអង្គុយយ៉ាងស្ងៀមស្ងាត់ចាំស្ដាប់គ្រូ ។

ឈ្ងៀម= គុ. ឈ្ងៀមបាយខ្លោច, ធុំក្លិនឈ្ងៀម...

១. អ្នកណាដុតកៅស៊ូធុំក្លិនឈ្ងៀមអាក្រក់ណាស់

ស្ដារ= កិ. (ជើង«ដ») ស្ដារទឹក, ស្ដារទូក, ស្ដារអន្លង់...

១. ត្រូវស្ដារទឹកឲ្យអស់ពីបាតទូកសិន មុននឹងចេញដំណើរទៅ ។

ស្តា= កិ.វិ.(ជើង«ត») ស្តាចុះស្តាឡើង, ស្តេស្តា ៗ...

១. អ្នកណាពាក់អាវសាត្រា ដើរស្តាចុះស្តាឡើងឯនោះ ។

ស្និត= ន. ស្និតបេក, ស្និតសិតសក់, ដូចស្និតបេក...

១. បុណ្យនេះមានមនុស្សមីរដេរដាសដូចស្និតបេក

ស្និទ្ធ= គុ. ស្និទ្ធស្នាល, ជិតស្និទ្ធ, ធ្វើការស្និទ្ធណាស់...

ឧ. ពូម៉ុកនិងពូមុីករាប់អានគ្នាស្និទ្ធស្នាលណាស់ ។

ស្នើ = កិ. ស្នើការ, សុំស្នើ, ទូលស្នើ ...

ឧ. មុននឹងសម្រេចការនេះខ្ញុំសុំស្នើ ឲ្យបានដឹងជាមុនសិន

ស្នើរ = ន. មួ១ស្នើរ=មាន២ សន្លឹក, មានវគ្គមានស្នើរ, ស្នើរក្រដាស ...

ឧ. បើនិយាយការអ្វីសុំនិយាយឲ្យមានវគ្គមានស្នើរ ។

ស្នា = ន. ស្នាធ្នូ, ស្នាំស្តាំ, អាវធ្លាក់ស្នា, ស្នាគាង ...

ឧ. ដៃមនុស្សយើងជាប់ទៅនឹងដងខ្លួនដោយសារស្នា ។

ស្នារលា = កិ. ស្នារលាទោស, ខ្ញុំសុំស្នារលា ... (ស្នារតី=ន.) ស្នារតីរឹង, តាំងស្នារតី, រន្ធត់ស្នារតី, ភ្លឹកស្នារតី ...

ឧ. កុមារតូចនេះមានស្នារតីតិចណាស់ ។

ស្រុស = កិ. ស្រុសមាន់, ស្រុសទា, ដូចគេស្រុស, ស្រុសទឹកក្តៅ

ឧ. ចិនលក់សាច់ កំពុងតែដាំទឹកក្តៅទុកស្រុសជ្រូក

ស្រុះ= គុ. ស្រុះស្រួល, ស្រុះគ្នា, ស្រុះមតិគ្នា ...

ឧ. បងប្អូនគេហ្នឹងស្រុះគ្នាណាស់ ។

ស្រះ= ន. ជីកស្រះ, ស្រះស្រង់, ដងទឹកស្រះ ...

ឧ. ប្រជាជននាំគ្នាជីកស្រះយកទឹកទុកសំរាប់ប្រើប្រាស

ស្រាស់= គុ. ស្រាស់របង, ស្រាស់គល់, និយាយស្រាស់គល់.

ឧ. ពុកវាឯងទៅកាប់បន្ទាមកស្រាស់របងកុំឲ្យមនុស្សម្នាចូល

ស្លាត= ន. ត្រីស្លាត, ប្រហិតត្រីស្លាត ...

ឧ. ខ្ញុំទៅផ្សារទិញត្រីស្លាតមួយយកមកធ្វើប្រហិត។

ឆ្លាត= គុ. ឆ្លាតវាងវៃ, ឆ្លាតណាស់, វៃឆ្លាត ...

ឧ. សិស្សម្នាក់នេះមិនសូវវៃឆ្លាតសោះ ដូចជាឥតប្រាជ្ញាពេកណាស់ ។

ស្លុះ= គុ. (ផុង, ធ្លាក់) ស្លុះអន្ទង់, ស្លុះរណ្ដៅ...

ឧ. ដើរឲ្យស្រួលបួលប្រយ័ត្នស្លុះរណ្ដៅសំរាម ។

ឆ្លុះ= គុ. (បញ្ចាំង) ឆ្លុះទឹងពិល, ឆ្លុះត្រី, ភ្លឺឆ្លុះសុសសាយ...

ឧ. ភ្លៀងធ្លាក់លើកដំបូងនាដើមឆ្នាំ នៅពេលយប់អ្នកស្រុកនាំគ្នា យកចង្កៀងទៅចុះក្រចុះអង្កែប ភ្លឺព្រោងព្រាតពេញវាលស្រែ ៗ

ស្លេស្ម= ន. (កំហាក) ធ្លាក់ស្លេស្ម, ឡើងស្លេស្ម ...

ឧ. អ្នកជម្ងឺនេះឈឺធ្ងន់ណាស់ទៅហើយ ស្លេស្មឡើងមកស្ទះបំពង់ក លេបថ្នាំលេបទឹកពុំរួចសោះ

ស្លេះ= កិ. (ទុកមួយអន្លើសិន-សង្ខេប) ស្លេះទុកសិន...

ឧ. ឥឡូវខ្ញុំសុំស្លេះរឿងនេះទុកមួយអន្លើសិនចុះ ៗ

# ហ

ហ័ត= (អា.ថ.ហាត់) ហ័តហោង=គុ. ព្រៃហ័តហោង...

ឧ. ក្នុងព្រៃហ័តហោងបែបនេះច្រើនមានខ្មោចបិសាច ៗ

ហត្ថ= ន. (អា.ថ.ហាត់) (ដៃ) លើកហត្ថបង្គំ, ហត្ថលេខា ...

ឧ. ខ្សែគោនេះគេវេញប្រវែង១៥ហត្ថ (ខ្នាតហត្ថ)

ហាត់= កិ. ហាត់ប្រាណ, ហាត់រៀន, ហាត់សរសេរ...

ឧ.ពល់ព្រឹកសិស្សហាត់ប្រាណពុំដែលខាន ។

ហិសៗ= កិ.ស.សំណើចហិសៗ, ពូស្លូរសើចហិសៗ...

ឧ.ឥពុកមាខ្ញុំគាត់សើចពុស្លូរហិសៗឲ្យខ្ញុំផុះ ។

ហស្ថ= ន.(អា.ថ.ហ៏ស់)(ដៃ)ព្រះហស្ថលេខា...

ឧ.សម្តេចឪទ្រង់ឡាយព្រះហស្ថលេខាលើគ្រាំងមាសៗ

គ្រហស្ថ= ន. (អា.ថ.គ្រហ៏ស់) (ព.ផ្ទុ.បព្វជិត), ព្រះសង្ឃ និងគ្រហស្ថ...

ឧ.ព្រះសង្ឃនិងគ្រហស្ថបានមូលមតិគ្នាធ្វើបុណ្យ

ហា= កិ. ហាមាត់, គ្រុំហាសំបក, កប្បាសហាសម្បក...

ឧ.ពេលបរិភោគអាហារមិនត្រូវហាមាត់ធំពេកទេ

ហារ=ន.លេខដើងហារ,លេខហារ,ដើងហារ.(អាហារ=ន.)

ឧ.សម័យសង្គមរាស្ត្រនិយម ប្រជាជនទាំងប្រុស ទាំងស្រីបានសិក្សាអក្សរ និងលេខបូកសងគុណ ហារ គ្រប់ៗគ្នា ។

ហ៊ុម= កិ. ព័ទ្ធហ៊ុម, ហ៊ុមជុំវិញ, ហ៊ុមហ, ហ៊ុមពេន៍, (ផាហ៊ុម=

ន. ហ៊ុម=គុ.) ជណ្ដប់ផាហ៊ុម, ស្អុយហ៊ុម...

ឧ. ស្ត្រីនេះជណ្ដប់ផាហ៊ុមព្រៃទៅលេងបុណ្យ ។

ហំ= ព.ផ្ស. (ទំហំ=ន.) ទំហំមាឌ, ទំហំគល់, ទំហំផ្ទៃក្រឡា

ឧ. ស្រែរបស់លោកមានទំហំផ្ទៃប្រាំរយអារ ។

ហៀ= គុ. ក្រមាស្ដើងហៀ, សំដើងហៀ, សំពត់ស្ដើងហៀ...

ឧ. សារុងនេះស្ដើងហៀយកមកស្លៀកម្ដេចកើត ។

ហៀរ= កិ. ពេញហៀរ, ហូរហៀរ, ហៀរសំបោរ...

ឧ. តួកល្ខោនកំប្លែង ធ្វើឲ្យអ្នកទស្សនាសើចហៀរ

ទឹកភ្នែកហៀរទឹកសំបោរ ។

ហ៊ា= ន. (ពាក្យចិន) (បង់) អាហ៊ា, អាហ៊ាលក់អី...

ឧ. អាហ៊ានេះធ្វើគុយទាវលក់ដាច់ណាស់ ។

ហោ= ន. ឈើគូសមួយហោ, អំបោះមួយហោ, ហោជាន់ផ្ទះ

ឧ. វត្តនៅក្នុងភូមិខ្ញុំ មានឧបាសកឧបាសិកាបានជ្រះថ្លា បរិច្ចាគធនធានបន្តិចបន្តួចម្នាក់ យកទៅសង់ហោ-ត្រៃមួយយ៉ាងល្អសំរាប់ដាក់គម្ពីរ ។

ហោ= គុ. (ហ៊ុង-ជ្រួញ) (ពាក្យចិន) (ល្អ) ដេរកុំឲ្យហោ ...

ឧ. ចូរឯងដេរសំពត់ព្រែនេះកុំឲ្យហោព្រោះវាទន់ៗ

ហោ= កិ. (ខ្ចប់-រុំ) ហោស្ពរ, ហោសព, ហោព្រះសព ...

ឧ. គ្រួសារនៃសពបានទិញសំពត់សមួយផាប់មក ហោបុគ្គលដែលស្លាប់ ។

ហោរ= ន. ចំនាយហោរ, ហោក, ឲ្យហោរគន់គូរមើល...

ឧ. ពាក្យដំណាលថា «ករនៅហោរ ហោរនៅជាង ៗ

ហ្ម= ន. (ភា.ថ.ម៉) ហ្មដំរី, ពេទ្យហ្ម, ហ្មថារ, សត្វគោហ្ម ...

ឧ. ហ្មដំរីនេះប្រសប់បង្ហាត់ដំរីឲ្យបេះសំពះ ។

ម៉= ព.ផ្ស. សត្វគោម៉, គោហ្ម, ម៉ៃ...

ឧ. គោម៉ជាសត្វល្អិតមានសម្បុរលឿងទុំ ។

ហ្មត់=កិ.វិ. អស់ហ្មត់, ចាយហ្មត់, ឆាលីងហ្មត់...

១. កូនខ្ញុំមានប្រាក់ប៉ុន្មានក៏ដោយក៏វាចាយហ្មត់ដែរៗ

ហ្មត់ហ្មង-ម៉ត់ហ្មង=គុ. ល្អហ្មត់ហ្មង...

១. នាងធ្វើការនេះល្អហ្មត់ហ្មងគ្មានទាស់ត្រង់ណា

ហ្មត់ចត់=គុ. និយាយហ្មត់ចត់, ធ្វើការហ្មត់ចត់...

១. ចូរយើងទម្លាប់ធ្វើការអ្វីឲ្យបានហ្មត់ចត់កុំធ្វេសៗ

ម៉ដ្ដ-ម៉ដ្ឋ=គុ.(ព.ផ្ទ.គគ្រាតគគ្រើម) សាច់ម៉ដ្ឋខៃ,សំពត់សាច់ម៉ដ្ដ, ម្សៅម៉ដ្ឋ...

១. សំពត់មួយការនេះសាច់ម៉ដ្ឋជាងសំពត់ព្រៃ ៗ

ហ្លួង=ន. (ស្ដេច-ព្រះមហាក្សត្រ) ក្រុមហ្លួង, អាជ្ញាហ្លួង...

១. ហ្លួងជាម្ចាស់ជីវិតលើត្បូង ទ្រង់គង់ក្នុងព្រះ-បរមរាជវាំង ៗ

លួង=កិ. លួងលោម, លួងចិត្ត, លួងប្អូន...

១. អូនទៅនិយាយលួងលោមចិត្តគាត់ទៅ ព្រោះ

គាត់ខឹងនឹងអូនឯងខ្លាំងណាស់ ។

# ឡ

ឡូ= ន. បោះឡូ, រន្ធឡូ, លេងល្បែងបោះឡូ...

ឧ. ក្មេងៗនាំគ្នាលេងល្បែងបោះឡូស៊ីសងជាប្រាក់ ។

ឡូត៍= ន. ដីមួយឡូត៍, ឡូត៍នៃសាខគ្រី...

ឧ. នៅទីក្រុងកាដការក្រុងបែងចែកដីជាឡូត៍ៗ ។

# អ-អ

អ= ន. បាយអ, ផ្ទុំបីអ, លំអ...

ឧ. ជាងសង់ផ្ទះកំពុងលាយបាយអយកទៅបូកជញ្ជាំង ។

អ= ឧ.ស. អ! លោកអញ្ជើញមកហើយ, អ! ដូច្នោះទេឬ? អ! បើ

ព្រះតេជគុណនិមន្តមកហើយ យើងមិនបាច់ទៅទេ

អរ= កិ. ត្រេកអរ, អរគុណ, កុំអរពេក, ខ្ញុំអរណាស់...

ឧ. បងមានសេចក្ដីត្រេកអរណាស់ ឮថាអូនបានសេចក្ដីសុខ ។

អង់= កិ. (រង់ចាំ) អែអង់, អង់មួយគ្រែត, អង់អាច, បង្អង់...

ឧ. នាងនេះអែអង់ចាំនរណាគេហ្នឹង ?

អង្គ= ន. (អា.ថ.អង់) ព្រះអង្គ, អង្គជាតិ, អង្គកាយ, តួអង្គ..

ឧ. ព្រះអង្គទ្រង់យាងទៅបរទេស ដើម្បីរៀបចំណងមិត្តភាព,

អង្គរ= ន. (អា.ថ.អង់គ) (ក្រុង-ធានី) អង្គរធំ, អង្គរបុរី...

ឧ. នៅថ្ងៃចូលឆ្នាំម្ដង ៗ ប្រជាជនបាននាំគ្នាទៅ លេងអង្គរវត្ត ។

អង្សា= ន. (អា.ថ.អង់សា) (ស្មា) អង្សា, ព្រះអង្សា...

ឧ. ព្រះនាងទ្រង់រួយព្រះអង្សា ព្រោះព្រះនាងពរ ព្រះរាជបុត្រ ។

អង្គា= ន. ដើមអង្គាសិល, ដើមអង្គាដី, ផ្កាអង្គាបុស្ស...

ឧ. បងស្រីខ្ញុំបេះត្រួយនិងផ្កាអង្គាដីយកមកស្ងកកូរ

អង្គារ= ន. ឧ. ថ្ងៃអង្គារគឺជាថ្ងៃទី ៣ នៃមួយអាទិត្យ ។

អដ្ឋ= ច.សំ. (អា.ថ.អាត់) (ប្រាំបី) (អដ្ឋទិស=ប្រាំបីទិស)

(អដ្ឋស័ក=ប្រាំបីឆ្នាំ) (អដ្ឋស្រ=ប្រាំបីជ្រុង) ។.

សូមឲ្យទេវតាទាំងអដ្ឋទិសជួយបីបាច់រក្សា ។

អឌ្ឍ= គុ.(សា.ថ.អាត់ធ:)(អឌ្ឍស័ក=កន្លះឆ្នាំ)(អឌ្ឍមាស=កន្លះខែ)(អឌ្ឍទិន=កន្លះថ្ងៃ)(អឌ្ឍមណ្ឌល=កន្លះឬពាក់កណ្តាលមណ្ឌល) ។

អត្ត=ន. (សា.ថ.អាត់ត:)លេខអត្ត,គន់គូរលេខអត្ត.(អត្តខាត់)

ឧ. លោកតាហោរាកំពុងគន់គូរលេខអត្តជូនកៀវប្រុសស្រីរបស់គាត់ ។

អត្ថ= ន. (សា.ថ.អាត់ថ:)អត្ថប្រយោជន៍, អត្ថរស, អត្ថវិជ្ជា.

ឧ.សេចក្តីខាងលើនេះ តើអ្នកយល់ឃើញថា វា មានអត្ថន័យយ៉ាងណា ?

អាត់= ន. កើតអាត់,អាត់ស៊ីដៃ,ជោះអាត់,អាត់ទឹកអាត់ខ្យល់..

ឧ. ក្មេងស្មោកគ្រោកដៃវាទាំងសងខាងអាត់ស៊ីឡើងគោម

អន់=គុ.(ព.ជ.គ្រាន់បើ.ល្អ) អន់ប្រាជ្ញា,ធុនអន់, អន់ណាស់

ឧ. ប្រហែលជាលោកអាក់អន់ស្រពន់ចិត្តហើយមើលទៅ

អន្ធ = គុ. (អា.ប.អន្ធៈ) អន្ធការ, អន្ធពាល...

ឧ. មនុស្សអន្ធការ ដើររកផ្លូវដោយសារដំបងកាន់នៅដៃ

អន្ដរ = ន. (ដើម«ដ») អន្ដរធាន, កើតអន្ដរកប្ប...

ឧ. ស្រុកកើតអន្ដរកប្បដោយបច្ចាមិត្តរាវលុកលុយរាតត្បាត

អន្តរ = (ដើម«ត») អន្តរជាតិ, អន្តរាយ, អន្តរកថា ...

ឧ. ថ្ងៃនេះព្រឹត្តិការណ៍អន្តរជាតិគួរចង់ឲ្យស្ដាប់ ។

អប្ប ឬ អាប់ = គុ. ប្រាជ្ញាអាប់, អប្បប្រាជ្ញា, អប្បគំនិត អប្បយស

ឧ. យើងមិនត្រូវបន្តុះបង្អាប់ក្មេងទេ នឹងនាំឲ្យវាអប្ប
បញ្ញារៀនសូត្រមិនកើត ។

អ័ព្ទ ឬ អ័ភ្រ = ន. (អា.ប.អាប់) អ្ពូអ័ព្ទ, ងងឹតអ័ព្ទ, ចុះអ័ព្ទ, ស្រ-
អ័ព្ទ ឬ ស្រអាប់ ...

ឧ. ព្រឹកនេះមេឃចុះអ័ព្ទងងឹតរកមើលអ្វីមិនឃើញសោះ

អប្សរ = ន. (អា.ប.អាប់សរ) ស្រីអប្សរ, ទេពអប្សរ អប្សរា...

ឧ. នាងល្អដូចជាស្រីទេពអប្សរចុះមកពីឋានសួគ៌ ។

អផ្សុក= កិ. (មិនសប្បាយ) អផ្សុកអប្បសាន្ត, អផ្សុកក្នុងខ្លួន.

ថ្ងៃនេះខ្ញុំដូចជា អផ្សុកក្នុងខ្លួនពន់ពេកណាស់ ។

អាប់= កិ. អាប់ប្រាក់, អាប់មកវិញ, អាប់លុយលើសទៅគេ.

ឧ. ខ្ញុំឲ្យប្រាក់ ១០ រៀលទៅអ្នកលក់ ។ អាប់មក

វិញចំនួនប្រាក់ ៣ រៀល ។

អសារ=គុ. (ឥតអំពើ, ឥតខ្លឹមសារ) អសារឥតការ ...

ឧ. ឯងនេះបានតែសំដីអសារឥតការទេ ។

អាសា= ន. (បំណង)យកអាសាគេ, អាសាស្ម័គ្រ, មានអាសា

ឧ. អ្នកនេះស្លាប់ខ្លួនដោយជួយយកអាសាគេ ។

អាសា-ឧស្សាហ៍= គុ. អាសាធ្វើការ, អាសារៀនសូត្រ ...

ឧ. ប្រពន្ធខ្ញុំអាសាអាសាញ់ធ្វើការគ្រាន់បើដែរ ។

អាច= កិ. (ហ៊ាន-មិនរុញរា) អាចទៅបាន, អាចធ្វើកើត ...

ម. សមត្ថភាពលោកអាចធ្វើកើតការនេះ ។

អាចម៍=ន.(សា.ថ.អាច់)អាចម៍គោ, អាចម៍ជ្រូក, អាចម៍ត្រចៀក

ម. បើចង់ឲ្យដំណាំដុះបានល្អត្រូវអាសាពាក់ដីអាចម៍សត្វ

អាចារ= ន. (មារយាទ-ឫកពា) មានអាចារៈល្អ, អាចារៈពុំគួរ

ម. នាងនេះធ្វើអាចារៈពុំគប្បីដល់ក្មេកសន្ដានសោះ ។

អាចារ្យ= ន. អាចារ្យវត្ត, គ្រូអាចារ្យ, អាចារ្យកាន់ពេលា...

ម. លោកតាអាចារ្យនេះដើរអង្គាសប្រាក់ធ្វើបុណ្យ

អាថិ= ន. (សា.ថ.អាត) អាថ៌កំបាំង, លាក់អាថិកំបាំង ...

ម. ប្រពន្ធនិយាយការអាថិកំបាំងប្រាប់ប្ដី ។

អាទិ-អាទិ៍= ន.(សា.ថ.អាត) (ដំបូង, ខាងដើម) ជាអាទិ, ដើមអាទិ, នាំអាទិ...

ម. អ្នកណានាំអាទិធ្វើការនេះមុនគេ ?

អារម្ភ= ន. (ពាក្យផ្ដើម, ផ្ដើមមុន) អារម្ភកថា, អារម្ភចិត្ត=ចិត្តគិតតាំងឡើង ...

ឧ. ការម្អកថាកូនសៀវភៅអ្នកនិពន្ធសរសេរយ៉ាងគ្រោះគ្រាយ

អារម្មណ៍= ន. បណ្ដែតអារម្មណ៍, អារម្មណ៍មិនល្អ...

ឧ. អ្នកកម្លោះអង្គុយបណ្ដែតអារម្មណ៍តែម្នាក់ឯង

បារម្ភ= ន.កិ.(ខ្ញុំមានបារម្ភក្រែង=ន.)(ខ្ញុំបារម្ភខ្លាចក្រែង=កិ.)

ឧ. ខ្ញុំមានការបារម្ភជាពន់ពេកក្រែងការរបស់យើង
ក៏មិនបានសម្រេចតាមគោលបំណងរបស់យើងៗ

អិដ្ឋ-ឥដ្ឋ= ន.ឥដ្ឋពណ៌, ផ្ទះឥដ្ឋ, ជញ្ជាំងឥដ្ឋ, គំនរឥដ្ឋ...

ឧ. ជាងកំបោរកំពុងរៀបជញ្ជាំងឥដ្ឋផ្ទះគេមួយខ្នងៗ

ឥត= និ. ឥតខុស, ឥតដឹង, ឥតអំពើ, ឥតប្រយោជន៍...

ឧ. ខ្ញុំឥតចាំងដឹងខ្លួនផង ស្រាប់តែមកប្រហាប់ខ្ញុំ ៗ

ឥទ្ធិ= ន. (សា.ប.អិតធិ)ឥទ្ធិពល, ឥទ្ធិឫទ្ធិ...

ឧ. ក្រុមយើងនេះមានឥទ្ធិពលខ្លាំងណាស់ ៗ

អ៊ុះ= ឧ.ស. អ៊ុះៗ ធ្លាក់ដីឥឡូវហើយៗ អ៊ុះៗ! គ្រឡាប់ឥឡូវៗ

ឧស ឬ អុស= ន. ពុះឧស, កេះឧស, (រឧសស្ពាន=ន.)

ឧ. ខ្ញុំកំពុងរកខុស ឥឡូវមកប្រទះនឹងឈើងាប់ ។

ឱស្ឋ= ន. (អា.ថ.អោស) (មាត់) មានព្រះឱស្ឋ, ព្រះឱស្ឋស្ងួត

ឧ. ព្រះអង្គទ្រង់មានព្រះឱស្ឋខ្ជាំងៗធ្វើឲ្យបរិយាកាសរីករាយ ។

អ៊ុត= កិ. អ៊ុតសក់, អ៊ុតខោអាវ, អ៊ុតអាប៉ោង...

ឧ. ចូររៀនអ៊ុតខោអ៊ុតអាវកុំនៅទំនេរ ។

ឱត្តរ= ន. (អា.ថ.អ៊ុតដរ) ទិសឧត្តរ, ឧត្តរកោរទ្វីប...

ឧ. នៅលើមេឃនាទិសឧត្តរ(ខាងជើង) មានពពក

ខ្មៅដេរដាស ។

អ៊ែ= គុ. អ៊ូអែ, អែៗ, សូរអែ, អែអុក...

ឧ. អ្នកណាខ្លះនិយាយគ្នាអែៗខាងក្រៅឯណោះ?

ឯ= និ. ឯណា, ឯណោះ, ឯនោះ, ឯនេះ...

ឧ. ឯនេះឯនោះសុទ្ធតែមនុស្សច្រើនត្រៀបត្រា ។

–. ចប់ .–

រោងពុម្ព ឧដុង្គស្មើ
លេខ ៤៦ វិថីព្រះបាទសីហនុ ភ្នំពេញ

២០៛